ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- សហរដ្ឋអាមេរិកជួយស្ថាបនាមជ្ឈមណ្ឌលឯកសារកម្ពុជា...
- ហាំ យិនឈេះ : ស្តីពីចេះអក្ខរា?

[illegible]

លេខ ១០៥ ខែកញ្ញា ឆ្នាំ២០០៨

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រៈ សហរដ្ឋអាមេរិកជួយស្ថាបនាមជ្ឈមណ្ឌលឯកសារកម្ពុជា....១

**ផ្នែកឯកសារ**

◆ មៀច សួន ៈ វិស្វករអគ្គិសនីមកពីប្រទេសបារាំង....................៣

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១............៦

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ រូបថតជាភ័ស្តុតាង..........................................................៩

◆ ការស្រាវជ្រាវរូបថតប្រជាជនថ្មី......................................១២

◆ ម៉ា ឃីនមេៈ ស្ទីអ៊ីចេះអង្គការ...........................................២១

◆ ជីវិត ថន បាន ...........................................................២៤

◆ ឌិត សារឿន ទាហានស័ក្ដិ៥ជំនាន់ លន់ នល់........................២៦

**ផ្នែកច្បាប់**

◆ សិទ្ធិនិងកាតព្វកិច្ចរបស់មេធាវីចុងចោទ..............................៣០

◆ សារសំខាន់នៃការរៀបចំសាក្សី.........................................៣៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ការរាប់ចំនួនមនុស្សស្លាប់.................................................៤០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ជីវិតក្នុងភាពនឹងថ្កល់.................................................. ៥១

◆ សុំ រិទ្ធីៈ សុំប្ដីងតុលាការជាតិនិងអន្ដរជាតិជួយរកយុត្តិធម៌......... ៥៥





ម៉ា ឃីនមេ និងកូនៗ

# រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះៈ** យិន នាន, ប៉ាង ពីរ៉ែន, ព្រំ ដល្លា, សុំ រិទ្ធី, សារិន វីរៈ, គង់ សុកគឿន, ម័រហ៊្គិន វ៉ាយថេនី, ប្រ៊ីស សម្រាប **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សូ ហ្វារីណា, **អ្នកបកប្រែៈ** ជី ទេវិទ្ធិ **និពន្ធនាយករងៈ** សាន់ កល្យាណ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** រ័ត្ន គារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ៖*

# សហរដ្ឋអាមេរិកជួយស្ថាបនាមជ្ឈមណ្ឌលឯកសារកម្ពុជាឱ្យក្លាយទៅជាវិទ្យាស្ថានសិក្សាស្រាវជ្រាវអំពីរបបខ្មែរក្រហមដែលមានលក្ខណៈអន្តរជាតិនិងអចិន្ត្រៃយ៍

*នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយជាមួយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ដើម្បីធ្វើឲ្យមានវិធីផ្តល់ជាជំនួយអចិន្ត្រៃយ៍តាមរយៈការបង្កើតឲ្យមានមូលនិធិទាយជ្ជទាន (Endowment) ។ ជំនួយដែលមានទឹកប្រាក់ចំនួន២លានដុល្លារអាមេរិកនេះ ជាអំណោយរបស់ប្រជាជនអាមេរិកាំងដើម្បីផ្តល់លទ្ធភាពឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាបន្តកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការលើកកម្ពស់ចំណេះដឹងនិងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។*



*លោក ម៉ាក ស្តូរឡា ភារធារីនៃស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជាបានថ្លែងនៅក្នុងពិធីនោះថា “ជំនួយនេះបញ្ជាក់ឲ្យឃើញកាន់តែច្បាស់ថែមទៀតនូវការប្តេជ្ញាចិត្តយូរអង្វែងរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា” ។ ក្រោមកិច្ចព្រមព្រៀងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងទទួលបានមូលនិធិទាយជ្ជទានចំនួន២លានដុល្លារអាមេរិកសម្រាប់គាំទ្រដល់ការចំណាយជាមូលដ្ឋាននិងកម្មវិធីផ្សេងទៀតដែលមានទិសដៅច្បាស់លាស់របស់មជ្ឈមណ្ឌល ។ បុព្វហេតុនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាអាចព្យាករណ៍បាននូវចំណូលប្រចាំឆ្នាំដែលគេអាចប្រើប្រាស់សម្រាប់ជាមូលដ្ឋានក្នុងការស្វែងរកធនធានបន្ថែមពីអ្នកដែលផ្តល់ជំនួយនិងអ្នកឧបត្ថម្ភផ្សេងទៀតដើម្បីរក្សាបាននូវឯករាជ្យភាពនិងអធិបតេយ្យភាពរបស់ខ្លួន ។*

*លោក យ៉ូណាថាន់ អែដុលតុន នាយកបេសកកម្មទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលបានធ្វើជាសាក្សីនៅក្នុងពិធីចុះហត្ថលេខានោះ មានប្រសាសន៍ថា “ក្នុងចំណោមអង្គការសង្គមស៊ីវិលទាំងអស់ដែលបានជំនួយពីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាអង្គការមួយដែលយើងគិតថានឹងបន្តបម្រើមនុស្សជំនាន់ក្រោយក្នុងរយៈពេល២០ឆ្នាំ ៥០ឆ្នាំ ឬក៏ ១០០ឆ្នាំ តទៅមុខទៀត” ។ យើងមានជំនឿយ៉ាងមុតមាំថា ជំនួយនេះនឹងជួយដល់មជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យសម្រេចនូវទស្សនវិស័យជាវិទ្យាស្ថានសិក្សាស្រាវជ្រាវអំពីរបបខ្មែរក្រហមដែលមានលក្ខណៈជាអន្តរជាតិនិងអចិន្ត្រៃយ៍មួយ ។ លោក ឆាំង យុ បានថ្លែងថា “មជ្ឈមណ្ឌលឯកសារកម្ពុជាប្រៀបដូចជាផ្លូវជាតិលេខ៤ (សាងសង់ឡើងដោយប្រាក់ជំនួយរបស់ប្រជាជនអាមេរិកាំង) ដែលបានបម្រើប្រជាជនរាប់រយរាប់ពាន់នាក់ បន្ទាប់ពីបានសាងសង់រួចមក ។ មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាកន្លែងដែលអ្នករស់រានពីរបបប្រល័យពូជសាសន៍និងកូនចៅរបស់គាត់អាចរំឭកឡើងវិញនិងចងចាំនូវអតីតកាលដើម្បីជាកម្លាំងសម្រាប់ការរស់នៅបន្តទៅទៀតឲ្យកាន់តែប្រសើរឡើង*

*នៅក្នុងថ្ងៃអនាគត» ។*

មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាវិទ្យាស្ថានស្រាវជ្រាវឯករាជ្យ ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥ ដោយមានជំនួយពីរដ្ឋាភិបាលអាមេរិកនិងប្រទេសជាច្រើននៅអឺរ៉ុប ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលបំណងបម្រើជូនជាអចិន្ត្រៃយ៍នូវប្រភពព័ត៌មានមួយដល់សាធារណជនដើម្បីឲ្យយល់កាន់តែច្បាស់ពីរបបខ្មែរក្រហម និងសម្រាប់ជនកម្ពុជាឬអ្នកដទៃទៀត ដែលមានបំណងស្វែងរកយុត្តិធម៌ពីអំពើប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តក្រោមរបបកម្ពុជាប្រជាធិបតេយ្យកាលពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងចុះបញ្ជីឯកសារសម្ភាសន៍អ្នកដែលមានតួនាទីនៅក្នុងរបបខ្មែរក្រហម រៀបចំផែនទីរណ្តៅសាកសព បង្កើតទស្សនាវដ្តីស្វែងរកការពិត រៀបចំបណ្ណាល័យ បន្ទប់សោតទស្សន៍ រោងពុម្ព និងបន្ទប់តាំងពិព័រណ៍ គ្រប់គ្រងនិងចាត់ចែងហ្វឹកហ្វឺននិងផ្តល់ជំនួយចិត្តសាស្ត្រសង្គមជូនជនរងគ្រោះដែលទទួលរងនូវការធ្វើទារុណកម្មក្នុងរបបខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានត្រៀមខ្លួនសាងសង់មជ្ឈមណ្ឌលស្រាវជ្រាវអចិន្ត្រៃយ៍របស់ខ្លួននៅលើទំហំដីដែលមានទីតាំងនៅក្រោយសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ ទំហំដីនេះជាអំណោយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ការដែលមិនទាន់មានការសាងសង់នៅលើទំហំដីនេះ ដោយមូលហេតុថា មានប្រជាជនក្រីក្រមួយចំនួនធំបាននាំគ្នាមកបោះទីតាំងសង់ផ្ទះនៅលើដីនោះ ហើយរាជរដ្ឋាភិបាលកម្ពុជាមិនទាន់មានលទ្ធភាពដោះស្រាយបាន ។ យើងបានសុំរាជរដ្ឋាភិបាលកម្ពុជានូវទីតាំងថ្មីវិញ ព្រោះប្រជាជនក្រីក្រដែលរស់នៅលើដីនោះសុទ្ធសឹងតែជាជនរងគ្រោះនៃរបបខ្មែរក្រហម ហើយគ្មានលទ្ធភាពផ្លាស់ប្តូរទីតាំងលំនៅបាន ។ ក្រសួងមហាផ្ទៃដែលជាប្រធានគណៈកម្មការដោះស្រាយដីធ្លីសម្រាប់សាងសង់មជ្ឈមណ្ឌលឯកសារកម្ពុជានេះបាននិងកំពុងពិចារណាលើសំណើនេះ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**



*អគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជានិងភរិយា ទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង(ស-២១)*

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# មៀច សួនៈ វិស្វករអគ្គិសនីមកពីប្រទេសបារាំង

មៀច សួន ហៅ សុន ជាវិស្វករអគ្គិសនីបច្ចេកទេសនៅវិទ្យាស្ថានបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត។ សុន មានស្រុកកំណើតនៅឃុំកំពង់លាវ ស្រុកព្រៃវែង ខេត្តព្រៃវែង។ ឆ្នាំ១៩៧៤ សុន បានចេញទៅប្រទេសបារាំង។ ចំណែក ប្រពន្ធនិងកូនពីររបស់ សុន រស់នៅទីក្រុងភ្នំពេញ ហើយត្រូវខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ ។ សុន បានត្រឡប់មកប្រទេសកម្ពុជាវិញនៅក្នុងឆ្នាំ១៩៧៦ ហើយត្រូវអង្គការចាប់ខ្លួននិងសួរចម្លើយនៅមន្ទីរស-២១ ។

សុន សារភាពថា គាត់ចូលចិត្តនយោបាយតាំងពីរៀននៅវិទ្យាល័យម៉េ្ាះ។ នៅពេលទំនេរពីការសិក្សា សុន និងមិត្តភក្តិរបស់គាត់ឈ្មោះ ឆាន់ ថៃ តែងតែចូលបណ្ណាល័យអានសៀវភៅនិងទស្សនាវដ្តីដែលនិយាយពីការលូតលាស់នៃសហរដ្ឋអាមេរិក ។ ចំណេះដឹងទាំងនេះបានបណ្តុះគំនិត សុន ឲ្យមានចំណូលចិត្តនឹងនិន្នាការនយោបាយបែបលោកសេរី ។ នៅឆ្នាំ១៩៦៣ ពេលកំពុងសិក្សានៅវិទ្យាល័យយុគន្ធរ មាននាយទាហានម្នាក់ឈ្មោះ ឃឹម កាស ដែលរស់នៅក្បែរផ្ទះបាននិយាយរឿងនយោបាយបែបលោកសេរីប្រាប់ សុន ជារឿយៗនិងបណ្តុះគំនិតឲ្យ សុន ស្អប់កុម្មុយនិស្តកុម្មុយនិស្តកាន់តែខ្លាំង ហើយប្រឆាំងជាមួយសិស្សនៅក្នុងសាលាដែលមានទស្សនៈខ្មែរក្រហម ។ សុន និងបក្ខពួកថែមទាំងបានធ្វើញត្តិនិងចូលរួមធ្វើបាតុកម្មប្រឆាំងខ្មែរក្រហមនៅតាមវិទ្យាល័យទៀតផង ។

ឆ្នាំ១៩៧០ សុន បានប្រលងជាប់ចូលសិក្សាផ្នែកវិស្វករអគ្គិសនីនៅវិទ្យាស្ថានបច្ចេកទេសមិត្តភាពខ្មែរ-សូវៀតរយៈពេលបួនឆ្នាំ ។ សុន បានចូលជាសមាជិកសមាគមនិស្សិតនៃវិទ្យាស្ថានបច្ចេកទេសនេះដែរ ដែលមាន ម៉ែន ហឿន និងឈ្មោះ ណាង ជាធ្វើជាប្រធាន។ អ៊ុយ វ៉ាន់ថុន ចាងហ្វាងវិទ្យាស្ថានបានហៅ ម៉ែន ហឿន ទៅប្រជុំជាញឹកញាប់ឲ្យគាំទ្ររដ្ឋាភិបាល លន់ ណុល ដើម្បីបានទទួលជំនួយពីសហរដ្ឋអាមេរិកមកស្តារប្រទេសកម្ពុជាដែលកំពុងប្រយុទ្ធតស៊ូជាមួយខ្មែរក្រហម ។

នៅឆ្នាំ១៩៧០ នាយករដ្ឋមន្ត្រី លន់ ណុល បានប្រកាសថាវៀតកុងបានឈ្លានពានមកដល់ខេត្តស្វាយរៀង ហើយក៏យកឱកាសនេះបង្កើតបាតុកម្មមួយដោយស្របច្បាប់ ។ ថ្ងៃទី១៦ ខែមីនា សុន បានចូលរួមធ្វើបាតុកម្មប្រឆាំងនឹងពួកវៀតកុងនៅមន្ទីររដ្ឋសភានិងស្ថានទូតវៀតណាមខាងជើង ។ ថ្ងៃទី១៧និងថ្ងៃទី១៨ ខែដដែល សុន ចូលរួមធ្វើបដាប្រឆាំងនឹងរបបសង្គមចាស់និងបំផុសបំផុលនិស្សិតឲ្យគាំទ្រការដឹកនាំរបស់រដ្ឋាភិបាល លន់ ណុល ។ បាតុកម្មនេះឋិតនៅក្រោមការដឹកនាំរបស់ចាងហ្វាង អ៊ុយ វ៉ាន់ថុន ។ ដោយសារទំនាស់រវាងរដ្ឋាភិបាល លន់ ណុល និងខ្មែរក្រហមចេះតែកើតមានឡើង នៅក្នុងវិទ្យាស្ថានបច្ចេកមិត្តភាពខ្មែរ-សូវៀតបានបង្កើតកងការពារសាលាមួយក្រុមហៅថា «កងយុវជនស្រោចស្រង់ជាតិ» ។ «កងយុវជនស្រោចស្រង់ជាតិ» មានតួនាទីយាមការពារសាលានិងឆែកឆេរគ្រប់ផ្លូវជាតិដែលចូលមកទីក្រុងភ្នំពេញ ។ ក្រៅពីយាមយប់នៅសាលា សុន មានតួនាទីមួយទៀតគឺ យាមឆែកឆេរនៅតាមផ្លូវជាតិលេខ១រយៈពេលមួយខែនិងផ្លូវជាតិលេខ៤រយៈពេលបីខែ ។

ខែកុម្ភៈ ឆ្នាំ១៩៧១ សុន បានចូលរួមធ្វើបាតុកម្មមួយដែលវិទ្យាស្ថានធ្វើឡើងក្នុងគោលបំណងពង្រឹងនយោបាយរដ្ឋាភិបាលលន់ណុលនិងទាមទារឲ្យរដ្ឋាភិបាលនេះទទួលយកជំនួយពីសហរដ្ឋអាមេរិក ។ បន្ទាប់ពីសេនាប្រមុខ លន់ ណុល ឡើងកាន់អំណាច សមាគមនិស្សិតគ្រប់មហាវិទ្យាល័យស្ថិតនៅក្រោមការគ្រប់គ្រងរបស់សមាគមនិស្សិតនៃរបបសាធារណរដ្ឋខ្មែរ ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧២ នៅក្នុងវិទ្យាស្ថានមានប្រារព្ធពិធីមួយរំឭកដល់ថ្ងៃជ័យជម្នះរបស់សេនាប្រមុខ លន់ ណុល(ថ្ងៃដែលលន់ណុលធ្វើរដ្ឋប្រហារ) ។ ក្នុងពេលនោះ ទន់ ហៅ សេង ប្រធាននិស្សិតបានធ្វើសន្និសីទជាមួយព្រះសង្ឃស្តីពីការដាក់ឲ្យប្រទេសខ្មែរឲ្យទៅជារបបសាធារណរដ្ឋខ្មែរ តើវាអាច

ធ្វើប៉ះពាល់ដល់សាសនាដែរឬទេ? ហើយខ្មែរក្រហមដែលធ្វើបាបព្រះសង្ឃនិងការបំបាត់សាសនាយ៉ាងណាដែរ ។ សន្និសីទនេះបានបំផុសស្មារតីនិស្សិតឲ្យមានកំហឹងជាមួយពួកខ្មែរក្រហមកាន់តែខ្លាំង ។ នៅខែតុលា សុន បានចូលរួមក្នុងកងកុម្ម៉ង់ដូនិស្សិត ដង្ហែក្បួនបាតុកម្មចេញពីវិទ្យាស្ថានឆ្ពោះទៅពហុកីឡដ្ឋានអូឡាំពិកដើម្បីថ្កោលទោសពួកខ្មែរក្រហម ។ សុន ក៏បានសរសេរអត្ថបទនិងចូលរួមធ្វើបាតុកម្មថ្កោលទោសខ្មែរក្រហមជាញឹកញាប់ដែរ ។

ខែមិថុនា ឆ្នាំ១៩៧៣ សុន បានចូលជាសមាជិកគណបក្សសង្គម-សាធារណរដ្ឋនិងចូលជាភ្នាក់សេ.អ៊ី.អានៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៤ តាមរយៈ ទន់ និង ប៉េង ស៊ីម ។

ក្រោយមកដោយសារស្ថានការណ៍ស្រុកទេសកាន់តែដុនដាប សេង បានបញ្ជូន សុន ទៅប្រទេសបារាំង ។ សុន បានទៅដល់ប្រទេសបារាំងថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៤ ដែលមាន ផុង ម៉ានយ៉ា និង ដាន់ បួយហាក់ (ធ្វើការនៅផ្ទះទូតសាធារណរដ្ឋខ្មែរប្រចាំប្រទេសបារាំង)ចាំទទួលនៅទីនោះ ។ អ្នកទាំងពីរបាននាំ សុន ទៅស្រស់ស្រូបអាហារនិងបើកលុយដំណើរទៅខេត្តណង់ស៊ី (ប្រទេសបារាំង)ដើម្បីជួបឈ្មោះ ឃួន សុផល ។ ថ្ងៃទី២០ កើត សាវ៉ាត បាននាំ សុន ទៅដល់ទីស្នាក់ការសមាគមនិស្សិតខ្មែរ សម្តែងភាពស្និទ្ធស្នាលនិងធ្វើការជាមួយគ្នា ។ ឃួន សុផល បានឲ្យ សុន ធ្វើជាអ្នកប្រមូលកម្លាំងនិស្សិតដើម្បីរៀបចំជាកម្លាំងស្នូលដណ្តើមអំណាចពីបដិវត្តន៍វិញ និងបន្ទាប់មកដាក់ប្រទេសកម្ពុជាចូលជាបក្សសម្ព័ន្ធរបស់សហរដ្ឋអាមេរិក ។ កម្លាំងស្នូលទាំងអស់នេះត្រូវបញ្ជូនមកបង្កប់ខ្លួននៅក្នុងប្រទេសកម្ពុជា ។

## ភារកិច្ចរបស់ សុន ចូលមកប្រទេសកម្ពុជា

ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៥ សុន និងជនជាតិខ្មែរចំនួន ៤០នាក់ដែលរស់នៅប្រទេសបារាំងត្រូវអង្គការអនុញ្ញាតឲ្យចូលប្រទេសវិញ ។ មកដល់ប្រទេសកម្ពុជា សុន ត្រូវបំពេញភារកិច្ចមួយចំនួនៈ

១)ស៊ើបរកឈ្មោះ ដាត់ ស៊ីផូ វិស្វករប្រចាំនៅខេត្តព្រះវិហារ និង មៀច សយ ជាបងប្រុសនិងកម្មាភិបាលយោធាស្រុកល្វាឯម ដើម្បីឲ្យអ្នកទាំងពីរនេះជួយស៊ើបពិនិត្យមើលផ្នែកនយោបាយ តើប្រទេសកម្ពុជាពិតជាអព្យាក្រឹតឬសង្គមនិយមនិងការទំនាក់ទំនងប្រទេសចិននិងកូរ៉េខាងជើង និងវៀតណាមយ៉ាងណា?

២)ស៊ើបរកឃ្លាំងសេដ្ឋកិច្ចធំៗ ។ ស៊ើបពិនិត្យលើផ្នែកយោធា តើកម្ពុជាមានមូលដ្ឋានសឹកចិនប៉េកាំងនិងកូរ៉េខាងជើងឬទេ នៅកន្លែងណាខ្លះ តើនរណាខ្លះទទួលខុសត្រូវខាងកងទ័ពជើងអាកាស ជើងទឹក និងជើងគោក ។

៣) ស៊ើបពិនិត្យពីរបៀបរៀបចំការការពារក្រុងតើមានអាវុធអ្វីខ្លះដែលសំខាន់ជាងគេ ។ ពិនិត្យរួចត្រូវរាយការណ៍ទៅ ទូច ហៅ វ៉ុន ដើម្បីបញ្ជូនដំណឹងនេះទៅក្រៅប្រទេស ។

សុន សម្រាកនៅទីក្រុងប៉េកាំងមួយយប់និងមកដល់ចំណតអាកាសយានដ្ឋានពោធិចិនតុងនៅថ្ងៃទី១៩ ។ សុន ត្រូវអង្គការបញ្ជូនមកស្នាក់នៅមន្ទីរមួយស្ថិតជិតវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាពខ្មែរ-សូវៀតរយៈពេលពីរខែ១០ថ្ងៃ ដែលក្នុងរយៈពេលនោះអ្នកមកពីបរទេសកើនឡើងរហូតដល់២០០នាក់ ។ បន្ទាប់មកអង្គការបានបើកវគ្គសិក្សានិងឆ្លងជីវទស្សន៍លើកទី១ ។ វគ្គសិក្សានោះនិយាយអំពី «វីរភាពរបស់កងទ័ពបដិវត្តន៍ប្រជាជន កម្មករកសិករ ក្រោមការដឹកនាំរបស់អង្គការ ដោយធ្វើសង្គ្រាមប្រជាជនតាំងពីបាតដៃទទេ រហូតបានទទួលជ័យជម្នះពីសហរដ្ឋអាមេរិក។ សង្គ្រាមនេះគឺធ្វើដោយប្រជាជនកម្ពុជាគ្មានជំនួយពីបរទេសទាល់តែសោះ» ។ សុន ស្រងាកចិត្តពេលឮដូច្នេះ ពីព្រោះអ្វីដែលគាត់បានឮកាលពីនៅក្រៅប្រទេស ខ្មែរក្រហមឃោសនាថា សង្គ្រាមនៅក្នុងប្រទេសកម្ពុជានេះ ខាងកងទ័ពបដិវត្តន៍មានកងទ័ពវៀតណាមខាងជើងនិងវៀតកុងជាអ្នកជំនួយ ។ កងទ័ពបដិវត្តន៍ឈ្នះសង្គ្រាមដោយសារអាមេរិកឈប់ធ្វើសង្គ្រាម ។ ក្រោយពីបញ្ចប់វគ្គសិក្សា សុន បានដើរបំផុសអ្នកមកពីបរទេសដូចគ្នាកុំឲ្យជឿលើនយោបាយដឹកនាំប្រទេសរបស់អង្គការបដិវត្តន៍ ។ សុន តែងប្រជុំគ្នាពិភាក្សាពីមាគ៌ានយោបាយរបស់អង្គការបដិវត្តន៍រាល់ល្ងាច ។

## នៅភូមិតាឡី

ថ្ងៃទី២៨កុម្ភៈ ឆ្នាំ១៩៧៦ អង្គការបានបញ្ជូនពួកមកពីបរទេសទៅនៅភូមិតាឡី ស្រុកដង្កោ ខេត្តកណ្តាល ។ តាមផ្លូវទៅកាន់ភូមិតាឡី សុន បានរៀបរាប់ថា មានសភាពស្ងាត់ជ្រងំ ឃើញមានតែកងការពារយាមតាមផ្លូវធំៗ ។ សុន រស់នៅមន្ទីរតាឡីអស់រយៈពេលជាងបីខែ គ្មានសិទ្ធិសេរីភាពដើរតាមចិត្តទេ សូម្បីតែ

ការទំនាក់ទំនងជាមួយពួកមកពីបរទេសក៏ពុំសូវហ៊ានដែរព្រោះខ្លាចអង្គការសង្ស័យ ។

ថ្ងៃទី៦ ខែមិថុនា អង្គការបានបញ្ជូន សុន ទៅរៀនវគ្គសិក្សានិងធ្វើជីវទស្សន៍លើកទីពីរនៅវិទ្យាស្ថានបច្ចេកទេសភ្នំពេញ ។

## នៅភូមិព្រែកប្ញស្សី

ក្រោយពីបញ្ចប់វគ្គ សុន និងមនុស្ស៥០នាក់ទៀត ត្រូវអង្គការបញ្ជូនទៅនៅមន្ទីរព្រែកប្ញស្សី ស្រុកតាខ្មៅ ដើម្បីមើលថែដំណាំ ។ សុន នៅតែបន្តការអួតសរសើរពីការដឹកនាំនិងការរៀបចំប្រទេសរបស់ពិភពលោកឲ្យយុវជនមន្ទីរព្រែកប្ញស្សីស្តាប់ជាហូរហែ ប៉ុន្តែគាត់ត្រូវយុវជនទាំងនោះ កសាងនិងធ្វើស្វ័យទិតៀនទៅវិញ ។ សុន បំផុសឲ្យអ្នកនៅមន្ទីរស្តាប់វិទ្យុនិងបង្កឲ្យអ្នកនៅមន្ទីរទំនាស់គ្នាដូចនៅមន្ទីរតាឡីដែរ ។ សុន រស់នៅមន្ទីរភូមិព្រែកប្ញស្សីរយៈពេល៣ខែនិង២៦ថ្ងៃ អង្គការចាប់ខ្លួន គាត់មកមន្ទីរស-២១ និងសួរចម្លើយនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៦ ។

សុន ត្រូវបានសួរចម្លើយចំនួនបីលើក ។ ដែលនៅក្នុងនេះមានភ្ជាប់បញ្ជីឈ្មោះអ្នកពាក់ព័ន្ធចំនួន៣៦នាក់និងឯកសារសរុបចម្លើយចំនួន៥សន្លឹកចុះហត្ថលេខាដោយសមមិត្ត លាង ហួយ ថ្ងៃទី១៥ ធ្នូ ១៩៧៦ សង្ខេបពីសកម្មភាពក្បត់របស់ សុន តាំងពីនៅរៀនរហូតដល់ចូលប្រទេស ។ នៅក្នុងនោះ ឌុច ជ.គណៈសួរនិងដកស្រង់ចម្លើយ បានសំណូមពរទៅអង្គការពិនិត្យអំពីករណី មៀច សួន និង មៀច សយ តាមដានជាក់ស្តែង ។

## អំពីក្រុមគ្រួសារ

ប្រពន្ធឈ្មោះ នង ដារី ។

កូនស្រី ឈ្មោះ មៀច វិថាវីន និងកូនប្រុសឈ្មោះ មៀច វិធារ៉ា ។ សួន មានបងប្អូន៧នាក់ ប្រុស៦ និងស្រី១÷

១) ឈ្មោះ មៀច សយ កម្មាភិបាលយោធាស្រុកល្វាឯម ទទួលផ្នែកនយោបាយ ។ ២) មៀច សុខុន និស្សិតបច្ចេកទេសនៅមហាវិទ្យាល័យខត្តុនិយម ។៣) មៀច សារុម សិស្សនៅសាលាមធ្យមកសិកម្មព្រែកលាប ។ ៤) មៀច សិរីវិទ្ធ និស្សិតបច្ចេក-ទេសនៅមហាវិទ្យាល័យខតុនិយម ។ ៥) មៀច សិទ្ធិសុវណ្ណ សិស្សវិទ្យាល័យថ្នាក់ទី៣ចាក់អង្រែ ។ ៦) មៀច ផាន់ដារ៉ាស៊ី សិស្សថ្នាក់ទី៧នៅសាលាបឋមសិក្សាវត្តប្រយូរវង្សភ្នំពេញ ។ ៧) មៀច សិរីវុត្ថា (ស្រី) សិស្សថ្នាក់ទី៧ នៅសាលាបឋមសិក្សាសុធារសភ្នំពេញ ។

ឪពុកឈ្មោះ មៀច សុត អតីតអ្នកយាមឃ្លាំងរតនាគារក្រុង ។ ថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ អ្នកទាំងអស់នេះត្រូវអង្គការជម្លៀសចេញពីទីក្រុងភ្នំពេញ ។

**លី សុផល**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ÷

◆ វិទ្យុ FM១០២MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧:៣០-៧:៤៥ល្ងាច ។

◆ វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

◆ វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧:០០-៧:៣០ព្រឹក និងម៉ោង៦:៣០-៧:០០ល្ងាច ។

◆ វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩:០០-៩:៣០ព្រឹក និងម៉ោង៣:០០-៣:៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើងនិងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**សូ ហ្វារីណា និង លី សុផល**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២២៤៦ | គុន ភុន ហៅ រេន | យុទ្ធជន | ជាមពល | ៣-៤-៧៧ | ១៣-៤-៧៧ |
| ២២៤៧ | ភុក ហេង (ស្រី) | មើលកុមារ | ស-២១យ | ??-៣-៧៧ | ១៣-៤-៧៧ |
| ២២៤៨ | ប៉ុល ប៊ុន ហៅ ពេន | យុទ្ធជន | ស-២១យ | ២៣-៣-៧៧ | ១៣-៤-៧៧ |
| ២២៤៩ | ប៉ុល រិន | យុទ្ធជន | ស-២១យ | ២៣-៣-៧៧ | ១៣-៤-៧៧ |
| ២២៥០ | ខាន់ ខិន ហៅ វឿន | យុទ្ធជន | ស-២១យ | ២៧-៣-៧៧ | ១៣-៤-៧៧ |
| ២២៥១ | ហ៊ិន គា | យុទ្ធជន | ស-២១យ | ២៧-៣-៧៧ | ១៣-៤-៧៧ |
| ២២៥២ | គីម កយ ហៅ ខ្វត | យុទ្ធជន | ស-២១យ | ២៧-៣-៧៧ | ១៣-៤-៧៧ |
| ២២៥៣ | កែប ហៃ ហៅ ចាន់ថា | យុទ្ធជន | ស-២១យ | ២៧-៣-៧៧ | ១៣-៤-៧៧ |
| ២២៥៤ | ហ៊ឹម ពុធ | យុទ្ធជន | ស-២១យ | ២៧-៣-៧៧ | ១៣-៤-៧៧ |
| ២២៥៥ | ប៉េង ថន ហៅ អឿន | យុទ្ធជន | ស-២១យ | ១៥-៣-៧៧ | ១៣-៤-៧៧ |
| ២២៥៦ | ស្រី កឿន ហៅ ឌឿន | យុទ្ធជន | ស-២១យ | ១៥-៣-៧៧ | ១៣-៤-៧៧ |
| ២២៥៧ | ស៊ុយ សំបាត់ ហៅ ខុន | យុទ្ធជន | ស-២១យ | ១៥-៣-៧៧ | ១៣-៤-៧៧ |
| ២២៥៨ | កុក សារ៉េត | មេក្រុម | ស-២១យ | ១៥-៣-៧៧ | ១៣-៤-៧៧ |
| ២២៥៩ | ដេន ដឿន | យុទ្ធជន | ស-២១យ | ១-៣-៧៧ | ១៣-៤-៧៧ |
| ២២៦០ | ហែម លុន | យុទ្ធជន | ស-២១យ | ២៩-១-៧៧ | ១៣-៤-៧៧ |
| ២២៦១ | មួយ គីមលី | យុទ្ធជន | ស-២១យ | ២៩-១-៧៧ | ១៣-៤-៧៧ |
| ២២៦២ | រី វឿន | យុទ្ធជន | ស-២១យ | ១០-៣-៧៧ | ១៣-៤-៧៧ |
| ២២៦៣ | លាង ហេង (ស្រី) | ប្រពន្ធ សានីត | ស-២១យ | ៣-៤-៧៧ | ១៣-៤-៧៧ |
| ២២៦៤ | ខ្វត ម៉ាន់ ហៅ វ៉ុន (ស្រី) | ប្រពន្ធ សុត យ៉េ | ស-២១យ | ២៧-៣-៧៧ | ១៣-៤-៧៧ |
| ២២៦៥ | ញឹម ថា ហៅ ណាំ (ស្រី) | យុទ្ធជន | ស-២១យ | ២៧-៣-៧៧ | ១៣-៤-៧៧ |
| ២២៦៦ | ចិន លី ហៅ វ៉ុង (ស្រី) | ប្រពន្ធ ណៃ | កងពល៤៥០ | ៣១-៣-៧៧ | ១៣-៤-៧៧ |
| ២២៦៧ | ប៉ែន ស៊ីណែត ហៅ ណិត (ស្រី) | ប្រពន្ធ ហាក់ ឈាវហុង | ស-២១ យ | ៣-៤-៧៧ | ១៣-៤-៧៧ |
| ២២៦៨ | សៀង ស៊ីណេ ហៅ នី (ស្រី) | មើលកុមារ | កងពល៤៥០ | ១១-៣-៧៧ | ១៣-៤-៧៧ |
| ២២៦៩ | ហុក ហាត ហៅ ហាន (ស្រី) | ប្រពន្ធ ចាន់ ជីង | ស-២១យ | ២៧-៣-៧៧ | ១៣-៤-៧៧ |
| ២២៧០ | ចាន់ ញឹមស៊ីវន (ស្រី) | ប្រពន្ធ ម៉ក់ សុខុន | ស-២១យ | ២៧-៣-៧៧ | ១៣-៤-៧៧ |
| ២២៧១ | មួយ (ស្រី) | ប្រពន្ធ ប្រាក់ ហេង | ស-២១យ | ២៧-៣-៧៧ | ១៣-៤-៧៧ |
| ២២៧២ | បាវ យិន ហៅ ថា | យុទ្ធជន | ស-២១ | ២-៥-៧៧ | ៥-៥-៧៧ |
| ២២៧៣ | ស្វាយ ទៀង ហៅ ស៊ុន | យុទ្ធជន | ស-២១ | ២-៥-៧៧ | ៥-៥-៧៧ |
| ២២៧៤ | កាំង អៀតាំង | យុទ្ធជន | ស-២១ | ២-៥-៧៧ | ៥-៥-៧៧ |
| ២២៧៥ | ដួ សែត ហៅ ថេ (ស្រី) | យុទ្ធនារី | កងពល៣១០ | ៤-៥-៧៧ | ៥-៥-៧៧ |

| | | | | | | |
|---|---|---|---|---|---|---|
| ២២៧៦ | ជិន ជឿន ហៅ យុទ្ធ | មេក្រុម | មន្ទីរវ-៦៦ | ៤-៥-៧៧ | ៥-៥-៧៧ | ដកទៅវិញ |
| ២២៧៧ | ជា សាម៉ុន ហៅ ហង់ សុគុន | យុទ្ធជន | មន្ទីរវ-៦៦ | ? | ៥-៥-៧៧ | ដកទៅវិញ |
| ២២៧៨ | នូវ ឆេងចិន | កម្មករចាស់ | រោងចក្រជ-៧ | ១០-២-៧៧ | ៥-៥-៧៧ | ឈឺស្លាប់ |
| ២២៧៩ | ពឹង គីមស៊ា | វេជ្ជបណ្ឌិត | ភូមិភាគពាយ័ព្យ | ? | ៦-៥-៧៧ | ទារុណកម្ម |
| ២២៨០ | តូច ខាំឌឿន | សមាជិកប-១ | ការបរទេស | ? | ៦-៥-៧៧ | ឈឺស្លាប់ |
| ២២៨១ | ឈន រីម ហៅ ណាង | យុទ្ធជន | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៨២ | ពេជ មាន់ថា ហៅ រុន | យុទ្ធជន | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៨៣ | គីម ហ៊ីន ហៅ គឿន | ភ័ស្តុភារ | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៨៤ | អ៊ុយ ហឿន ហៅ ធឿន | យុទ្ធជន | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៨៥ | យុ ហួត | បញ្ជាការ | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៨៦ | មាស ហឿង ហៅ អង់ | មេក្រុម | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៨៧ | ណែម វឿន ហៅ សួន | នីរសា | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៨៨ | ជា ញឹប | បញ្ជាការ | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៨៩ | កែវ កែម | ភ័ស្តុភារ | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៩០ | ដាំ ប៊ុនលី ហៅ ដល | បញ្ជាការ | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៩១ | ស ឈន់ ហៅ យឿន | យុទ្ធជន | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៩២ | គិត បេន ហៅ សាង | យោធាកងធំ | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៩៣ | យ៉ាន យត ហៅ ពល | មេពួកពេទ្យ | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៩៤ | យិន ម៉ុន | ភ័ស្តុភារ | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៩៥ | ឌី រ៉ូ ហៅ ភាប់ | អនុក្រុម | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៩៦ | មាស ឈុន ហៅ ថាត | អនុក្រុម | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៩៧ | មាស សុក ហៅ ស៊ីម | សមាជិក | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៩៨ | អ៊ុន ថាវ | បញ្ជាការ | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២២៩៩ | អ៊ុម អឿន ហៅ អឿ | បញ្ជាការ | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២៣០០ | ប៉ិល ទូច ហៅ ជិន | មេពួក | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២៣០១ | ខាត់ ស្រេត ហៅ ដា | បញ្ជាការ | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២៣០២ | ដៃ ហួន ហៅ ភាព | យុទ្ធជន | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២៣០៣ | យ៉ែម មុនី ហៅ រ៉ែន | សមាជិក | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២៣០៤ | សាត សយ | សមាជិក | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២៣០៥ | សំ សយ | យុទ្ធជន | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២៣០៦ | សែន ហេន | អនុក្រុម | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២៣០៧ | ឌុច ហាប់ ហៅ វៀន | បញ្ជាការ | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២៣០៨ | តែ ប៊ុនតៃ ហៅ ថន | បញ្ជាការ | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២៣០៩ | សាំង ជឿន ហៅ ជេត | យុទ្ធជន | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | |
| ២៣១០ | តឹក តុងស្រេង | សមាជិក | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ | **(នៅមានត)** |

# ស្វែងរករូបថតថែរក្សាទុកនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានថតនៅរវាងឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧៥

ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានចំណងជើងថា "ជីវិតក្នុងភាពទីងថ្កល់" ដែលបង្ហាញអំពីរូបថតជាច្រើនដែលបន្សល់ទុកពីសម័យខ្មែរក្រហម ។ សៀវភៅនេះរៀបរាប់អំពីដំណើរជីវិតរបស់បុរស៣៥នាក់និងស្ត្រី១៦នាក់មកពីខេត្តកំពង់ចាម កណ្ដាល កំពង់ធំ និងតាកែវ ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ មនុស្សចំនួន៣៩នាក់ ក្នុងចំណោម៥១នាក់ដែលបានចុះនៅក្នុងសៀវភៅនេះបានស្លាប់នៅមន្ទីរសន្តិសុខ ស-២១ ហើយមានតែ៩នាក់ប៉ុណ្ណោះដែលមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងពេលឆាប់ៗខាងមុខនេះ យើងនឹងអានអត្ថបទស្ដីពីរឿងរ៉ាវរបស់មនុស្សមួយចំនួននៅក្នុងសៀវភៅនេះផ្សាយតាមរលកធាតុអាកាសវិទ្យុ FM102MHz ទីក្រុងភ្នំពេញ វិទ្យុ FM93.25MHz ខេត្តកំពត វិទ្យុ FM99MHz ខេត្តព្រះវិហារ និងវិទ្យុFM ១០៣.២៥MHz ខេត្តបាត់ដំបង ។

ក្នុងការសរសេរសៀវភៅនេះ យើងបានធ្វើសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម ប្រជាជនមូលដ្ឋាន និងសមាជិកក្រុមគ្រួសាររបស់អ្នកទាំងនោះ ។ សាក្សីរបស់យើងបានឲ្យរូបថតជាច្រើនមកយើង ដែលភាគច្រើននៃរូបថតទាំងនោះបានថតមុនពេលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ប៉ុន្តែក៏មានរូបថតកម្មាភិបាលមួយចំនួនបានថតក្នុងអំឡុងពេលចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។

សៀវភៅដែលរួមមានទាំងរូបថតនិងរឿងរ៉ាវអមជាមួយនេះបានទទួលជំនួយពី "ទាយជ្ជទានជាតិដើម្បីប្រជាធិបតេយ្យ" ។ សៀវភៅនេះបង្ហាញថា អ្នកដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមមានក្ដីសង្ឃឹមនិងការចង់បានដូចជាប្រជាជនកម្ពុជាដទៃទៀត ហើយអ្នកទាំងនោះក៏បានជួបប្រទះនូវការលំបាកជាច្រើនដែរ រួមទាំងការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួនផង ។ យើងសង្ឃឹមថាសៀវភៅនេះនឹងជួយឲ្យប្រជាជនកម្ពុជាយល់ថា ទាំងជនរងគ្រោះនិងជនដៃដល់គឺជាមនុស្សដូចគ្នា ។

ឥឡូវនេះ យើងមានគម្រោងសរសេរសៀវភៅថ្មីមួយក្បាលទៀតដែលរៀបរាប់អំពីដំណើររឿងរបស់ប្រជាជនថ្មីនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ។ ប្រសិនបើលោកអ្នកឬសាច់ញាតិណាម្នាក់របស់លោកអ្នកជាប្រជាជនថ្មី ហើយចង់រួមចំណែកចែករំលែករឿងរ៉ាវនៅក្នុងសៀវភៅនេះយើងនឹងទៅសម្ភាសលោកអ្នកដោយផ្ទាល់ ។ យើងសូមស្វាគមន៍ចំពោះការចូលរួមចំណែករបស់ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ហើយដោយសារតែរូបថតទាំងនេះជាផ្នែកមួយដែលមានសារសំខាន់សម្រាប់សៀវភៅ យើងគ្រាន់តែស្នើសុំការជួយជ្រោមជ្រែងពីសំណាក់ប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចែករំលែករូបថតរបស់ខ្លួនតែប៉ុណ្ណោះ ។ រូបថតទាំងនោះចាំបាច់ត្រូវតែជារូបថតដែលបានថតមុនឬក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងនឹងថតចម្លងរូបថតរបស់អស់លោកអ្នក បន្ទាប់មកនឹងប្រគល់រូបថតដើមជូនទៅលោកអ្នកវិញ ។



សូមលោកអ្នកទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ០២៣ ២១១ ៨៧៥ ឬផ្ញើលិខិតមកប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញឬទាក់ទងតាមអ៊ីមែល truthpivoine@dccam.org ។

សូមអរគុណ ។

# រូបថតជាភស្តុតាង


សួស សារិន

សួស សារិន អាយុ៥៣ឆ្នាំ ជាប្រជាជនរស់នៅឃុំសំបួរ ស្រុកស្វាយទាប ខេត្តស្វាយរៀង ។ សារិន មានបងប្អូនទាំងអស់៥នាក់ បងពីរនាក់បានបាត់ខ្លួនដោយសារចូលបម្រើចលនាបដិវត្តន៍ខ្មែរក្រហម ។ សួស សារ៉ាន់ ជាបងស្រីបង្អស់បានបាត់ខ្លួននៅក្នុងឆ្នាំ១៩៧៨ ចំណែកបងប្រុស សួស ម៉ុន បាត់ខ្លួននៅឆ្នាំ១៩៧៣ ។ សារិន រង់ចាំដំណឹងអ្នកទាំងពីរនាក់អស់រយៈពេលជាច្រើនឆ្នាំមកហើយ ទើបតែនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០០៥ សារិន ទទួលបានប្រវត្តិរូបរបស់ សួស សារ៉ាន់ ពីអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ នោះគឺជាប្រវត្តិរូបអ្នកទោសគុកទួលស្លែង ។ នៅក្នុងប្រវត្តិរូប សារ៉ាន់ ត្រូវអង្គការចាប់ខ្លួនមកដាក់គុកទួលស្លែងនៅថ្ងៃទី២៨/៣/៧៨ ។ ចាប់តាំងពីថ្ងៃទទួលបានឯកសារ សារិន សម្រាន្តមិនលក់ទេ ។

សារិន និងស្វាមី ព្រមទាំងក្មួយស្រីបានមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃ២៩ ខែសីហា ឆ្នាំ២០០៥ ។ សារិន បានប្រាប់ពីអារម្មណ៍របស់គាត់ថា គាត់ចាប់អារម្មណ៍តាំងពីទូររបងពណ៌ខ្មៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឡើងទៅ ។ សារិន បានប្រាប់ក្មួយស្រីគាត់ថា «របងនេះជារបងកាន់ទុក្ខ» ។

សារិន អង្គុយបើកមើលសៀវភៅរូបថតអ្នកទោសមួយស្របក់ក៏ប្រទះឃើញរូបថតបងស្រី ។ ភ្លាមនោះដោយមិនអាចពិពណ៌នាបាន សារិន យំអស់មួយសន្ទុះទើបបន្លឺសំឡេងថា «ឃើញបងហើយៗ» ។

សារ៉ាន់ បានបញ្ចប់ការសិក្សាត្រឹមថ្នាក់ទី៨ ។ សារ៉ាន់ និងយុវនារីនៅក្នុងភូមិបីនាក់ បានចាកចេញពីផ្ទះទៅបម្រើបដិវត្តន៍តាមការអំពាវនាវរបស់សម្តេចឪនៅឆ្នាំ១៩៧២ ។ សារិន រំឭកថា «ខ្ញុំបានឃាត់គាត់កុំឲ្យទៅ ប៉ុន្តែគាត់ថា សម្តេចឪទៅហើយបងនៅមិនបានទេ» ។ ចន្លោះឆ្នាំ១៩៧១ដល់ឆ្នាំ១៩៧៥ សារ៉ាន់ បម្រើការនៅពេទ្យឃុំសំបួរ ហើយបានទទួលការហ្វឹកហ្វឺនអស់រយៈពេលមួយឆ្នាំកន្លះ បន្ទាប់មកធ្វើការខាងផលិតថ្នាំនៅពេទ្យឃុំ ។ ក្រោយឆ្នាំ១៩៧៥ សារ៉ាន់ ត្រូវអង្គការបញ្ជូនទៅធ្វើការនៅក្នុងអង្គភាពនារីតំបន់២៣ ខេត្តស្វាយរៀង ។ សារិន ធ្លាប់ទៅលេងកន្លែងបងស្រីធ្វើការបានម្តង ។ នៅកន្លែងរបស់ សារ៉ាន់ មានម្ហូបអាហារឆ្ងាញ់ៗហូបគ្រប់គ្រាន់ ខុសពីប្រជាជននៅសហករណ៍ដែលខ្វះខាតម្ហូបអាហារសូម្បីតែអំបិលក៏គ្មានផង ។ សារិន បាននិយាយអំពីភាពខុសនៅតំបន់និងសហករណ៍ប្រាប់បងស្រី ប៉ុន្តែកម្មាភិបាលម្នាក់ដែលធ្វើការជាមួយ សារ៉ាន់ បានព្រមាន សារិន កុំឲ្យនិយាយផ្តេសផ្តាស ។

សារិន និយាយថា សារ៉ាន់ ស្រឡាញ់ប្អូនៗណាស់ ។ ពេលដែលគាត់ពុំទាន់ចេញទៅបម្រើបដិវត្តន៍ សារ៉ាន់ រាប់រងការងារក្នុងផ្ទះទាំងអស់ សូម្បីតែពេលដែលគាត់ចូលបម្រើបដិវត្តន៍ហើយក៏ដោយ សារ៉ាន់ នៅតែឆ្លៀតពេលដេរសម្លៀកបំពាក់មកឲ្យប្អូនៗដែរ ។ សារ៉ាន់ បានមកលេងផ្ទះបានបីដងមុនពេលបាត់ខ្លួន ។ លើកទី១ សារ៉ាន់ បានយកសម្លៀកបំពាក់ប្រាំមួយកំប្លេមកឲ្យប្អូនៗ ។ លើកទី២ សារ៉ាន់ បានយកថ្នាំពេទ្យឲ្យម្តាយព្យាបាលជំងឺសន្លាក់ឆ្អឹង ។ នៅពេលមកលេងផ្ទះម្តងៗ សារ៉ាន់ តែងណែនាំប្អូនៗឲ្យខិតខំធ្វើការងារកុំជំទាស់នឹងអង្គការ និងជួយមើលថែឪពុកម្តាយផង ។ លើកទី៣គឺក្នុងឆ្នាំ១៩៧៨ សារ៉ាន់ បានមកលេងផ្ទះម្តងទៀត ដោយទឹកមុខស្រពាប់ស្រពោនក្នុងឯកសណ្ឋានខ្មៅបង់កក្រមានិងបង្កេចខោអាវតូចមួយ ដែលនៅក្នុងនោះមានចាំឡូមួយដាក់បាយមួយដុំប៉ុនកំភ្លូនជើង ។


សួស សារ៉ាន់ ឆ្នាំ១៩៧៨

សាវ៉ាន់ បានប្រាប់ប្អូនថា «ដល់ពេលណាអស់កម្លាំងបងហូបតិចៗ ទៅបើអាចទៅរួច» ។ សាវ៉ាន់ ផ្តាំផ្ញើ សារិន ឲ្យជួយមើលថែរក្សាប្អូនៗ និងម្តាយចាស់ជំនួសខ្លួនផង ព្រោះខ្លួនគាត់ត្រូវរត់ទៅប្រទេសវៀតណាមហើយ ។ សារិន រំឭកថា «ប្អូនឯងនៅមើលថែម៉ែប្អូនៗទៅ បងចេញទៅយួនហើយ មិនដឹងជាស្លាប់រស់ទេ ។ បើបងមិនទៅបងពិតជាស្លាប់ បើបងស្លាប់គ្មានធាតុធ្វើបុណ្យទេ ។ ប្អូនកុំនិយាយកិច្ចការអី ប្អូនធ្វើពលកកម្មតាមគេទៅប្រយ័ត្នគេយកវៃចោល ។ អត់មានរៀនសូត្រទេ កុំថាគេយកទៅរៀនសូត្រមានតែយកអូនឯងទៅវៃចោលទេ» ។ សមមិត្តនារីខ្មែរក្រហមម្នាក់ដែលធ្លាប់ស្គាល់ក្រុមគ្រួសាររបស់ សារិន បានប្រាប់ សារិន ថា សាវ៉ាន់ មានបំណងរត់ទៅប្រទេសវៀតណាមដើម្បីគេចពីការបោសសម្អាតរបស់អង្គការ ។ សាវ៉ាន់ ក៏បាត់ខ្លួនតាំងពីពេលនោះមក ។ ក្រោយមកពេល សារិន កំពុងធ្វើការ ខ្មែរក្រហមម្នាក់ដែលមកសុំទឹកផឹកបានខ្សឹបប្រាប់ សារិន «មិត្តនារី! បងសមមិត្តនារីគេចាប់ហើយ» ។ សារិន បានប្រាប់ថានៅពេលនោះគាត់ស្ទើរតែពុំអាចគ្រប់គ្រងអារម្មណ៍បាន ។

បីខែក្រោយពីការបាត់ខ្លួនបងស្រី ក្រុមគ្រួសាររបស់ សារិន ឋិតក្នុងការតាមដានរហូត ។ មានថ្ងៃមួយសមមិត្តខ្មែរក្រហមម្នាក់បានគំរាម សារិន ថា «បើរកបងមិត្តនារីមិនឃើញ យកមិត្តនារីឯងទៅរៀនសូត្រ ។

សារិន បានឲ្យដឹងថា ប្រជាជនមួយចំនួនបានភៀសខ្លួនទៅប្រទេសវៀតណាម ត្រូវខ្មែរក្រហមយកគោឬក្របីទៅដូរជាមួយប្រទេសវៀតណាមដើម្បីយកជនភៀសខ្លួនទាំងនោះមកសម្លាប់ចោល ។ គ្រូបង្រៀនម្នាក់ឈ្មោះ ស សារិន ដែលរស់នៅភូមិជាមួយគាត់បានភៀសខ្លួនទៅប្រទេសវៀតណាម ត្រូវបានខ្មែរក្រហមយកក្របីទៅដូរយកគាត់មកវិញ ហើយបន្ទាប់មកចងគាត់វាយធ្វើបាបនៅក្នុងវត្តសំបួរនៅចំពោះមុខប្រជាជនដើម្បីកុំឲ្យប្រជាជនយកតម្រាប់តាម ។ ក្រោយមក ខាងវៀតណាមដឹងរឿងនេះ ក៏បានបញ្ឈប់ការដោះដូរ ។

អង្គការបានជម្លៀសប្រជាជននៅភូមិភាគបូព៌ាឲ្យទៅរស់នៅភូមិភាគផ្សេងដើម្បីកុំឲ្យប្រជាជនបន្តភៀសខ្លួនទៅប្រទេសវៀតណាមទៀត ។ ខ្មែរក្រហមពុំបានពន្យល់ប្រជាជនអំពីហេតុផលទាំងនេះទេ ផ្ទុយទៅវិញបែរជាប្រាប់ប្រជាជនថា អង្គការឲ្យប្រជាជនទៅរស់នៅតំបន់សំបូរសប្បាយមិនខ្វះម្ហូបអាហារទេ ។ ពេលដល់កន្លែងរស់នៅថ្មី អតីតប្រជាជននៅភូមិភាគបូព៌ាត្រូវអង្គការបង្ខំឲ្យធ្វើការងារធ្ងន់ៗ ប្រឈមមុខនឹងកង្វះខាតម្ហូបអាហារកាន់តែខ្លាំងជាងមុន និងត្រូវយកទៅសម្លាប់ច្រើនជាងប្រជាជនដទៃទៀត ។ អង្គការបានយកកម្មាភិបាលមកពីភូមិភាគនិរតីមកគ្រប់គ្រងប្រជាជននៅភូមិភាគបូព៌ា ។ ជាទូទៅប្រជាជននិយាយថាកម្មាភិបាលភូមិភាគនិរតីកាចសាហាវ ប៉ុន្តែ សារិន និយាយថា ក្រុមគ្រួសាររបស់គាត់ត្រូវបានប្រធានសហករណ៍ឈ្មោះ យ៉ាវ និងប្តី ឈ្មោះ វង វឿន ដែលជាកម្មាភិបាលមកពីភូមិភាគនិរតីជួយសង្គ្រោះ បន្ទាប់ពីគាត់ត្រូវជម្លៀសចេញពីភូមិកំណើតមករស់នៅស្រុកកៀនស្វាយ ។ យ៉ាវ បានសុំ សារិន ធ្វើជាប្អូនធម៌និងជួយកាន់បញ្ជីកត់ត្រាម៉ោងធ្វើការ


ក្រុមគ្រួសារមីង ស្លស សារិន មកទស្សនកិច្ចនៅមជ្ឈមណ្ឌលកម្ពុជា

នៅសហករណ៍ ។ មិនតែប៉ុណ្ណោះ ក្រុមគ្រួសាររបស់ សារិន បានរស់នៅសុខស្រួលជាងប្រជាជនដទៃទៀតដែលជម្លៀសចេញពីភូមិភាគបូព៌ាដូចគ្នា ។ យ៉ាវ និង វឿន បានអនុញ្ញាតឲ្យ សារិន ធ្វើពិធីបូជាសពម្តាយក្មេករបស់គាត់ ដោយមានអាចារ្យ៥នាក់សូត្រធម៌ ។ ពេលមួយប្តីរបស់ សារិន បានលួចបេះផ្លែដូងពីរផ្លាយ ហើយត្រូវឈ្លបចាប់បាន ប៉ុន្តែ វឿន បានចេញមុខការពារនិងដោះលែងវិញ ។ ជិតចូលដល់ឆ្នាំ១៩៧៩ វឿន បានប្រាប់ឲ្យក្រុមគ្រួសាររបស់ សារិន រត់ទៅស្រុកកំណើតវិញ បើពុំនោះទេនឹងត្រូវខ្មែរក្រហមសម្លាប់ដោយសារតែបេះផ្លែដូងពីរផ្លាយនោះជាពុំខាន ។

តាំងពីពេលវិលមករស់នៅភូមិកំណើតវិញ ក្រុមគ្រួសាររបស់ សារិន ទន្ទឹងមើលផ្លូវ សាវ៉ាន់ និង ម៉ុន ប៉ុន្តែមិនឃើញវិលមកវិញសោះ ។

បន្ទាប់ពីបានរៀបរាប់ប្រាប់នូវសាច់រឿងរបស់គាត់ សារិន បានសម្តែងនូវអារម្មណ៍សប្បាយរីករាយថា «បងខ្ញុំស្លាប់ហើយ ប៉ុន្តែមានឯកសារមានរូបថតបន្សល់ឲ្យខ្ញុំ ទោះខ្ញុំមិនបានអដ្ឋិធាតុក៏ត្រេកអរដែរ ដែលបានរូបថតយកទៅធ្វើបុណ្យតាមប្រពៃណីខ្មែរ» ។ លើសពីនេះទៀត គាត់បានសំណូមពរឲ្យជួយរកបងប្រុសគាត់ម្នាក់ទៀត ។ សារិន ប្រាប់ថា ការរៀបរាប់រឿងរ៉ាវបានធ្វើឲ្យគាត់រសាយចិត្តបានខ្លះ ហើយកំហឹងនិងការឈឺចាប់របស់គាត់ដែលនៅសល់នឹងរលាយបាត់នៅពេលគាត់បានឃើញសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានបង្កើតឡើងដើម្បីរកយុត្តិធម៌ជូនគាត់និងព្រលឹងអ្នកដែលស្លាប់ទៅ ។ សារិន និយាយថា គាត់នឹងផ្ញើពាក្យបណ្តឹងរបស់គាត់មកកាន់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅពេលសាលាក្តីនេះចាប់ផ្តើមដំណើរការ ។

**ព្រុំ ផល្លា និង លី សុផល**

## វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែររៀបចំកម្មវិធី «វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» លើកទី២ ចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត និងប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យព័ត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮនិងទស្សនៈផ្ទាល់ខ្លួនរបស់លោកអ្នកចំពោះរបបកម្ពុជាប្រជាធិបតេយ្យដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ÷

- រួមចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់ឲ្យកូនចៅជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។
- ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខការខឹងគុំកួនមកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។
- ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។
- ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនិងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។ សូមទាក់ទងព័ត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។ សូមអរគុណ ។

# ការស្រាវជ្រាវរូបថតប្រជាជនថ្មី

## ប៉ុន អារុណ
## អតីតក្រឡាបញ្ជីសាលាដំបូង

កូនស្រីរបស់ ប៉ុន អារុណ ឈ្មោះ អារុណ ដាតិប៉ុណ្ណារី បានផ្ញើអត្ថបទមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ប៉ុណ្ណារី បានភ្ជាប់ជាមួយនូវរូបថតពីរសន្លឹកគឺ រូបថតឪពុកធំនិងជីតារបស់គាត់ដែលថតមុនឆ្នាំ១៩៧៥ ។ រូបថតឪពុករបស់ ប៉ុណ្ណារី ដែលនៅសេសសល់នេះគឺដោយសារបងស្រីរបស់គាត់លាក់ទុកយ៉ាងប្រយ័ត្នប្រយែងនៅក្នុងរបបខ្មែរក្រហម ។ រូបថតអ៊ំនិងជីតារបស់ ប៉ុណ្ណារី បានមកពីសាច់ញាតិដទៃទៀត ។ ប៉ុណ្ណារី បានកប់រូបថតផ្សេងៗទៀតចោលនៅក្នុងស្រុកឈូកនៅក្នុងរបបខ្មែរក្រហមអស់ទៅហើយ ។ បច្ចុប្បន្ន ប៉ុណ្ណារី រស់នៅក្នុងឃុំគានី ស្រុកអង្គជ័យ ខេត្តកំពត ។ ខាងក្រោមនេះគឺជាការរៀបរាប់របស់ ប៉ុណ្ណារីៈ



ប៉ុន អារុណ ថតពេលមានអាយុ២០ឆ្នាំ
ក្នុងទសវត្សរ៍ឆ្នាំ១៩៥០

ប៉ាម៉ាក់ខ្ញុំស្រឡាញ់គ្នាណាស់ ។ គាត់ទាំងពីរបានឆ្លងកាត់ឧបសគ្គជាច្រើនទម្រាំតែបានរស់នៅជាមួយគ្នា ។ ម៉ាក់ខ្ញុំជាតួឯកល្ខោនបាសាក់នៅម្តុំផ្សារកាប់គោ ។ ម៉ាក់ខ្ញុំស្អាតណាស់ ។ គាត់គឺជាកូនកំព្រាឪពុកម្តាយមកពីខេត្តកំពត ។ ចំណែកប៉ាខ្ញុំជាកូនខុកញ៉ា ។ ប៉ាចាប់ចិត្តស្រឡាញ់ម៉ាក់តាំងពីពេលគាត់ជួបគ្នាលើកដំបូង ។ ប៉ាទៅមើលម៉ាក់រាំល្ខោនជារៀងរាល់ថ្ងៃ ។ លោកយាយខាងប៉ារបស់ខ្ញុំមិនពេញចិត្តនឹងម៉ាក់របស់ខ្ញុំឡើយ ។ ពេលដែលគាត់ដឹងពីទំនាក់ទំនងរវាងប៉ានិងម៉ាក់គាត់រកវិធីជាច្រើនដើម្បីបំបែកបំបាក់អ្នកទាំងពីរ ។ ទោះជាយ៉ាងណា ប៉ារបស់ខ្ញុំនៅតែស្អាត់មករកម៉ាក់ ។ ដោយឃើញប៉ារបស់ខ្ញុំស្រឡាញ់ម៉ាក់ខ្លាំងពេក អ្នកម្នាង យុន គាតដែលជាថៅកែរោងល្ខោន បានរៀបចំពិធីមង្គលការឲ្យប៉ាម៉ាក់ខ្ញុំតាមប្រពៃណីខ្មែរ ។ សាច់ញាតិខាងប៉ាមិនបានមកចូលរួមពិធីមង្គលការទេ ។ ក្រោយពីប៉ាម៉ាក់ខ្ញុំរៀបការហើយ លោកយាយនៅតែចង់បំបែកបំបាក់គាត់ទាំងពីរនាក់ទៀត ។ ម៉ាក់ខ្ញុំមានផ្ទៃពោះកូនទី១ លោកយាយមានបំណងឲ្យប៉ារៀបការជាមួយប្រពន្ធថ្មី ប៉ុន្តែប៉ាមិនព្រម ។ ប៉ាបានវិលមករកម៉ាក់វិញ ។ ពេលម៉ាក់កើតបានខ្ញុំ លោកយាយនៅតែចង់បំបែកពួកគាត់ម្តងទៀត ប៉ុន្តែនៅតែមិនអាចបំបែកបាន ។ នៅទីបំផុតលោកយាយក៏យល់ព្រមទទួលស្គាល់ម៉ាក់ខ្ញុំជាកូនប្រសាដោយសារគាត់អាណិតចៅៗ ។

លោកយាយបាននាំម៉ាក់ចូលក្នុងវាំងធ្វើជាអ្នកសម្អាងកាយឲ្យអ្នករាំល្ខោនហ្លួង ។ ចំណែកប៉ាបានឈប់ធ្វើទាហានមកធ្វើពេទ្យនៅក្នុងវាំង ។ ក្រុមគ្រួសារខាងប៉ាសុទ្ធតែអ្នកធ្វើការនៅក្នុងវាំង ។ ប៉ាធ្វើការបានតែ៤ឆ្នាំ អ៊ំប្រុសរបស់ខ្ញុំក៏មកបបួលប៉ាទៅធ្វើការនៅខាងក្រឡាបញ្ជីសាលាដំបូង ។ ប៉ាធ្វើការនៅភ្នំពេញបាន២ឆ្នាំផ្លាស់ទៅធ្វើការជាក្រឡាបញ្ជីសាលាដំបូងស្រុកតាខ្មៅ ខេត្តកណ្តាល ។ ពេលនោះអ៊ំប្រុសរបស់ខ្ញុំបានសុំឲ្យខ្ញុំទៅរស់នៅជាមួយគាត់ពីព្រោះគាត់មានតែកូនប្រុស ។ ខ្ញុំបានទៅរស់នៅជាមួយអ៊ំប្រុសបានតែ១ឆ្នាំក៏សុំគាត់ត្រឡប់មកផ្ទះខ្ញុំវិញ ។ ក្រុមគ្រួសារអ៊ំរបស់ខ្ញុំរស់នៅរបៀបជាអ្នកវាំង ។ អ៊ំស្រីរបស់ខ្ញុំជាប់ខ្សែរាជវង្សហើយគាត់កាចណាស់ ។

នៅឆ្នាំ១៩៦៦ ប៉ាបានផ្លាស់ទៅធ្វើការនៅខេត្តកំពត ។ ពេលនោះក្រុមគ្រួសារខ្ញុំបានផ្លាស់ទៅរស់នៅទីនោះទាំងអស់គ្នា ។ ផ្ទះរបស់ខ្ញុំនៅទីរួមខេត្តនៅជិតផ្សារកំពត ។ ប៉ាមានដីចម្ការជាច្រើនហិកតានៅថ្មរូង ហើយចូលហ៊ុនជាមួយអ៊ំប្រុសរបស់ខ្ញុំដើម្បីដាំ

ដំណាំលក់ ។ ដីនោះមានដាំដំណាំដូចជា សាវម៉ាវ ដូង និងធូរេន ។ នៅទីនោះប៉ាំនៅតែធ្វើការងារជាក្រឡាបញ្ជីដដែល ។ ពេលខ្លះខ្ញុំបានទៅជាមួយគាត់ ហើយខ្ញុំអង្គុយចាំគាត់នៅក្នុងបន្ទប់ធ្វើការរបស់គាត់ ។ ប៉ាស្លៀកសម្លៀកបំពាក់ជាអ្នកកាត់ក្តី ។ ប៉ាច្រើនតែដោះស្រាយរឿងទំនាស់ដីធ្លីនិងរឿងកាប់សម្លាប់គ្នា ។

ឆ្នាំ១៩៦៩ ខ្ញុំបានភ្ជាប់ពាក្យជាមួយបុរសម្នាក់ ប៉ុន្តែក្រោយមកផ្តាច់ពាក្យវិញ ដោយសារម្តាយរបស់គាត់ចង់ឲ្យខ្ញុំទៅរស់នៅខាងគាត់នៅឯខេត្តពោធិសាត់ ប៉ុន្តែប៉ាម៉ាក់ខ្ញុំមិនព្រម ។

នៅដើមឆ្នាំ១៩៧៥ សាលាដំបូងត្រូវបិទទ្វារ ហើយផ្លូវថ្នល់ត្រូវកាត់ផ្តាច់និងមានការទម្លាក់គ្រាប់បែកស្ទើរគ្រប់ទីកន្លែង ។ ប៉ាម៉ាក់ខ្ញុំសម្រេចចិត្តទៅរស់នៅទីក្រុងកំពង់សោមដោយយកប្អូនៗ៧នាក់ទៅជាមួយ ។ ចំណែកខ្ញុំនិងបងស្រីរបស់ខ្ញុំដែលមានគ្រួសារហើយ អត់បានទៅតាមប៉ាម៉ាក់ទេ គឺបន្តរស់នៅខេត្តកំពតដដែល ។ ប៉ាទៅទីនោះដោយសារគាត់មានបំណងឆ្លងទៅប្រទេសក្រៅ ។ នៅកំពង់សោមម៉ាក់និងប្អូនៗរបស់ខ្ញុំប្រកបមុខរបរលក់ដូរបន្តិចបន្តួច ចំណែកប៉ាមានជំងឺសម្រាកនៅតែផ្ទះ ។

នៅថ្ងៃរំដោះ ប៉ាម៉ាក់និងប្អូនៗរបស់ខ្ញុំបានឡើងជិះកប៉ាល់តាមសមុទ្រជាមួយទាហាន លន់ ណុល បម្រុងទៅប្រទេសថៃ ។ កប៉ាល់ចេញពីច្រាំងបានតែបន្តិច ប៉ាសម្រេចចិត្តត្រឡប់មកវិញ ព្រោះគាត់ចង់មករកខ្ញុំនិងបងស្រី ។ ពេលមកដល់ច្រាំងវិញ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសាររបស់ខ្ញុំឲ្យទៅព្រៃនប់ ។ អង្គការបានចាត់តាំងឲ្យក្រុមគ្រួសារខ្ញុំទៅរស់នៅភូមិស្នាច់ដែង ។ នៅទីនោះអង្គការបានចាត់តាំងឲ្យប៉ាខ្ញុំកាប់ទន្រ្ទានខែត្រនិងកាប់ដី ។ ដំបូងឡើយក្រុមគ្រួសារខ្ញុំហូបបាយនៅតាមផ្ទះព្រោះមានអង្ករដែលសេសសល់ ។ ក្រោយមក អង្គការចាត់តាំងឲ្យហូបបាយរួម ។ បងប្អូនរបស់ខ្ញុំ៤នាក់ទៅរស់នៅជាមួយប៉ា ។ ចំណែកប្អូនៗដែលមានគ្រួសារហើយ ត្រូវអង្គការបញ្ជូនឲ្យទៅរស់នៅភូមិផ្សេង ។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានយកប៉ាខ្ញុំទៅសម្លាប់ចោល ។ យប់នោះ ឈ្លបបានមកហៅប៉ាថា «អើលោកក្រឡាបញ្ជីរៀបចំអីវ៉ាន់ទៅភូមិថ្មី» ។ ម៉ាក់ខ្ញុំបានឲ្យប្អូនប្រុសខ្ញុំ២នាក់ទៅតាមមើលប៉ា ។ ប្អូនខ្ញុំឃើញឡានមួយចតនៅមុខមន្ទីរឃុំ ។ ឈ្លបបានចងស្លាបសេកប៉ា ហើយយកក្រណាត់ខ្មៅចងមុខគាត់ជិត ។ ប្អូនខ្ញុំទាំងពីរនាក់ពួនយំ ព្រោះមិនអាចជួយប៉ាបាន ។ ប៉ាត្រូវដឹកតាមឡានចេញទៅជាមួយអ្នកទោសផ្សេងៗទៀត ។ ពេលត្រឡប់មកផ្ទះវិញ ប្អូនខ្ញុំបានជួបឈ្លបនៅតាមផ្លូវ ហើយឈ្លបនោះសួរវាថា «មកពីណាទាំងយប់អធ្រាត្រ?» ប្អូនខ្ញុំឆ្លើយថា «មកពីរកគោ» ។ ឈ្លបបានគំរាមប្អូនខ្ញុំមិនឲ្យដើរទៅណាផ្តេសផ្តាស ប្រយ័ត្នកងទ័ពឃើញ ។ ពេលម៉ាក់របស់ខ្ញុំដឹងរឿងរបស់ប៉ា គាត់ពិបាកចិត្តណាស់ ។ គាត់គិតថាប៉ាពិតជាស្លាប់ហើយ ព្រោះមានប្រជាជនជាច្រើននាក់ក៏ត្រូវដឹកចេញទៅភូមិថ្មីដែរ ហើយមិនដែលបានឃើញត្រឡប់មកវិញទេ ។ ប្រជាជនមូលដ្ឋាននៅទីនោះខ្សឹបប្រាប់ម៉ាក់ថា កុំរង់ចាំប៉ាអី ប៉ាពិតជាស្លាប់ ។ ក្រោយពីអង្គការយកប៉ាទៅ ម៉ាក់នៅធ្វើការដូចធម្មតា ។ គាត់ចិញ្ចឹមជន្លូវនាងនិងមើលថែទាំកុមារតូចៗនៅមណ្ឌលកុមារ ។ មួយខែក្រោយពីប៉ាស្លាប់ប្អូនស្រីខ្ញុំឈ្មោះ វ៉ាដា បានទៅលេងម៉ាក់ ប៉ុន្តែឃើញតែផ្ទះស្ងាត់ជ្រងំ ហើយទ្រើងននោងដែលប៉ាធ្លាប់ដាំបាក់ខ្ទេចខ្ទីអស់ ។ អ្នកជិតខាងបានលួចខ្សឹបប្រាប់ប្អូនខ្ញុំថា ម៉ាក់និងប្អូន៤នាក់ទៀតត្រូវអង្គការយកទៅភូមិថ្មីហើយ ។ មានប្រជាជនខ្លះនិយាយថាអង្គការមិនវាយសម្លាប់ប៉ាទេ គឺដឹកឡានយកទៅចាក់ចោលនៅក្នុងជ្រោះពេជ្រនិល ។

ចំណែកខ្ញុំដែលរស់នៅខេត្តកំពត ត្រូវអង្គការជម្លៀសមកខាងស្រុកឈូក ។ នៅមុនឆ្នាំ១៩៧៥ ខ្ញុំបានរៀបការជាមួយបុរសម្នាក់ឈ្មោះ វ៉ាវី តាមការរៀបចំរបស់ប៉ាម៉ាក់ខ្ញុំ ។

ពេលជម្លៀសចេញពីខេត្តកំពត ខ្ញុំឆ្លងកាត់ការលំបាកជាច្រើនជាមួយប្តីរបស់ខ្ញុំ ។ យើងធ្វើដំណើរដោយគ្មានគោលដៅ គឺទៅតាមតែការចាត់តាំងរបស់អង្គការ ។ អង្គការបានចាត់តាំងខ្ញុំមករស់នៅភូមិព្រៃស្បូវ ឃុំមានជ័យ ស្រុកឈូក ខេត្តកំពត ។ ទៅដល់ទីនោះ ខ្ញុំគិតក្នុងចិត្តដោយសប្បាយរីករាយថា ពិតជាបានជួបបងប្អូនខាងម្តាយរបស់ខ្ញុំដែលរស់នៅក្បែរនោះមិនខាន ។ ប៉ុន្តែនៅពេលខ្ញុំទៅដល់ទីនោះ សាច់ញាតិទាំងអស់មិនទទួលស្គាល់ខ្ញុំ ហើយថែមទាំងនិយាយថា គាត់គ្មានបងប្អូនដែលជាពួកខ្មាំង (អ្នក១៧មេសា) ទេ ។ នៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំនិងប្តីព្រមទាំងកូនប្រុសអាយុពីរឆ្នាំ បានធ្វើដំណើរមកដល់វត្តអង្គស្វាយនៅ

ក្នុងភូមិអន្លង់ស្វាយ ឃុំមានជ័យ ។ អង្គការបានចាត់តាំងឲ្យខ្ញុំទៅដកស្ទូងជាមួយកងស្រ្តី ។ ប្តីខ្ញុំធ្វើការនៅក្នុងកងយុវជន ។ កូនរបស់ខ្ញុំនៅក្នុងកងកុមារមានចាស់ៗជួយមើលថែរក្សា ។ ពីមុនខ្ញុំមិនដែលស្គាល់អ្វីដែលហៅថាការងារស្រែចម្ការទេ ។ ខ្ញុំរស់នៅក្រោមការមើលងាយពីសំណាក់ស្រ្តីមូលដ្ឋានមួយចំនួនថា ខ្ញុំជាអ្នក១៧មេសាធ្លាប់តែជិះជាន់គេ ដល់ឲ្យស្ទូងធ្វើមិនកើត ។ ប្រធានក្រុមរបស់ខ្ញុំគឺជាអ្នកមូលដ្ឋាន ។ ខ្ញុំធ្វើការជាច្រើននៅក្នុងសហករណ៍ ដូចជា ស្ទូងស្រូវ ដកសំណាប និងរែកដី ។ ខ្ញុំត្រូវដកសំណាបក្នុង១ថ្ងៃឲ្យបានពី៣ទៅ៤ដួន ។ ប្រសិនបើខ្ញុំធ្វើមិនបានគ្រប់តាមផែនការ ខ្ញុំត្រូវប្រធានក្រុមស្តីបន្ទោស និងត្រូវអង្គប្រជុំទិតៀន ។

ប្តីរបស់ខ្ញុំស្លូតណាស់ ។ គាត់តែងតែជួយខ្ញុំជានិច្ច ។ នៅពេលមួយខ្ញុំមានជំងឺពិសនៅថ្គាមខាងឆ្វេង ប្តីខ្ញុំខំស្វែងរកគ្រូពេទ្យមកព្យាបាលខ្ញុំ ។ អង្គការស្តីបន្ទោសគាត់យ៉ាងខ្លាំង ប៉ុន្តែគាត់នៅតែលួចមកសួរសុខទុក្ខខ្ញុំរហូតដល់ខ្ញុំជាសះស្បើយ ។

នៅពាក់កណ្តាលឆ្នាំ ១៩៧៧ អង្គការចាត់តាំងប្រជាជនឲ្យទៅធ្វើទំនប់ម្លេច ។ នៅដើមខែមេសា ឆ្នាំ១៩៧៨ ទំនប់ម្លេចបានលើករួចរាល់ជាស្ថាពរ ។ ប្រជាជនទាំងអស់រួមទាំងរូបខ្ញុំ សប្បាយរីករាយណាស់ដែលបានវិលត្រឡប់មកជួបជុំក្រុមគ្រួសារវិញ ។ ប្តីរបស់ខ្ញុំត្រូវអង្គការចាត់តាំងឲ្យកាប់គាស់ដីធ្វើចម្ការដំឡូងនិងពោតនៅម្តុំភ្នំបាក់នឹម ។ ខ្ញុំនិងកូនទន្ទឹងរង់ចាំគាត់ត្រឡប់មកផ្ទះ ប៉ុន្តែរយៈពេលជាច្រើនខែនៅតែមិនឃើញគាត់ត្រឡប់មកវិញ ។ នៅភូមិអង្គការចាត់តាំងឲ្យខ្ញុំសែងលាមកមនុស្សនៅតាមផ្ទះយកមកជ្រលាយជាមួយអាចម៍គោ ទន្រ្ទានខែត្រ និងដីដំបូកដើម្បីធ្វើជីដាក់ស្រែ ។ នៅក្នុងស្រែមានសុទ្ធតែឈ្លើង ។ ខ្ញុំខ្លាចវាណាស់ ប៉ុន្តែខ្ញុំមិនហ៊ានប្រកែក ឬតវ៉ាជាមួយអង្គការទេ ។

នាវេលាម៉ោង៦ល្ងាច នៅខែកក្កដា ឆ្នាំ១៩៧៨ ភ្លៀងរលឹមស្រិចៗ ប្តីខ្ញុំបានបរទេះក្របីមកចតនៅមុខផ្ទះ ។ ខ្ញុំនិងកូនត្រេកអរណាស់ពេលបានជួបគាត់ ហើយខ្ញុំបានប្រាប់គាត់ថា ៣-៤ថ្ងៃមុនអង្គការបានហៅប្រុសៗ៤នាក់ឲ្យទៅទប់ទឹក ហើយក៏បាត់ខ្លួនរហូត ។ ប្តីខ្ញុំលួងលោមខ្ញុំថា កុំនិយាយព្រោក ហើយកុំបារម្ភអី ។ យប់នោះ ប្រធានសេដ្ឋកិច្ចឈ្មោះ ផាត បានមកហៅប្តីខ្ញុំទៅទប់ទឹកទាំងយប់ ។ គ្រាន់តែឮពាក្យថា «ទប់ទឹក» ខ្ញុំដាក់ទឹកមុខចុះ ហើយសម្លឹងមើលមុខគាត់ ។ ពេលនោះសម្លៀកបំពាក់គាត់នៅទទឹកជោកមិនទាន់បានផ្លាស់ចេញនៅឡើយ ។ ខ្ញុំដឹងច្បាស់ថាអ្នកដែលទៅទប់ទឹកទាំងប៉ុន្មានមិនដែលត្រឡប់មកផ្ទះវិញទេ ។ ប្តីខ្ញុំយកចបកាប់រួច ដើរទៅតាមផាត ដែលយួរចង្កៀងប្រេងកាតដាក់នៅក្នុងជ៉ោតទៅទិសខាងលិចសំដៅទៅទំនប់ត្រពាំងខ្ញុំ។ មួយសន្ទុះក្រោយ គាត់ក៏ត្រឡប់មកផ្ទះវិញ ហើយថើបកូនម្តងទៀត និងផ្តាំផ្ញើខ្ញុំថា បើបាត់គាត់យូរមិនបាច់រង់ចាំគាត់ទេ ។ គាត់ក៏ធ្វើដំណើរទៅជាមួយឈ្លបម្នាក់ ។ ប្តីខ្ញុំចេះតែងាកមើលក្រោយ ព្រោះមិនដាច់អាល័យពីកូននិងខ្ញុំ ។ យប់នោះ ខ្ញុំយល់សប្តិឃើញគាត់មករកខ្ញុំនិងកូន ប៉ុន្តែគាត់មានតែខ្លួនអត់មានក្បាល ។ ខ្ញុំសន្និដ្ឋានថា ប្តីខ្ញុំពិតជា



រូបឆ្មេង ជីតារបស់ ប៉ុនណ្ណារី ឈ្មោះ ពេជ ប៉ុន និងអ៊ីឈ្មោះ ប៉ុន វង្សវត្តី ក្នុងទសវត្សរ៍ឆ្នាំ១៩៦០

ស្លាប់ហើយ ។ ខ្ញុំក្លាយទៅជាស្ត្រីមេម៉ាយតាំងពីពេលនោះមក ។

ក្រោយមក មិត្តគី ដែលយកប្តីខ្ញុំទៅទប់ទឹកបានមកប៉ុនប៉ង ធ្វើបាបលើរាងកាយខ្ញុំ ប៉ុន្តែមិនបានសម្រេចព្រោះខ្ញុំបានកាប់វា នឹងកាំបិត ។ មិត្តគី បានយកដៃរងកាំបិត ហើយហក់ចុះពីលើ កូនខ្ទមរបស់ខ្ញុំ ។ ព្រលឹមឡើងមានឈ្លបជិត៣នាក់បានស្រែក ហៅខ្ញុំឲ្យយកកូនទៅផ្ញើទុកនៅឯយាយៗ ហើយទៅតាមគេ ប៉ុន្តែ ខ្ញុំបានអង្វរសុំយកកូនទៅជាមួយដែរ ។ រទេះសេះបាននាំខ្ញុំនិង កូនមកដល់មន្ទីរឃុំមួយក្បែរវត្តនារាយណ៍ ។ ឈ្លបបានចាប់ខ្ញុំយក ទៅដាក់មន្ទីរសន្តិសុខ ។ ខ្ញុំបានឃើញ មិត្តគី អង្គុយនៅក្បែរបុរស ម្នាក់ឈ្មោះ សាក់ ។ សាក់ បានចោទប្រកាន់ខ្ញុំថាជាគិញសម្ងាត់ និងជាប្រពន្ធរបស់សេ.អុី.អា ។ ឈ្លបបានចងដៃខ្ញុំទៅក្រោយ ហើយដឹកតាមរទេះសេះទៅមន្ទីរឃុំនៅស្រុកឈូក ។ នៅទីនោះ ឈ្លបស្រាយចំណងខ្ញុំចេញ ហើយឲ្យយុទ្ធជននិងយុទ្ធនារីប្រហែល ១០នាក់យាមខ្ញុំ ។ កម្មាភិបាលស្រុកម្នាក់វាយធ្វើបាបលើរាង កាយខ្ញុំយ៉ាងដំណំ ។

មួយអាទិត្យក្រោយមក អង្គការបានបញ្ជូនខ្ញុំទៅគុកធំនៅ ភ្នំល្អាង ។ ខ្ញុំត្រូវដាក់ខ្នោះជើងទាំងពីរ ចំណែកកូនខ្ញុំមិនបានដាក់ ខ្នោះឡើយ ។ អ្នកទោសនៅទីនោះស្គមសល់តែស្បែកដណ្តប់ឆ្អឹង ។ ខ្ញុំនៅទីនោះទាំងភ័យព្រួយ ។ រៀងរាល់យប់ អ្នកយាមគុកតែង មកយកអ្នកទោស៣ទៅ៤នាក់ចេញទៅបាត់ៗ ហើយខ្ញុំឮសម្រែក អួយៗល្ហើយៗពីចម្ងាយ ។

ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ខ្ញុំឮស្នូរកាំភ្លើងល្ហើយៗ ពីព្រំប្រទល់ខេត្តកំពត ។ នៅក្នុងគុកមាននៅសល់អ្នកទោសតែ ១៣នាក់រួមទាំងរូបខ្ញុំផង ។ រំពេចនោះ មានក្មេងម្នាក់កាន់កូនសោ មកបើកទ្វារគុក ហើយនិយាយថា អ្នកណានៅស្រុកណាត្រឡប់ ទៅស្រុកនោះវិញចុះ ។ ខ្ញុំពកូនរត់ចេញពីគុកដោយរីករាយលាយ ឡំនឹងទឹកភ្នែក ។ ខ្ញុំដើរកាត់ព្រៃកាត់វាលស្រែរហូតដល់ជួបអ្នក ភូមិ ហើយធ្វើដំណើរជាមួយគ្នា ។ ខ្ញុំពកូនដើរតាមផ្លូវទៅវត្ត នារាយណ៍ ។ ខ្ញុំបានឮសំឡេងមេក្រូរបស់កងទ័ពរំដោះអំពាវនាវឲ្យ ប្រជាជនវិលចូលទីលំនៅដើមវិញ ។ ខ្ញុំបានមកដល់ភូមិព្រៃស្បូវ ហើយសម្រាកនៅទីនោះបណ្តោះអាសន្ន ។ មានថ្ងៃមួយ ខ្ញុំបាន ទៅជញ្ជូនស្រូវពីជង្រុករួមមកទុកហូប ហើយជជែកលេងជាមួយ ពួកកងទ័ពដែលនៅទីនោះ ។ ពេលនោះស្រាប់តែមានសំឡេង មួយហៅខ្ញុំពីក្រោយខ្នង ។ ខ្ញុំងាកទៅភ្ញាក់ព្រើតព្រោះគាត់ជា គូដណ្តឹងរបស់ខ្ញុំកាលពីមុន ដែលបែកគ្នាកាលពីឆ្នាំ១៩៦៩ ។ គាត់បានសុំឲ្យខ្ញុំទៅរស់នៅជាមួយគាត់ដោយសន្យាថាគាត់នឹង ថែរក្សាខ្ញុំនិងកូនឲ្យបានល្អ ។

រហូតមកដល់សព្វថ្ងៃ ខ្ញុំនៅតែមិនអាចបំភ្លេចរឿងរ៉ាវ ដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមបាន ជាពិសេសរឿងដែល ប្តីរបស់ខ្ញុំត្រូវយកទៅសម្លាប់ ហើយខ្ញុំត្រូវជាប់នៅក្នុងគុកធំ ។ ខ្ញុំសុំឲ្យមានតុលាការមួយដើម្បីរកយុត្តិធម៌ឲ្យខ្ញុំនិងដើម្បីកុំឲ្យអ្នក ក្រោយយកគម្រាប់តាម ។ ◆◆◆

## យស់ ព្រឹម
## អតីតនាយទាហានសក្តិ៤កន្លះ

នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៥ ចាប ស៊ីថា អាយុ៦៥ ឆ្នាំ ជាប្រពន្ធរបស់ យស់ ព្រឹម បានមកមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយនាំមកនូវរូបថតប្តីរបស់គាត់មួយសន្លឹក ។ ស៊ីថា បានស្តាប់ វិទ្យុអាស៊ីសេរីក្នុងកម្មវិធីមួយដែលផ្សាយពីរឿងរ៉ាវនៅក្នុងរបប ខ្មែរក្រហម ហើយចង់ចែករំលែករឿងរ៉ាវរបស់គាត់ជាមួយ ប្រជាជនកម្ពុជាដទៃទៀត ។ ខាងក្រោមនេះជាការរៀបរាប់ របស់ ស៊ីថា ÷

នៅពេលជម្លៀសឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំមានសមាជិក ទាំងអស់១៨នាក់ ប៉ុន្តែពេលដែលរបបខ្មែរក្រហមត្រូវបានបញ្ចប់ សមាជិកគ្រួសារខ្ញុំនៅរស់តែ ៤នាក់ប៉ុណ្ណោះ ។ ១០នាក់ ទៀតបានស្លាប់នៅក្នុងរបប ខ្មែរក្រហម មានប្តីខ្ញុំកូនប្រុស ខ្ញុំ៤នាក់កូនស្រីម្នាក់ ចៅ២ នាក់កូនប្រសាម្នាក់និងម្តាយ ក្មេកខ្ញុំម្នាក់ទៀត ។ ចាប់តាំង ពីពេលនោះមក ខ្ញុំយំរហូត ដល់ងងឹតភ្នែក ។



យស់ ព្រឹម

កាលពីសង្គមរាស្ត្រនិយមផ្ទះរបស់ខ្ញុំនៅម៉ុំទួលគោក ។ ប្តីរបស់ខ្ញុំឈ្មោះ យស់ ព្រឹម ធ្វើទាហានស័ក្តិ៤កន្លះ ។ នៅឆ្នាំ

១៩៧០ ពេលដែលចៅហ្វាយខេត្តកណ្តាលត្រូវរបួសបាក់ដៃដោយសារសង្គ្រាម ប្តីរបស់ខ្ញុំបានឡើងកាន់តំណែងជំនួស ។ ឪពុកគាត់ឈ្មោះ ម៉ក់ និងម្តាយគាត់ឈ្មោះ ដៀង ។ ស្រុកកំណើតប្តីខ្ញុំនៅខេត្តស្វាយរៀង ។ គាត់បានចាកចេញពីស្រុកកំណើតមកបន្តការសិក្សានៅទីក្រុងភ្នំពេញ ដោយស្នាក់នៅវត្តខណ្ឌលោម ជាមួយលោកតា សូ ហាយ ។ ក្រោយពីប្រឡងឌីប្លូមជាប់គាត់បានប្រឡងចូលសាលាទាហាន ។ ខ្ញុំជាអ្នកទីក្រុងភ្នំពេញ ។ ប្តីរបស់ខ្ញុំបានឃើញខ្ញុំនៅឆ្នាំ១៩៥២ ហើយចាប់ចិត្តស្រឡាញ់ខ្ញុំ ។ គាត់បានឲ្យឪពុកម្តាយគាត់ចូលស្តីដណ្តឹងខ្ញុំរៀបការ ។ ពេលនោះគាត់ធ្វើទាហានពាក់ដោយមួយជាន់ ។ ប្តីខ្ញុំឡើងបុណ្យស័ក្តិជាបន្តបន្ទាប់ ។ គាត់បានទៅហ្វឹកហាត់ទាហាននៅខេត្តកំពង់ឆ្នាំង តាកែវ និងស្រែក្នុង ។ ខ្ញុំធ្វើដំណើរទៅតាមគាត់គ្រប់ទីកន្លែង ។ នៅពេលដែលខ្ញុំមានកូន៨នាក់ ថ្នាក់លើបានចាត់តាំងគាត់ឲ្យទៅប្រចាំការនៅខេត្តរតនគិរី ជាអ្នកមើលខុសត្រូវជនជាតិភាគតិច ។ ពេលនោះខ្ញុំមិនបានទៅរស់នៅជាមួយប្តីខ្ញុំទេ ដោយខ្ញុំគិតថា ប្តីខ្ញុំទៅទីនោះពិតជាជួបគ្រោះថ្នាក់ ខ្ញុំបានស្នើសុំទៅប្រធានរបស់គាត់ឲ្យគាត់មកប្រចាំការនៅទីក្រុងភ្នំពេញវិញ ពីព្រោះខ្ញុំគិតថាប្រសិនបើគាត់មានគ្រោះថ្នាក់ទៅខ្ញុំនិងកូន៨នាក់ទៀតពិតជាពិបាកហើយ ។

នៅមុនឆ្នាំ១៩៧៥ ពេលដែលស្រុកទេសមានការជ្រួលច្របល់ខ្លាំង ខ្ញុំបានបបួលប្តីខ្ញុំទៅរស់នៅប្រទេសថៃមួយរយៈសិន ប៉ុន្តែគាត់មិនព្រម ។ គាត់និយាយថា គាត់ជាកូនកសិករជាអ្នកស្នេហាជាតិ គាត់មិនអាចក្បត់ជាតិបានទេ ។ គាត់ប្រាប់ខ្ញុំថា បើខ្ញុំចង់ទៅខ្ញុំអាចទៅបាន ប៉ុន្តែខ្ញុំមិនអាចទៅចោលប្តីខ្ញុំបានទេ ។ ខ្ញុំក៏សម្រេចចិត្តរស់នៅទីនេះជាមួយកូននិងគាត់ ។

នៅពេលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំត្រូវជម្លៀសទៅរស់នៅភូមិកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល ។ ដំបូងឡើយ ខ្ញុំមានបំណងទៅរស់នៅខេត្តស្វាយរៀង ព្រោះជាស្រុកកំណើតខាងប្តីរបស់ខ្ញុំ ប៉ុន្តែដោយសារតែមានការកកស្ទះផ្លូវខ្លាំងពេក ហើយខ្ញុំមានម្តាយក្មេកម្នាក់ដែលមានវ័យចាស់ជរា នៅក្នុងបន្ទុកដែលពិបាកក្នុងការធ្វើដំណើរផ្លូវឆ្ងាយ ខ្ញុំក៏សម្រេចចិត្តទៅតាមទិសដៅដែលអង្គការបានកំណត់ឲ្យ គឺទៅស្រុកកោះធំ ។ នៅទីនោះអង្គការបានសួរអំពីប្រវត្តិរូបក្រុមគ្រួសាររបស់ខ្ញុំ ។ ខ្ញុំបាននិយាយកុហកថា ប្តីរបស់ខ្ញុំជាអ្នករកស៊ី ។ អង្គការបានចាត់តាំងឲ្យខ្ញុំដាំបន្លែបង្ការសម្រាប់ផ្ទះបាយនិងធ្វើស្រែ ។ ក្នុងមួយព្រឹកខ្ញុំត្រូវរែកទឹកស្រោចដំណាំឲ្យបាន៤០អម្រែក ចំណែកប្តីរបស់ខ្ញុំធ្វើស្រែ ស្ទូងស្រូវ ជីកប្រឡាយ និងរែកដី ។ កូនៗរបស់ខ្ញុំរស់នៅក្នុងកងចល័ត ។

ថ្ងៃមួយវេលាម៉ោង៩យប់ ប្តីរបស់ខ្ញុំត្រូវអង្គការស្នើឲ្យទៅរៀនសូត្រមួយរយៈដោយប្រាប់ថា ពេលណារៀនចប់នឹងបានវិលត្រឡប់មកផ្ទះវិញ ។ ឈ្លបដែលមកហៅឈ្មោះ ឃ្លោក ។ ឃ្លោក បានប្រាប់ខ្ញុំថា «កុំបារម្ភអីអង្គការស្នើឲ្យទៅជួបអង្គការនៅផ្ទះយាយភី តែមួយភ្លែតទេ» ។ យាយភី ជាប្រជាជនដែលរស់នៅក្នុងភូមិជាមួយខ្ញុំដែរ ។ ខ្ញុំរង់ចាំប្តីរបស់ខ្ញុំ ប៉ុន្តែមិនឃើញគាត់ត្រឡប់មកវិញសោះ ។ ខ្ញុំប្រាប់កូនៗខ្ញុំថា ឪពុករបស់វាប្រហែលជាត្រូវអង្គការសម្លាប់បាត់ហើយ កុំឲ្យពួកវាភ័យឆោឡោឲ្យសោះ ។ ខ្ញុំបានប្រើឲ្យកូនខ្ញុំទៅស៊ើបសួរនៅផ្ទះ យាយភី ។ យាយភី បានប្រាប់កូនខ្ញុំថា «មិនចាំបាច់មើលផ្លូវឪពុកឯងទេ ហើយប្រយ័ត្នប្រយែងមាត់ផង កុំនិយាយអ្វីផ្តេសផ្តាសឲ្យសោះ ប្រយ័ត្នគេយកទៅមួយពូជ ព្រោះឪពុកឯងមានប្រវត្តិធំណាស់» ។ ខ្ញុំយល់ថា អង្គការយកប្តីខ្ញុំទៅដោយសារគាត់ជាអតីតចៅហ្វាយខេត្តកណ្តាល ។

ពីរខែក្រោយមក អង្គការបានប្រាប់ខ្ញុំឲ្យផ្លាស់ទៅរស់នៅទីក្រុងភ្នំពេញ ។ ក្រុមគ្រួសារខ្ញុំបានធ្វើដំណើរទាំងយប់អធ្រាត្រជិះទូកឆ្លងពីវត្តកំពង់កុងទៅដល់វត្តកំពង់រពៅ ។ បន្ទាប់មក មានឡានមកដឹកយកទៅដាក់នៅមុំទួលលាបនៅខាងលិចតាខ្មៅហើយឡើងជិះរថភ្លើងធ្វើដំណើរបន្តទៅខេត្តបាត់ដំបង មិនមែនទៅភ្នំពេញទេ ។ ទៅដល់ទីនោះ ប្រជាជនមូលដ្ឋានយករទេះគោមកដឹកមនុស្សចាស់ជរានិងអ្នកដែលទើបតែឆ្លងទន្លេហើយទៅកាន់ភូមិ ចំណែកពួកខ្ញុំដើរ ។ ៤-៥ថ្ងៃក្រោយមក អង្គការបានចែកកូនខ្ទមមួយឲ្យក្រុមគ្រួសារខ្ញុំរស់នៅ ។ ខ្ទមនោះមានសភាពចាស់ទ្រុឌទ្រោម ។ បន្ទាប់មក អង្គការយកកុមារទាំងអស់ទៅដាក់នៅកងចល័ត ស្ត្រីដាក់ឲ្យនៅក្នុងកងស្ត្រី បុរសដាក់នៅក្នុងកងបុរស ។ កូនស្រីពៅរបស់ខ្ញុំដែលមានអាយុ៦ឆ្នាំរស់នៅជាមួយខ្ញុំ ។

ពេលខ្លះ ខ្ញុំលួចដាំបាយយកទៅឲ្យកូនរបស់ខ្ញុំហូបនៅឯ

កង ។ ក្រោយមកអង្គការក៏ចាត់តាំងឲ្យកូនរបស់ខ្ញុំទៅជីកប្រឡាយ និងអាងទឹកនៅការដ្ឋានឆ្ងាយពីផ្ទះរបស់ខ្ញុំប្រមាណ៤០គីឡូម៉ែត្រ ។ កូនខ្ញុំម្នាក់កើតឆ្នាំរកា អាយុ១៧ឆ្នាំ ស្លាប់ដោយសារជំងឺនិងខ្វះខាតអាហារ ។ ពេលកូនខ្ញុំឈឺអង្គការបានយកវាទៅទុកចោលនៅពេទ្យ ហើយហៅខ្ញុំឲ្យទៅមើលកូន ។ ខ្ញុំទៅដល់ទីនោះបានតែមួយយប់កូនខ្ញុំក៏ស្លាប់ ។ មុននឹងកូនខ្ញុំស្លាប់ វាថ្វូរប្រាប់ខ្ញុំថា «ម៉ែអើយ! ខ្ញុំឃ្លានណាស់ ខ្ញុំវេទនាជាងសត្វទៅទៀត សុំឲ្យខ្ញុំស្លាប់ទៅនឹងបានកើតជាថ្មីទៀត ឲ្យខ្ញុំរស់នៅធ្វើអ្វី?» ។ កូនប្រុសរបស់ខ្ញុំ៤នាក់ និងកូនស្រីបងម្នាក់បានស្លាប់ជាបន្តបន្ទាប់រំលងគ្នាតែរយៈពេល ៤-១០ថ្ងៃប៉ុណ្ណោះ ។ ខ្លះស្លាប់ដោយសារជំងឺ ខ្លះទៀតស្លាប់ដោយសារអង្គការចោទប្រកាន់ថាមានជាប់ពាក់ព័ន្ធជាមួយខ្មាំង ។ កូនស្រីច្បងរបស់ខ្ញុំត្រូវអង្គការយកទៅសម្លាប់ចោលទាំងប្តី-ប្រពន្ធនិងកូន២នាក់ ដោយសារកូនប្រសាររបស់ខ្ញុំជាកូនអតីតចៅហ្វាយក្រុង ។

ពេលដែលកូនចៅខ្ញុំស្លាប់ ប្រធានភូមិឈ្មោះ សុំ បានប្រាប់ខ្ញុំថា ត្រូវជម្រុះកម្មសិទ្ធិឲ្យអស់កុំឲ្យមាននៅសល់ ។ ប្រធានភូមិរូបនោះបាននិយាយថា សាច់ឈាមរបស់ខ្ញុំមិនមែនជាអ្នកតូចតាចទេ យ៉ាងហោចណាស់ក៏ជាលោកស្រីឬលោកជំទាវ ហើយបើជាអ្នករកស៊ីក៏ជាប្រពន្ធរបស់ថៅកែដែរ ។ សុំ បានប្រើខ្ញុំឲ្យទៅប្រមូលលាមកចេញពីបង្គន់ជារៀងរាល់ថ្ងៃ ។ ខ្ញុំមិនហ៊ានប្រកែកតវ៉ាទេ ។ បើខ្ញុំហ៊ានតវ៉ាខ្ញុំពិតជាស្លាប់ហើយ ។ ខ្ញុំយកលាមកនោះទៅហាលថ្ងៃ ហើយយកទៅចាក់លាយជាមួយផេះ ។ ពេលខ្លះខ្ញុំខ្ទើមរអើមខ្លាំងពេក ខ្ញុំដួលសន្លប់នៅកន្លែងធ្វើការ ។ ពេលដឹងខ្លួនមកវិញ ខ្ញុំដេកនៅក្នុងមន្ទីរពេទ្យ ។ មានប្រជាជនថ្មីម្នាក់ដែលទៅជាមួយខ្ញុំ ហើយតែងតែជួយយកអាសា ខ្ញុំបានប្រាប់ខ្ញុំថា អង្គការធ្វើបែបនេះគឺដើម្បីចង់ឲ្យខ្ញុំស្លាប់ ។ បើខ្ញុំហ៊ានប្រកែកខ្ញុំនឹងត្រូវសម្លាប់ទាំងយប់ ។ ក្រោយមកមិត្តម្នាក់នោះត្រូវអង្គការយកទៅសម្លាប់ដោយមិនដឹងពីមូលហេតុច្បាស់លាស់ ។

ម្តាយក្មេករបស់ខ្ញុំអាយុ៧០ឆ្នាំ បានស្លាប់ដោយជំងឺនិងខ្វះអាហារបរិភោគ ។ ខ្ញុំតែងតែលួចបាយម្ហូបខ្លះលាក់ទុកឲ្យគាត់ជានិច្ច ។ ខ្ញុំស្រឡាញ់គាត់ដូចជាម្តាយរបស់ខ្ញុំបង្កើតដែរ ។ គាត់រស់នៅជាមួយខ្ញុំរហូត ។ គាត់មានតែកូនប្រុស២នាក់ ។ ពេលដែលជម្លៀសចេញពីទីក្រុងភ្នំពេញ គាត់ធ្វើដំណើរទៅជាមួយខ្ញុំ ។ ជារឿយៗតែងតែមានឡានដឹកមនុស្សចេញពីភូមិ ហើយត្រឡប់មកវិញតែឡានទទេ ។ ប្រជាជននៅក្នុងភូមិរបស់ខ្ញុំត្រូវអង្គការហៅទៅស៊ើរពាយពីភូមិ ។ នៅពេលយប់ឈ្លបដើរហៅអ្នកណាដែលមានឈ្មោះនៅក្នុងបញ្ជី ។ ជារៀងរាល់យប់ ខ្ញុំមិនដែលដេកបានស្រួលទេ មិនដឹងថា ដល់វេនគេឬវេនខ្ញុំ ។ ខ្ញុំបន់ឲ្យតែមេឃឆាប់ភ្លឺ ។ ខ្ញុំប្តូរទីកន្លែងរស់នៅពីសហករណ៍មួយទៅសហករណ៍មួយជាញឹកញាប់ ។ ជាពិសេស នៅពេលដែលផលដំណាំជិតទទួលបានផល ។ ពេលខ្លះខ្ញុំត្រូវធ្វើដំណើរទាំងយប់ ហើយមានធ្លាក់ភ្លៀងថែមទៀត ។

ការរស់នៅក្នុងតំបន់៤លំបាកណាស់ ។ ក្រុមគ្រួសារខ្លះត្រូវស្លាប់ទាំងពូជ ។ ក្រុមគ្រួសារខ្លះទៀតស្លាប់ប្តីឬប្រពន្ធ ។ ក្រុមគ្រួសារខ្ញុំសំណាងណាស់ដែលសល់សមាជិកខ្លះ ។ ពេលកងទ័ពវៀតណាមវាយរំដោះនៅឆ្នាំ១៩៧៩ ខ្ញុំបានធ្វើដំណើរដោយថ្មើរជើងត្រឡប់ចូលទីក្រុងភ្នំពេញវិញជាមួយកូនៗដែលនៅរស់ ។ ខ្ញុំបានមកដល់គីឡូម៉ែត្រលេខ៧នៅខែមេសា ឆ្នាំ១៩៧៩ ។ នៅទីនោះ ខ្ញុំបានស្នាក់នៅជាមួយក្មួយរបស់ខ្ញុំម្នាក់ ហើយប្រកបរបរលក់ដូរបន្តិចបន្តួច ។ ៣ខែក្រោយមក ខ្ញុំបានមករស់នៅម៉ុស្ស៊ីងមានជ័យជាមួយក្មួយរបស់ខ្ញុំម្នាក់ទៀត ។ ខ្ញុំផ្ញើកូនខ្ញុំទាំងបីនាក់ឲ្យក្មួយខ្ញុំជួយមើល ហើយខ្ញុំចេញទៅរត់ពន្ធអីវ៉ាន់តាមរថភ្លើងដើម្បីបានប្រាក់ខ្លះមកកូនឲ្យកូនរៀន ។ ដោយសារការធ្វើដំណើរតាមរថភ្លើងជួបគ្រោះថ្នាក់ច្រើន ខ្ញុំឈប់ប្រកបរបរនេះ ហើយមកបើកហាងលក់គុយទាវនិងបបរវិញ ។ ខ្ញុំប្រឹងប្រែងធ្វើការងារទាំងថ្ងៃទាំងយប់គ្មានពេលសម្រាកទេ ។ ខ្ញុំមិនដែលឲ្យកូនៗខ្ញុំធ្វើការងារលំបាកឡើយ ។ ខ្ញុំចង់ឲ្យកូនរបស់ខ្ញុំមានចំណេះវិជ្ជាខ្ពស់ ។ គ្មានអ្វីដែលធំជាងចំណេះវិជ្ជាទេ ។ ពេលដែលប្តីខ្ញុំនៅរស់ ខ្ញុំរស់នៅដោយពឹងផ្អែកលើគាត់ទាំងស្រុង ។ ប៉ុន្តែពេលគាត់ស្លាប់ទៅខ្ញុំត្រូវប្រឹងប្រែងដោយខ្លួនឯង ដើម្បីតែកូនៗរបស់ខ្ញុំ ។

ចាប់តាំងពីបាត់បង់ប្តី កូន និងម្តាយក្មេកមក ខ្ញុំយំស្ទើររៀងរាល់យប់រហូតដល់ភ្នែកខ្ញុំងងឹតមើលឃើញព្រិលៗ ។ ក្រោយពេលបែករបបខ្មែរក្រហម ខ្ញុំបានទៅមន្ទីរពេទ្យព្យាបាលភ្នែករបស់ខ្ញុំ ហើយក៏បានជាសះស្បើយឡើងវិញ ។

សព្វថ្ងៃខ្ញុំនៅសល់តែរូបថតរបស់ប្តីខ្ញុំមួយសន្លឹកគត់ ។ រូបថតនេះគាត់ថតនៅឆ្នាំ១៩៧២ នៅទីក្រុងភ្នំពេញ ។ ពេលនោះគាត់មានតួនាទីជាទាហានប្រចាំការនៅបន្ទាយស្រែខ្ទុំ នៅខេត្តកំពង់ស្ពឺ ។ ពេលនោះខ្ញុំមានកូន៦នាក់ហើយ ។ ពេលគាត់ថតរូបហើយខ្ញុំបានឃើញរូបថតនោះម្តងដែរ ក្រោយមកខ្ញុំលែងបានឃើញរូបថតនោះទៀត ។ ពេលជម្លៀសឆ្នាំ១៩៧៥ ខ្ញុំមិនបានរក្សាទុករូបថតប្តីខ្ញុំទេ ។ ខ្ញុំគិតថា គ្រួសារខ្ញុំជាអ្នកមានបណ្តាសក្តិធំ ដូច្នេះប្រសិនបើជាមានអ្នកណាឆែកឆេរឃើញគ្រួសារ ខ្ញុំមុខជាត្រូវស្លាប់ទាំងអស់គ្នា ។ ខ្ញុំបានដុតរូបថតចោលខ្លះ ហើយនៅសល់ប៉ុន្មានខ្ញុំកប់ចោលក្នុងភក់ ។ រូបថតនេះខ្ញុំទើបតែឃើញម្តងទៀតនៅក្រោយឆ្នាំ១៩៧៩ ។ មានអ្នកគ្រូម្នាក់ឈ្មោះ សុម៉ាលី ជាអតីតគ្រូបង្រៀននៅសាលាយុគន្ធរ ជាអ្នកដែលធ្លាប់ស្គាល់ខ្ញុំជិតដិត បានទៅឃើញរូបថតមួយសន្លឹកនេះនៅផ្ទះមួយដែលខ្ញុំមិនបានស្គាល់ឈ្មោះ គាត់ក៏សុំពីម្ចាស់ផ្ទះយកមកឲ្យខ្ញុំ ។ ពេលនោះខ្ញុំមិនបានដេញដោលគាត់អំពីអ្នកទុករូបថតនេះទេ ពីព្រោះខ្ញុំមានការមមាញឹកក្នុងការប្រកបរបរចិញ្ចឹមជីវិត ។ ខ្ញុំក៏រក្សាទុករូបថតនេះរហូតមក ហើយយកវាទៅផ្តិតសាជាថ្មីឡើងវិញដើម្បីទុកជាអនុស្សាវរីយ៍ ។

ពេលអង្គការស្នើប្តីខ្ញុំទៅ ខ្ញុំមិនដឹងថាប្តីខ្ញុំត្រូវបញ្ជូនទៅទីណាទេ ។ ក្រោយឆ្នាំ១៩៧៩ ក្មួយរបស់ខ្ញុំបានទៅមើលនៅទួលស្លែង ហើយបានឃើញឈ្មោះប្តីខ្ញុំនៅក្នុងបញ្ជីឈ្មោះអ្នកទោសនៅទីនោះ ។ ខ្ញុំបានដឹងពីអ្នកនៅរស់រានមានជីវិតម្នាក់ដែលកំពុងរស់នៅក្បែរនោះថា អ្នកទោសដែលជាប់គុកនៅទួលស្លែងត្រូវបានបញ្ជូនយកទៅសម្លាប់នៅបឹងជើងឯក ។

នៅពេលមានពិធីបុណ្យទានម្តងៗ ខ្ញុំតែងតែយកចង្ហាន់ទៅបឹងជើងឯកជានិច្ច ដើម្បីសែនព្រេននិងឧទ្ទិសកុសលឲ្យដល់ប្តីរបស់ខ្ញុំ ។ ខ្ញុំយល់សប្តិឃើញប្តីខ្ញុំញឹកញាប់ណាស់ ។ ◆◆◆

## ឈួន សុភ័ក្ត្រ
## អតីតប៉េអឹម

ឈួន សុភ័ក្ត្រ បានរក្សាទុករូបថតមួយសន្លឹកដែលគាត់បានថតនៅមុនឆ្នាំ១៩៧៥ ។ សុភ័ក្ត្រ មានរូបថតជាច្រើនសន្លឹកទាំងក្នុងឯកសណ្ឋានទាហាននិងស៊ីវិល ប៉ុន្តែពេលគាត់ធ្វើដំណើរទៅខេត្តបាត់ដំបងមុនឆ្នាំ១៩៧៥ គាត់បានកប់ចោលនៅទីនោះអស់ជាច្រើនសន្លឹក ពីព្រោះគាត់គិតថារូបថតទាំងនោះអាចនាំគ្រោះថ្នាក់ដល់អាយុជីវិតគាត់ ។ នៅក្នុងរបបខ្មែរក្រហមមានឈ្លបមកឆែកឆេរនៅផ្ទះរបស់គាត់ ហើយបានយកនាឡិកាដៃនិងម៉ាញ៉ៅទៅ ប៉ុន្តែមិនបានយករូបថតនោះទេ ។ ខាងក្រោមនេះគឺជារឿងរ៉ាវរបស់ ឈួន សុភ័ក្ត្រ៖


ឈួន សុភ័ក្ត្រ

នៅក្នុងរបបខ្មែរក្រហមខ្ញុំបានប្តូរឈ្មោះពី ស៊ឹម ឈូក ទៅជា សុខ ឆន វិញ ពីព្រោះខ្ញុំជាអតីតទាហាននៅក្នុងរបបសង្គមរាស្ត្រនិយមនិងជាអតីតប៉េអឹម នៅក្នុងរបបលន់នល់ ។ ខ្ញុំដឹងថា បើខ្ញុំមិនប្តូរឈ្មោះទេ ខ្ញុំពិតជាស្លាប់ ។

ខ្ញុំមានស្រុកកំណើតនៅស្រុកបាភ្នំ ខេត្តព្រៃវែង ។ ខ្ញុំជាក្មេងកំព្រាម្តាយ ។ ឪពុកខ្ញុំគ្មានលុយគ្រប់គ្រាន់សម្រាប់ចំណាយការរៀនសូត្ររបស់ខ្ញុំទេ ។ ដូច្នេះខ្ញុំបានទៅរស់នៅទីក្រុងភ្នំពេញជាមួយបងថ្លៃឈ្មោះ ចាន់ គឹមហ៊ា មានឋានៈជាពលបាលត្រីនៅបន្ទាយសេះ ។ បងថ្លៃខ្ញុំបានឲ្យខ្ញុំប្រឡងចូលធ្វើទាហាន ។ ខ្ញុំបានទៅហាត់ហ្វឹកហ្វឺននៅខេត្តពោធិសាត់ចំនួន៧ខែ ។ ក្រោយមក ខ្ញុំបានមករៀនបច្ចេកទេសបាញ់យន្តហោះនៅត្រាំខ្នារនិងកំពង់សិលា ។ មិត្តភក្តិរបស់ខ្ញុំខ្លះជ្រើសរើសយកផ្នែកខាងកីឡា ។ ចំណែកខ្ញុំជ្រើសរើសយកផ្នែកកាំភ្លើងធំការពារដែនអាកាស ។ ពេលរៀនចប់ ខ្ញុំនិងក្រុមរបស់ខ្ញុំ៧នាក់បានទទួលបញ្ជាពីថ្នាក់លើធ្វើជាកងការពារព្រះកុរណាសម្តេច នរោត្តម សីហនុ នៅពេលណាសម្តេចយាងទៅតាមខេត្តផ្សេងៗ ។ មួយក្រុមមានកាំភ្លើងធំទំហំ៣៧មីល្លីម៉ែត្រមួយដើម ។

នៅឆ្នាំ១៩៦៧ ខ្ញុំចាប់បានខ្មែរក្រហមម្នាក់ឈ្មោះ ឡឹក ស៊ាន នៅស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ សម្តេចព្រះ នរោត្តម សីហនុ បានប្រទានមេដាយកិត្តិយសមួយឲ្យដល់ខ្ញុំ ហើយខ្ញុំបានឡើងតំណែង និងផ្ទេរមកធ្វើការនៅកងអនុសេនាធំទី៣ខាងកងយន្តហោះប្រដេញ ។ ខ្ញុំបានចេញច្បាំងនៅសមរភូមិជាច្រើន

ដូចជានៅសមរភូមិស្អាង សិត្បូ ទន្លេបិទ តាំងគោក និងគគីរធំ ។ កងកម្លាំងរបស់ខ្ញុំត្រូវខ្មែរក្រហមព័ទ្ធជាប់ចំនួន២លើក នៅកន្លែងដដែលនៅម្តុំតាំងគោក ។ លើកទី១ខ្ញុំជាប់នៅទីនោះចំនួន៧យប់ ៧ថ្ងៃ និងលើកទី២ខ្ញុំជាប់៩យប់៩ថ្ងៃ ។

នៅឆ្នាំ១៩៧២ ខ្ញុំបានរៀបការជាមួយប្រពន្ធខ្ញុំឈ្មោះ អ៊ិន សៃមួន ។ ប្រពន្ធខ្ញុំមានស្រុកកំណើតនៅខេត្តកំពង់ចាម ។ ខ្ញុំបានជួបនាងនៅចម្ការអណ្តូង ក្នុងពេលដែលខ្ញុំលើកទ័ពវរសេនាតូចលេខ៥០ ទៅច្បាំងនៅចេនឡាទី១ និងទី២ ។ ក្រោយពេលរៀបការ ខ្ញុំបាននាំប្រពន្ធមករស់នៅទីក្រុងភ្នំពេញ និងទិញផ្ទះមួយខ្នងនៅម្តុំគល់ស្ពានច្បារអំពៅ ។ ប្រពន្ធខ្ញុំប្រកបរបរដេរសម្លៀកបំពាក់ ។ ខ្ញុំគិតថាប្រសិនបើខ្ញុំនៅតែធ្វើទាហាន ខ្ញុំត្រូវតែទៅសមរភូមិចៀសមិនរួច ។ ខ្ញុំក៏សម្រេចចិត្តសុំបងរបស់ខ្ញុំផ្លាស់មកធ្វើការជាមួយគាត់នៅកងរាជអាវុធហត្ថជាតិទីក្រុងភ្នំពេញ ។ នៅទីនោះខ្ញុំធ្វើការជាមួយលោក ហែម សាវ៉េត ។ ពេលនោះដែរ ក៏មានការអំពាវនាវពីសំណាក់សម្តេច នរោត្តម សីហនុ ឲ្យប្រជាជនចូលព្រៃម៉ាគី ដើម្បីវាយប្រយុទ្ធជាមួយ លន់ នល់, សិរិមតៈ និង ចេង ហេង ។ ទាំងប្រជាជននៅតាមទីជនបទនិងនៅក្នុងទីក្រុងភ្នំពេញក៏បានចូលរួមធ្វើបាតុកម្មប្រឆាំងនឹងរបប លន់ នល់ ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៥ ដោយសារប្រទេសជាតិកាន់តែជ្រួលច្របល់ ខ្ញុំបានសម្រេចចិត្តបែកចេញពីប្រពន្ធនិងកូនខ្ញុំមួយរយៈសិន ។ ប្រពន្ធរបស់ខ្ញុំមិនអាចទៅចោលឪពុកម្តាយនៅឯស្រុកកំណើតបានទេ ។ ឪពុកម្តាយក្មេកខ្ញុំនៅខាងតំបន់យៀកកុងកាន់កាប់ ចំណែកខ្ញុំនិងប្រពន្ធនៅខាងលន់ណុល ។ ម្យ៉ាងទៀត ខ្ញុំគ្មានលុយគ្រប់គ្រាន់សម្រាប់ឲ្យប្រពន្ធនិងកូនខ្ញុំទិញសំបុត្រយន្តហោះទេគឺមានសម្រាប់តែខ្លួនខ្ញុំម្នាក់ប៉ុណ្ណោះ ។ ខ្ញុំមានបំណងឆ្លងទៅប្រទេសអាមេរិកតាមរយៈប្រទេសថៃ ។ ខ្ញុំធ្វើដំណើរតាមយន្តហោះចេញពីភ្នំពេញឆ្ពោះទៅស្រុកអូរជ្រៅ ដើម្បីស្វែងរកខ្សែរយៈទាក់ទងនៅប្រទេសថៃនិងឆ្លងទៅប្រទេសអាមេរិក ។ មុនពេលចេញដំណើរ ខ្ញុំផ្តាំប្រពន្ធខ្ញុំថា បើស្រុកបានសន្តិភាពខ្ញុំនឹងវិលត្រឡប់មករកគាត់និងកូនៗវិញ ។ យន្តហោះបានឈប់នៅខេត្តបាត់ដំបង រួចទើបបន្តទៅស្រុកអូរជ្រៅ ពីព្រោះខ្ញុំមានសាច់ញាតិនៅទីនោះ ។ ប្រជាជននៅទីនោះអាចឆ្លងទៅមកប្រទេសថៃបាន ប៉ុន្តែពេលនោះខ្ញុំបែរជាសម្រេចចិត្តរស់នៅប្រទេសខ្មែរវិញ ។

ថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានរៀបចំទ័ពនៅតាមព្រំដែន ។ កងទ័ពខ្មែរក្រហមជិះឆេះដេញខ្ញុំនិងប្រជាជនដទៃទៀតឲ្យចេញពីភូមិគោកនិមិត្តមកភូមិគោកតូច ។ នៅទីនោះមានទីស្នាក់ការខ្មែរក្រហមមួយ ហើយខ្មែរក្រហមប្រកាសឲ្យប្រជាជនទាំងអស់ចុះឈ្មោះចូលធ្វើការវិញ ។ បើអ្នកណាធ្លាប់ធ្វើការអ្វីត្រូវដាក់ថាធ្វើការងារនោះ អង្គការនឹងបញ្ជូនទៅធ្វើការតាមកន្លែងដើមវិញ ។ ប្រជាជនបាននាំគ្នាចុះឈ្មោះជាបន្តបន្ទាប់ ។ អ្នកខ្លះចុះឈ្មោះថាធ្វើគយនិងធ្វើប៉េអឹម ចំណែកខ្ញុំបានប្តូរឈ្មោះទៅជា សុខ ឆន ធ្វើជាកម្មករ ។ មួយថ្ងៃបន្ទាប់ អ្នកទាំងនោះត្រូវខ្មែរក្រហមដឹកតាមឡានយកទៅទីកន្លែងផ្សេង ហើយមិនឃើញត្រឡប់មកវិញសោះ ។ ប្រជាជនបាននាំគ្នាសន្និដ្ឋានថា អ្នកទាំងនោះត្រូវខ្មែរក្រហមយកទៅសម្លាប់អស់ហើយ ។ ខ្ញុំត្រូវអង្គការចាត់តាំងឲ្យធ្វើស្រែនៅក្បែរព្រំប្រទល់ថៃ ។ ខ្ញុំមានបំណងសុំច្បាប់ប្រធានភូមិដើម្បីមករកប្រពន្ធនិងកូនខ្ញុំដែរ ប៉ុន្តែច្បាប់តឹងតែងពេកទើបខ្ញុំមិនហ៊ានសុំ ម្យ៉ាងទៀតខ្ញុំគិតថា ប្រសិនបើខ្ញុំត្រឡប់ទៅស្រុកកំណើតវិញខ្ញុំពិតជាត្រូវស្លាប់ ពីព្រោះខ្ញុំជាទាហាន ។

នៅភូមិគោកតាសត ខ្មែរក្រហមបានចាត់តាំងឲ្យខ្ញុំធ្វើជាគោភ្ជួរស្រែក្នុងមួយក្រុមមានគ្នា៩នាក់ ៨នាក់ជាអ្នកអូសនង្គ័ល និងម្នាក់ជាអ្នកកាន់ដងនង្គ័ល ។ ខ្ញុំរស់នៅលាយឡំជាមួយប្រជាជនមូលដ្ឋាន ។ ប្រជាជនមូលដ្ឋានមានសិទ្ធិជាងប្រជាជនថ្មីទាំងការហូបចុកនិងការនិយាយស្តី ។ ដំបូងឡើយខ្ញុំមានអាហារហូបគ្រប់គ្រាន់ ក្រោយមកដោយសារសហករណ៍ខ្វះខាតស្រូវ អង្គការចាត់តាំងឲ្យក្រុមខ្ញុំដែលមានសមាជិកចំនួន៥០នាក់អូសគ្រាក់ទ័រទៅដឹកស្រូវនៅភូមិគោកនិមិត្ត ដែលមានចម្ងាយប្រមាណ២០គីឡូម៉ែត្រ ពីភូមិគោកតាសត ។ ក្នុងគ្រាក់ទ័រមួយអាចផ្ទុកស្រូវបានចំនួន១៣០បាវ ។

នៅទីនោះសម្បូរស្រូវណាស់ ។ ប៉ុន្តែពេលខ្ញុំធ្វើស្រូវបាន អង្គការតែងតែផ្លាស់ប្តូរខ្ញុំឲ្យទៅរស់នៅនិងធ្វើការនៅភូមិផ្សេងជានិច្ច ។ ខ្ញុំផ្លាស់ពីភូមិអូរតាសតទៅភូមិជ្រោយម្ទេសភូមិបរវេល និងបន្ទាប់មកទៅនៅភូមិសង្កែវារ ។ ខ្ញុំធ្វើជាកម្មករនៅរោងម៉ាស៊ីន

កិនស្រូវ ។ ការងារនៅទីនោះពិបាកជាងការងារនៅក្នុងសហករណ៍ ដោយខ្ញុំត្រូវលីបាវស្រូវនិងបាវអង្ករពីរទេះដាក់ចូលក្នុងរោងម៉ាស៊ីននិងពីរោងម៉ាស៊ីនមកដាក់រទេះវិញ ។ ក្រុមការងាររបស់ខ្ញុំប្រជុំស្ទើររាល់សប្តាហ៍ ។ មិត្តបុង ដែលជាអ្នកធ្វើការនៅក្នុងរោងម៉ាស៊ីនស្រូវជាមួយខ្ញុំត្រូវអង្គការយកទៅសម្លាប់ចោលដោយចោទថាជាជនជាតិវៀតណាម ។ ពីរថ្ងៃក្រោយមក អង្គការបានចាប់ប្រពន្ធនិងកូនគាត់យកទៅសម្លាប់ទាំងអស់ ។ តាមពិតគាត់មិនមែនជាជនជាតិវៀតណាមទេ គាត់គ្រាន់តែចេះនិយាយភាសាវៀតណាមប៉ុណ្ណោះ ។

មានពេលមួយ កម្មាភិបាលម្នាក់ដែលធ្វើការនៅសហករណ៍បានយកទាកាប៉ាមួយគូមកផ្ញើទុកនៅខ្ញុំឲ្យជួយចិញ្ចឹម ដោយសន្យាថាពេលណាទាមានកូនយើងនឹងចែកគ្នា ។ នៅពេលទានោះធំ រោងម៉ាស៊ីនកិនស្រូវត្រូវប្តូរកម្មាភិបាលថ្មី ។ កម្មាភិបាលនោះបានសុំយកទាទៅវិញ ប៉ុន្តែខ្ញុំគ្មានសិទ្ធិឲ្យទៅវិញទេ ពីព្រោះសិទ្ធិទាំងអស់ត្រូវស្ថិតនៅលើអ្នកគ្រប់គ្រងថ្មី ។ កម្មាភិបាលរូបនោះបានចោទថា ខ្ញុំជាអ្នកលួចទារបស់គាត់ ។ ប្រហែលជាម៉ោងពីររសៀលថ្ងៃនោះ ឈ្លបបានមកចាប់ខ្ញុំចង ហើយបណ្តើរទៅមន្ទីរពាណិជ្ជកម្មសង្កែវ៉ារ ។ នៅទីនោះ កម្មាភិបាលស្រី-ប្រុសបានត្អូះតិះដៀលខ្ញុំថាជាពួកចក្រពត្តិប្រតិកិរិយា ។ ខ្ញុំមិនអាចប្រកែកតវ៉ាបានឡើយ ។ ខ្ញុំបានត្រឹមតែលួចសូត្រធម៌ប៉ុណ្ណោះ ។ ឈ្លបបានវាយធ្វើបាបខ្ញុំរហូតដល់សន្លប់មួយថ្ងៃមួយយប់ ។ ខ្ញុំមានរបួសពាសពេញខ្លួននិងបែកឈាមសើមដោក ។ អង្គការក៏បញ្ជូនខ្ញុំមកអង្គភាពដើមវិញ ។ អ្នកធ្វើការនៅក្នុងអង្គភាពរបស់ខ្ញុំគ្មានអ្នកណាម្នាក់ហ៊ាននិយាយរកខ្ញុំទេ ដោយសារខ្ញុំជាអ្នកមានទោស ។

ពេលកងទ័ពវៀតណាមវាយរំដោះឆ្នាំ១៩៧៩ ខ្ញុំបានប្រមូលកម្លាំងប្រជាជននៅក្នុងភូមិសម្រុកចេញច្បាំងដោយប្រើដំបងនិងកាំបិតផ្គាក់ ។ ពេលបែកឆ្នាំ១៩៧៩ ខ្ញុំបានត្រឡប់ទៅរកប្រពន្ធនិងកូនរបស់ខ្ញុំនៅភូមិស្វាយមាស ខេត្តកំពង់ចាមវិញ ប៉ុន្តែប្រជាជននៅទីនោះបានប្រាប់ខ្ញុំថា ទាំងប្រពន្ធនិងកូនខ្ញុំ៣នាក់ រួមទាំងប្អូនថ្លៃនិងឪពុកក្មេករបស់ខ្ញុំត្រូវអង្គការយកទៅសម្លាប់នៅភូមិបុសខ្នុរអស់ហើយ ។ នៅមុនពេលជម្លៀស អ្នកទាំងអស់បានភៀសខ្លួនមករស់នៅទីក្រុងភ្នំពេញនៅម្តុំច្បារអំពៅ ។ នៅពេលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញប្រពន្ធនិងកូនរបស់ខ្ញុំបានធ្វើដំណើរទៅរស់នៅស្រុកកំណើតវិញ ។ ខ្ញុំបានទៅតាមរកសាកសពអ្នកទាំងអស់ដែរ ប៉ុន្តែរកមិនឃើញ ។ នៅទីនោះខ្ញុំឃើញមានមន្ទីរឃុំឃាំងមួយដ៏ធំ ។

ខ្ញុំចង់បានយុត្តិធម៌ ដើម្បីឲ្យប្រពន្ធនិងកូនខ្ញុំព្រម ទាំងអ្នកដែលបាត់បង់ជីវិតផ្សេងទៀតបានអស់ចិត្ត ។ បើគ្មានតុលាការរកយុត្តិធម៌ទេ ប្រពន្ធកូន និងសាច់ញាតិរបស់ខ្ញុំនឹងស្លាប់ដោយមិនអស់ចិត្ត ហើយការឈឺចាប់របស់ខ្ញុំទាំងប៉ុន្មាននៅតែដក់ជាប់ក្នុងចិត្តគ្មានថ្ងៃណាភ្លេច ។ ខ្ញុំស្អប់របបខ្មែរក្រហមណាស់ ព្រោះរបបនេះបានជម្លៀសប្រជាជនទាំងអស់ឲ្យទៅធ្វើស្រែ ជារបបគ្មានច្បាប់ គ្មានទម្លាប់ គ្មានលុយចាយនិងគ្មានសាលារៀន ។

**ប៉ាង ពីច័ន**

## ពាក្យស្លោកខ្មែរក្រហម

◆ **ឈរជាប់ខាងនិងគ្រប់កាលៈទេសៈ លើជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន កាន់កាប់វាសនាខ្លួនដោយខ្លួនឯង។**

(សៀវភៅកំណត់ហេតុលេខ ០៧៦)

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
Email: dccam@online.com.kh
Home page: www.dccam.org

# ម៉ា យីនមេៈ ស្អីអីចេះអង្គការ?

ម៉ា យីនមេ ហៅណាង អាយុ៧០ឆ្នាំ ជាកូនកាត់កូឡា-ខ្មែរ បច្ចុប្បន្នរស់នៅជាមួយកូនស្រីនិងចៅៗពីរនាក់នៅក្នុងឃុំវត្តគរ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ណាង ជាកូនទោលក្នុងគ្រួសារអ្នកមានមួយដែលមានឪពុកឈ្មោះ ធន់ ទីន ជាជនជាតិកូឡា និងម្តាយឈ្មោះឡៃ ជាជនជាតិខ្មែរ ។ ឪពុករបស់ ណាង ជាអ្នកច្នៃត្បូងនៅបរប៉ៃលិន ចំណែកម្តាយជាអ្នកចម្ការ ។ ណាង បានក្លាយជាកូនកំព្រាម្តាយតាំងពីអាយុ៧ឆ្នាំម្ល៉េះ ។ ក្រោយពេលម្តាយស្លាប់ ឪពុករបស់ ណាង បានរៀបការប្រពន្ធម្នាក់ទៀត ហើយមានកូនបីនាក់ ប៉ុន្តែជាអកុសលកូនទាំងបីនិងប្រពន្ធក្រោយបានស្លាប់អស់ទៀត ។

នៅអាយុ១៩ឆ្នាំ ឪពុករបស់ ណាង បានរៀបការនាងទៅឲ្យបុរសម្នាក់ឈ្មោះ អ៊ុង ពុន ជាជនជាតិកូឡានិងជាអ្នករកស៊ីត្បូងដែលមានទីលំនៅនៅបរប៉ៃលិនដែរ ។ ក្រោយពេលរៀបការរួច ណាង បានទៅរស់បរប៉ៃលិនជាមួយប្តីប្រកបមុខរបរទិញត្បូងនិងធ្វើចម្ការដាំសារម៉ាវនិងធូរេនចំនួន១៣ហិកតា ដែលជាដីកេរ្តិ៍របស់ឪពុកម្តាយក្មេក ។ ណាង និងស្វាមីមានកូនប្រាំមួយនាក់ កូនប្រុសច្បងម្នាក់ស្លាប់ដោយសារត្រូវគ្រាប់នៅក្នុងរបបលន់ណុល ។

ខែមេសា ឆ្នាំ១៩៧៥ ពេលខ្មែរក្រហមវាយដណ្តើមក្រុងប៉ៃលិន ប្រជាជនកូឡាទាំងអស់ដែលរស់នៅភូមិបរតាំងស៊ូ ភូមិថាំងម៉ៃ បរឌិននៀវ និងភូមិអូរតាពុក ត្រូវបានជម្លៀសចេញ ។ បងប្អូនខាងម្តាយរបស់ ណាង បាននាំគ្នាភៀសខ្លួនទៅទីរួមខេត្តបាត់ដំបង ចំណែក ណាង និងគ្រួសារមិនរត់ទៅណាទេ ពីព្រោះប្តីរបស់គាត់មិនព្រមចេញ ដោយគិតថានឹងសុំខ្មែរក្រហមនៅទីនោះ ។ ខ្មែរក្រហមបានបើកឡានប្រកាសខ្លាំងៗថា «ចេញឲ្យអស់ត្រឹមព្រឹកថ្ងៃស្អែក» ។ ណាង និងគ្រួសារធ្វើដំណើរទៅដល់ក្បាលស្ពានខេត្តបាត់ដំបង ហើយត្រូវខ្មែរក្រហមកៀរត្រឡប់ក្រោយវិញ ។ ណាង បានសុំកងទ័ពខ្មែរក្រហមស្នាក់នៅមន្ទីរឃោសនាការមួយយប់ដើម្បីបន្តដំណើរនៅថ្ងៃស្អែក ។ ណាង និយាយទាំងអស់សំណើចថា «ខ្ញុំឆោតណាស់ ពេទ្យឆ្មបនៅមុខផ្ទះរបស់ខ្ញុំប្រាប់ថា ចែខ្ញុំទៅហើយ ចែឯងទៅមិនបាច់បិទទ្វារទេ សំពត់ខោអាវថ្មីៗ មិនបាច់យកទៅទេ អង្គការគេដេរថែរក្សាឲ្យ ។ ខ្ញុំថាស្អីអីចេះអង្គការ ។ បើចែឯងនៅចែឯងអុជម៉ាំងសុងកុំបិទទ្វារ ។ មានអី(ខ្ញុំ) អុជចង្កៀងម៉ាំងសុងឡើងភ្លឺតែម្នាក់ឯង ។ ស្រាប់តែនៅម៉ោងប្រហែលជា១០ ឡានហ្ស៊ីបមួយគ្រឿងបានបើកមកដល់កៀនផ្ទះខ្ញុំថា ម៉ោង៦ព្រឹកចេញឲ្យអស់ តែមិនចេញយើងបាញ់ចោលហើយ» ។

ក្រុមគ្រួសាររបស់ ណាង បានត្រូវជម្លៀសចេញពីភូមិមួយទៅភូមិមួយ ។ ដំបូង ណាង បានទៅស្នាក់នៅសាលាក្រៅរយៈពេលបីបួនថ្ងៃ អង្គការបានដេញឲ្យមកនៅភូមិដូងវិញ ។ នៅភូមិដូង ឃុំអម្ពិលប្រាំដើម អង្គការបានចាប់ផ្តើមប្រមូលទ្រព្យសម្បត្តិពីប្រជាជនដោយប្រាប់ថាបញ្ជូនទៅប្រទេសចិនដើម្បីដូរយកថ្នាំពេទ្យនិងសាច់ក្រណាត់ខ្មៅវិញ ។ នៅក្នុងភូមិនេះមានប្រជាជនកូឡាស្លាប់ច្រើន ហើយកូនរបស់ ណាង បីនាក់បានស្លាប់ដោយសារជំងឺរាកនិងហើម ។ ណាង និយាយថា «រាប់រយគ្រួសារងាប់ ខ្ញុំទៅនៅហ្នឹងងាប់អស់កូនបី ឪពុកមួយ ប្តីមួយ អស់ប្រាំនាក់នៅអម្ពិលប្រាំដើម ។ ពីរនាក់កប់ផ្នូរជិតគ្នា មួយទៀត កប់តែឯង ។ វេទនាណាស់ ។ កូឡាស្លាប់ច្រើនណាស់ ។ និយាយពីឈឺងាប់មហាងាប់ មិនមែនតែកូនខ្ញុំទេ អស់ពីកប់ឆ្ងាយ យូរទៅៗឆ្ងាយអត់បានកប់តែកៀនៗនេះឯង» ។ ក្រៅពីស្លាប់ដោយសារជំងឺ ជនជាតិកូឡាមួយចំនួនធំបានស្លាប់ដោយដាន់មីននិងត្រូវកងទ័ពខ្មែរក្រហមបាញ់សម្លាប់នៅពេលរត់គេចទៅប្រទេសថៃ។ ប្អូនថ្លៃរបស់ ណាង ឈ្មោះ អ៊ុង ញូន មួយគ្រួសារត្រូវខ្មែរក្រហមបាញ់សម្លាប់ចោលទាំងអស់ សព្វថ្ងៃសល់កូនស្រីម្នាក់រស់នៅក្នុងប្រទេសថៃ ។

ណាង ស្នាក់នៅភូមិដូងរយៈពេលជាងមួយខែ ទើបអង្គការចាប់ផ្តើមបំបែកប្រជាជនកូឡាជាក្រុមតូចៗ ហើយបែងចែកឲ្យទៅរស់នៅតាមភូមិផ្សេងទៀត ។ ណាង ត្រូវអង្គការបញ្ជូនមកនៅភូមិដំណាក់ដង្កោដែលជាកន្លែងពិបាករស់នៅបំផុតក្នុងអំឡុងពេល៣ឆ្នាំ៨ខែនិង២០ថ្ងៃ ។ ណាង ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើ

ស្រែនិងបោចស្មៅនិងច្របាច់ដី ។ ណាង ទទួលរបបបបរតែបីវែកប៉ុណ្ណោះក្នុងមួយពេល ។ ជួនកាលបបរនោះលាយជាមួយដីទៀត ភាគតិចណាស់ដែល ណាង បានហូបបបរលាយពោត ។ ក្រោយសម្រាកពីការងារ ណាង ត្រូវដើរបេះស្លឹកសង្កែទៅលីង និងយកសំបកដំឡូងឈើស្ងោរហូប ដើម្បីសម្រន់ការស្រេកឃ្លាន ។ ឪពុកនិងប្តីរបស់ ណាង កើតជំងឺរាកនិងហើម ហើយត្រូវអង្គការបញ្ជូនអ្នកទាំងពីរទៅសម្រាកនៅមន្ទីរពេទ្យដំណាក់សាលា ។ ក្រោយមកអ្នកទាំងពីរបានស្លាប់ជាបន្តបន្ទាប់ដោយ ណាង មិនបានជួបមុខអ្នកទាំងពីរជាចុងក្រោយផង ។ ណាង រំឭកថា «គាត់ (ប្តី) ស្គមដូចរូបអាសុភ គាត់ថាឲ្យអញចេញទៅ អញទៅដឹកទឹកបាយក៏អញរស់ដែរ ។ ខ្ញុំទៅសួរពេទ្យៗថាអ្នកជំងឺដើរបានគេឲ្យចេញ ដើរមិនបានគេមិនឲ្យចេញទេ ។ ខ្ញុំទៅរករទេះអ្នកភូមិមេកង មេក្រុមខ្ញុំអត់មាន គេយកចុះស្រែអស់ហើយ ។ បានប្រាំបីថ្ងៃខ្ញុំទៅទៀត គេ(អ្នកស្គាល់)មកប្រាប់ថា ប្តីខ្ញុំខ្លាំងហើយ ។ ខ្ញុំទៅឃើញតែមួកនិងអាវ គេយកទៅកប់បាត់អត់ឃើញ ដូចឪពុកខ្ញុំអ៊ីចឹង ។ សព្វថ្ងៃចង់គាស់ឆ្អឹងធ្វើបុណ្យមិនដឹងទៅរកឯណាទេ» ។ ក្រោយមក ណាង បាននាំកូនទាំងពីរលួចរត់ចេញពីដំណាក់ដង្កោមកនៅស្រែតាហែន ពីព្រោះគាត់ឮថានៅទីនោះ មានរបបហូបសេរី ។ ប៉ុន្តែនៅពេលទៅដល់ គណៈស្រុកស្រែតាហែនបានបញ្ជូនណាងនិងកូនៗមកដំណាក់ដង្កោវិញ ។ ប្រជាជនមូលដ្ឋានស្រែតាហែននាំគ្នាអាណិតអាសូរ ណាង ហើយបានសុំកូនៗរបស់ណាង ទៅចិញ្ចឹមព្រោះដឹងថាពេលត្រឡប់ទៅភូមិវិញប្រាកដជា



ក្រុមគ្រួសាររបស់ ម៉ា ឃីនមេ

គណៈស្រុកមិនទុកជីវិតទេ ។ ផ្ទុយទៅវិញ ណាង មិនបានទទួលទណ្ឌកម្មទេ គាត់ថែមទាំងត្រូវបានអនុញ្ញាតឲ្យរស់នៅភូមិដដែលទៀតផង ។ អ្នកភូមិប្រមាណ៦០គ្រួសារឃើញដូច្នេះ បាននាំគ្នារត់ចេញពីភូមិដែរ ប៉ុន្តែគ្មានសំណាងដូច ណាង ទេ អ្នកទាំងនោះត្រូវអង្គការដឹកតាមកាណូត ហើយឲ្យរស់នៅវាលស្រែដែលគ្មានអ្វីហូបទាល់តែសោះមិនដឹងថាស្លាប់ឬរស់ផង ។ ណាង បានឲ្យដឹងថា ខ្មែរក្រហមមិនធ្វើបាបកូឡាទេ ព្រោះកូឡាជាមនុស្សទៀងត្រង់ មិនដែលហ៊ានប្រឆាំងជាមួយអង្គការឡើយ អង្គការឲ្យធ្វើអ្វីធ្វើហ្នឹង ហើយឈឺស្លាប់ច្រើនដោយសារអត់អីហូប ពីព្រោះមិនចេះរក ។

ណាង ត្រូវប្រពន្ធរបស់ប្រធានភូមិឈ្មោះ យាយចាន់ ហាម មិនឲ្យ ណាង នាំកូននិយាយភាសាកូឡា ព្រោះខ្លាចឈ្លបដើរយប់ស្តាប់ឮ ។ ដូច្នេះ ណាង ត្រូវបង្ខំចិត្តនិយាយភាសាខ្មែរជាមួយកូនៗទាំងកូន មិនចេះនិយាយភាសាខ្មែរមួយម៉ាត់សោះ ។ ណាង បានមានប្រសាសន៍ថា «អត់មានលាវ មានសៀម មានចិន មានយួន អីអត់ទេ ។ អ៊ីខ្ញុំប្រពន្ធគាត់វៀតណាម អត់ចេះខ្មែរបន្តិចសោះចេះតែកូឡា គាត់និយាយទៅប៉ៃឡាំៗ រួចពួកអាពតវាដើរតាមដានហើយកូនគាត់ ចេះកូឡាដូចខ្ញុំអ៊ីចឹង វាប្រាប់ថាម៉ែវាកូឡា ហើយអ្នកជិតខាងថា គាត់ហ្នឹងកូឡាមែន បើយួនយកទៅវ៉ៃចោលបាត់ហើយ» ។



ណាង បានបន្តថា សព្វថ្ងៃនេះកូនៗរបស់គាត់ចេះនិយាយភាសាកូឡាបានបន្តិចបន្តួចប៉ុណ្ណោះ ប៉ុន្តែបើចៅៗវិញ ចេះស្តាប់និងអាចនិយាយភាសាកូឡាឆ្លើយឆ្លងជាមួយគាត់បានល្អ ។

ប្រហែលជាចុងឆ្នាំ១៩៧៧ ណាង ត្រូវអង្គការបញ្ជូនឲ្យទៅរស់នៅបាល័ង្ក ។ នៅទីនោះ ណាង មិនសូវលំបាកដូចនៅដំណាក់ដង្កោទេ អង្គការបានបែងចែកការងារឲ្យធ្វើដូចប្រជាជនមូលដ្ឋានដែរ ។ ណាង រស់ នៅភូមិបាល័ង្កនេះរហូតដល់ថ្ងៃកងទ័ពវៀតណាមចូលមកដល់ ។ នៅថ្ងៃ៧មករា ឆ្នាំ១៩៧៩ ណាង បាននាំកូនទៅរស់នៅស្រុកស្វាយស៊ីសុផុនអស់ជាច្រើនឆ្នាំ ទើបនាំកូនត្រឡប់មករស់នៅលើទឹកដីកំណើតរបស់ម្តាយគាត់វិញ ។ ណាង មិនបានត្រឡប់ទៅរស់នៅបរប៉ៃលិនទេ ពីព្រោះដីរបស់គាត់ត្រូវអ្នកផ្សេងកាន់កាប់បាត់ទៅហើយ ។ ណាង និយាយថា «គេ(ប្អូន)ហៅខ្ញុំទៅលេង ខ្ញុំមិនទៅទេ ទៅៗនាំតែនឹកឃើញសព្វគ្រប់» ។

ណាង មិនចង់ចងគំនុំជាមួយមេដឹកនាំខ្មែរក្រហមទេ គាត់យល់ថា មិនមែនមានតែគ្រួសារគាត់ទេដែលឈឺចាប់និងបាត់បង់សមាជិកគ្រួសារនោះ ប្រជាជនទាំងអស់ដែលរស់នៅក្នុងប្រទេសកម្ពុជាសុទ្ធតែឆ្លងកាត់នូវបទពិសោធន៍ឈឺចាប់ដូចៗគ្នា ។ ណាង បន្ទោសរបបខ្មែរក្រហមថា បានធ្វើឲ្យគាត់បាត់បង់ទ្រព្យសម្បត្តិនិងសាច់ញាតិ ហើយជនជាតិកូឡាទាំងអស់ត្រូវរស់នៅបែកខ្ញែកគ្នា ។ សព្វថ្ងៃនៅក្រុងប៉ៃលិនមានប្រជាជនកូឡារស់នៅតែបីបួនគ្រួសារប៉ុណ្ណោះ ។

**លី សុផល**

# ជីវិត ថន បាន




ថន បាន អង្គុយសំឡឹងមើលរូបថតប្អូនស្រីទាំងទឹកមុខស្រងូតស្រងាត់ ។ ថន បាន សួរខ្ញុំថាហេតុអ្វីបានជាប្អូនស្រីរបស់គាត់ត្រូវខ្មែរក្រហមចាប់ខ្លួន? ទោះបីយ៉ាងណា ថន បាន ជឿជាក់ថាប្អូនស្រីរបស់គាត់ប្រាកដជាមិនអាចមានជីវិតរស់ទេ ពីព្រោះតាមរយៈប្រវត្តិរូបបញ្ជាក់ថានាងឈ្មោះ អ៊ឹម ប៉ារីស ត្រូវបានចាប់ខ្លួនបញ្ជូនមកគុកព្រៃសនៅថ្ងៃទី២១ ខែមករា ឆ្នាំ១៩៧៨ ។

ថន បាន មានប្អូនពីរនាក់ឪពុកតែមួយ និងប្អូនស្រីម្នាក់ឈ្មោះ អ៊ឹម ប៉ារីស ឪពុកជាជនជាតិបារាំង ។

ឪពុកបង្កើតរបស់ ថន បាន ឈ្មោះ នួន ថន បានរៀបការជាមួយម្តាយគាត់ឈ្មោះ អ៊ុយ ក្នុងទសវត្សរ៍ឆ្នាំ១៩៤០ ហើយបានកូនបីនាក់ ។ ក្រោយមក ដោយសារជីវភាពក្រលំបាកពេក ឪពុកម្តាយរបស់គាត់បានលែងលះគ្នា ។ ថន បាន ត្រូវរស់នៅជាមួយប្អូននិងម្តាយ នៅក្នុងស្រុកភូមិដដែល ។ បន្ទាប់ពីលែងលះគ្នាឪពុករបស់ ថន បាន ផ្លាស់ទៅរស់នៅទីក្រុងភ្នំពេញ ។ ថន បានមិនបានរៀនសូត្រជ្រៅជ្រះនៅពេលនោះ ដោយសារគាត់រវល់រកលុយចិញ្ចឹមប្អូនៗនិងម្តាយមេម៉ាយ ។

ដើមឆ្នាំ១៩៥០ ម្តាយរបស់ ថន បាន បានទៅធ្វើជាចុងភៅដាំបាយនិងរៀបចំផ្ទះសំបែងឲ្យជនជាតិបារាំងម្នាក់ឈ្មោះ ពិកា ។ ក្រោយមកអ្នកទាំងពីរក៏បានស្រលាញ់គ្នា ហើយបានយកគ្នាជាប្តីប្រពន្ធ ។ ពិកា ជាវិស្វករសាងសង់ផ្លូវថ្នល់ដែលបានមកបម្រើការនៅប្រទេសកម្ពុជាតាំងពីមុនឆ្នាំ១៩៥០មកម្ល៉េះ ។ ពិកា ជាអ្នកមើលការខុសត្រូវលើកម្មករសាងផ្លូវកៅស៊ូពីព្រំប្រទល់ខេត្តកំពង់ចាមទៅដល់ទីរួមខេត្តព្រៃវែង ។ ម្តាយរបស់ ថន បាន រស់នៅជាមួយជនជាតិបារាំងនោះនៅឯឃុំពានា ស្រុកកញ្ជ្រៀច ខេត្តព្រៃវែងបានរយៈពេល៣ឆ្នាំ ។

ចុងឆ្នាំ១៩៥៣ ពិកា ត្រូវបញ្ចប់បេសកម្មនៅប្រទេសកម្ពុជានិងត្រូវវិលត្រឡប់ទៅប្រទេសបារាំងវិញ ។ នៅពេលចាកចេញ ម្តាយរបស់ ថន បាន មិនបានប្រាប់ប្តីថាគាត់មានផ្ទៃពោះទេ ។ ៦ខែក្រោយមក ម្តាយរបស់ ថន បាន សម្រាលបានកូនស្រីមួយដាក់ឈ្មោះថា ប៉ារីស ។

ឆ្នាំ១៩៥៦ ពេលដែល ប៉ារីស អាយុបានជិត៣ឆ្នាំ ម្តាយរបស់ ថន បាន បានរៀបការជាមួយបុរសពោះម៉ាយម្នាក់ឈ្មោះ អ៊ឹម ។ អ្នកទាំងពីរគ្មានកូននឹងគ្នាទេ ។ ៣ឆ្នាំក្រោយ អ៊ឹម បានស្លាប់ចោលម្តាយរបស់ បាន ថន ទៀត ។

ឆ្នាំ១៩៥៩ ម្តាយរបស់ ថន បាន ក៏បានធ្លាក់ខ្លួនឈឺ ដូច្នេះបន្ទុកគ្រួសារត្រូវធ្លាក់មកលើខ្លួនគាត់ទាំងស្រុង ។ ថន បាន ខិតខំរកប្រាក់ដើម្បីព្យាបាលជំងឺម្តាយរហូតបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យរុស្ស៊ីឯទីក្រុងភ្នំពេញ ប៉ុន្តែគ្មានបានផលអ្វីបន្តិចសោះ ថន ក៏បាននាំម្តាយមកស្រុកកំណើតវិញ ។ ម្តាយរបស់ ថន ឈឺអស់រយៈពេល៨ឆ្នាំទើបស្លាប់ ។

បន្ទាប់ពីម្តាយស្លាប់ចោល ថន បាន ទទួលបន្ទុកមើលថែនិងផ្គត់ផ្គង់ប្អូនៗឲ្យរៀនសូត្រ ។ ថន បាន ស្រលាញ់ ប៉ារីស ណាស់ ពីព្រោះ ប៉ារីស ជាក្មេងស្រីស្អាត ហើយមានប្រាជ្ញាឈ្លាសវៃទៀតផង ។ ថន បាន បានបញ្ជូន ប៉ារីស ទៅរៀននៅសាលាវត្តព្រៃស្វាយ ក្នុងស្រុកកញ្ជ្រៀច ។ ប៉ារីស រៀនបានត្រឹមថ្នាក់ទី៧ពីសង្គមចាស់ ។ ប៉ារីស អាចនិយាយនិងចេះសរសេរភាសាបារាំងបានយ៉ាងល្អ ។

ក្រោយថ្ងៃរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ក្នុងឆ្នាំ១៩៧០ ប៉ារីស បានឈប់រៀន ចំណែកខ្លួនគាត់បានទៅធ្វើការជាមួយមិត្តភក្តិម្នាក់ឈ្មោះ សុភា កេត តំណាងរាស្ត្រស្រុកកញ្ជ្រៀច ដើរប្រមូលប្រជាជនពីស្រុកចំនួន៣ដើម្បីចូលរួមជង្រែក្បួនបាតុកម្មទាមទារឲ្យសម្តេច សីហនុ ឡើងកាន់រាជបល្ល័ង្កវិញ ។ សុភា កេត ទទួលខុសត្រូវក្នុងការបញ្ចុះបញ្ចូលនិងប្រមូលប្រជាជនពីស្រុកព្រៃវែង ចំណែក ថន បាន ជាអ្នកប្រមូលប្រជាជនក្នុងស្រុកកញ្ជ្រៀចនិងស្រុកស៊ីធរកណ្តាល ។

ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧០ ក្បួនបាតុកម្មនេះមាន

គោលបំណងដង្ហែទៅឈប់នៅមុខសភាជាតិនៃទីក្រុងភ្នំពេញ ដើម្បីសុំជួបជាមួយលោកសេនាប្រមុខ លន់ នល់ ក្នុងការទាមទារឲ្យសម្តេច សីហនុ ចូលប្រទេសវិញ។ ក្បួនរថយន្តដែលមានចំនួន ៤០ គ្រឿងបានតម្រៀបនៅលើផ្លូវបានចេញដំណើរពីស្រុកព្រៃវែងឆ្ពោះទៅចូលទីក្រុងភ្នំពេញ។ ក៏ប៉ុន្តែក្បួនបាតុកម្មនេះត្រូវទាហានរបស់ លន់ ណុន ដែលជាប្អូនរបស់ លន់ នល់ បាញ់រះបញ្ឈប់ដំណើរនៅត្រឹមទីរួមខេត្តព្រៃវែង។

សុភា កេត ត្រូវទាហានបាញ់ស្លាប់នៅនឹងកន្លែង។ បាតុករជាច្រើនបានត្រូវស្លាប់នៅនឹងកន្លែង។ ថន បាន និងអ្នកបើកឡានម្នាក់ទៀត បានប្រកាសឲ្យក្រុមបាតុករទាំងអស់ត្រឡប់ក្រោយវិញ។ ចាប់តាំងពីពេលនោះមកការរស់នៅរបស់ ថន បាន គឺស្ថិតនៅក្រោមការតាមដាននិងឃ្លាំមើលពីទាហាន លន់ នល់ គ្រប់ពេលវេលា។ ថន បាន ត្រូវបានចោទប្រកាន់ថាជាមេដឹកនាំធ្វើបាតុកម្មតវ៉ាប្រឆាំងនឹងរដ្ឋាភិបាល លន់ នល់ ។


អ៊ឹម ប៉ារីស ក្នុងឆ្នាំ១៩៦៩


អ៊ឹម ប៉ារីស ក្នុងឆ្នាំ១៩៧៨

ដោយភ័យខ្លាចពីការតាមដាននិងគោលបំណងទាមទារអំណាចជូនសម្តេចព្រះ នរោត្តម សីហនុ ថន បាន បានសម្រេចចិត្តរត់ចូលព្រៃម៉ាគីជាមួយក្រុមអ្នកតស៊ូជាច្រើនទៀតដោយទុកឲ្យប្អូនៗចោលនៅឯផ្ទះ។

ពីរសប្តាហ៍ក្រោយមក ប៉ារីស បានរត់ចូលព្រៃដើម្បីតាមរក ថន បាន។ ប៉ុន្តែមិនបានជួប នាងក៏ត្រឡប់មកស្រុកភូមិវិញ។ ដោយការព្រួយបារម្ភអំពីសុវត្ថិភាពរបស់ ប៉ារីស, ថន បាន បានផ្តាំផ្ញើឲ្យ សុង លេខាស្រុកកញ្ជៀចនិងត្រូវជាមិត្តភក្តិជួយមើលថែប្អូនស្រីជំនួសខ្លួនផង ខ្លាចក្រែងពួកទាហាន លន់ នល់ ធ្វើបាបនាង។

រយៈពេល៣ខែក្រោយពីរត់ចូលព្រៃរបស់ ថន បាន, សុង បាននាំ ប៉ារីស និងមិត្តភក្តិរបស់ ប៉ារីស ពីរនាក់ទៅធ្វើការនៅមន្ទីរស្រុកជាមួយគាត់។ សុង បានឲ្យ ប៉ារីស កាន់ខាងភ័ស្តុភារនិងជួយធ្វើការងារនៅក្នុងផ្ទះរបស់គាត់។

បន្ទាប់ពីសភាពការណ៍បានស្ងប់ស្ងាត់ ថន បាន វិលត្រឡប់ចូលភូមិវិញ។ ថន បាន ត្រូវអង្គការចាត់តាំងឲ្យកាន់ខាងសេដ្ឋកិច្ចឃុំ និងជាអ្នកផ្គត់ផ្គង់ស្បៀងអាហារឲ្យទ័ពតំបន់និងទ័ពភូមិភាគ។ ថន បាន ដើរទិញ អង្ករ ជ្រូក មាន់ ទា និងអំបិលនៅតាមស្រុកផ្សេងៗ ដើម្បីដឹកទៅសមរភូមិប្រយុទ្ធផ្សេងៗ មិនថាជិតឬឆ្ងាយនោះទេ។

ឆ្នាំ១៩៧២ ប៉ារីស បានមកលេងផ្ទះម្តង ហើយថែមទាំងបានយកស្បែកជើងកង់ឡានមួយគូនិងខោអាវជូនបងប្រុសទៀតផង។ ប៉ារីស បានប្រាប់បងប្រុសថានាងធ្វើការនៅមន្ទីរស្រុកជាមួយ សុង ដែលជាលេខាស្រុក ហើយមិត្តភក្តិរបស់នាងពីរនាក់ឈ្មោះ គុន និង សឿន ក៏ធ្វើការនៅទីនោះដែរ។ ប៉ារីស ស្នាក់នៅផ្ទះបាន៤ថ្ងៃ ក៏ត្រឡប់ទៅមន្ទីរស្រុកវិញ ព្រមទាំងបាននាំយកកូនរបស់ ថន បាន ពីរនាក់ទៅជាមួយផង។ នៅពេលនោះ ថន បាន មមាញឹកការងារខ្លាំងណាស់ ក្នុងការស្វែងរកទិញស្បៀងទៅឲ្យយោធាស្រុក យោធាតំបន់ និងយោធាភូមិភាគ។

បន្ទាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ជ័យជម្នះរបស់អង្គការអាវខ្មៅ ថន បាន ត្រូវដកពីតំណែង។ ថន បាន ត្រូវអង្គការខ្មែរក្រហមចោទថាមានជាប់ខ្សែស្រឡាយជាមួយព្រះអង្គម្ចាស់ ប៊ុទុមចាន់។ ដោយសារតែបញ្ហានេះ ថន បានត្រូវចាត់តាំងឲ្យធ្វើការនៅតាមសហករណ៍ដូចជាប្រជាជនធម្មតាដែរ។

បួនខែក្រោយមក ប៉ារីស ត្រូវអង្គការបញ្ជូនទៅធ្វើការនៅភ្នំពេញ។ ប៉ារីស ជាអនុប្រធានរោងចក្រស្បែកជើងដឹបតុង

ដែលស្ថិតនៅម្តុំទួលគោក ។ ឆ្នាំ១៩៧៦ ប៉ារីស បានច្បាប់អនុញ្ញាតមកលេងផ្ទះម្តងទៀត នាងបានប្រាប់បងប្រុសថា ធ្វើការរោងចក្រស្បែកជើងនៅភ្នំពេញ ។ ប៉ារីស ស្នាក់នៅផ្ទះបាន២ថ្ងៃ ក៏បានត្រឡប់ទៅភ្នំពេញវិញ រួចក៏បាត់ដំណឹងចាប់តាំងពេលនោះមក ។

ក្នុងរបបខ្មែរក្រហម ថន បាន បានស៊ើបសួរដំណឹង ប៉ារីស ជាច្រើនកន្លែង ប៉ុន្តែមិនបានទទួលនូវដំណឹងអ្វីទាល់តែសោះ គាត់សង្ស័យថា ប៉ារីស ប្រហែលជាស្លាប់នៅអំឡុងពេលដែលមានការចាប់ខ្លួនកម្មាភិបាលភូមិភាគបូព៌ានិងការបោសសម្អាតកម្មាភិបាលដែលបម្រើការនៅតាមក្រសួង និងមន្ទីរ នានា ដែលមកពីភូមិភាគបូព៌ាបាត់ទៅហើយ ។

ថន បាន រស់នៅក្នុងសហករណ៍ជាមួយអ្នកភូមិរហូតទាល់តែវៀតណាមរំដោះបានប្រទេសទាំងស្រុង ។ ក្រោយឆ្នាំ១៩៧៩ ថន បាន បានបន្តតាមរក ប៉ារីស រហូតដល់ខេត្តបន្ទាយមានជ័យ ប៉ុន្តែនៅតែគ្មានដំណឹងពីនាង ។

ថន បាន ឈឺចាប់និងស្តាយក្រោយជាខ្លាំងអំពីការខិតខំប្រឹងប្រែងរបស់គាត់ចំពោះបដិវត្តន៍ខ្មែរក្រហម ក្រោយពីឮសេចក្តីប្រកាសថា ប៉ុល ពត ជាលេខាបក្សកុម្មុយនីស្តកម្ពុជា ដែលផ្ទុយពីការរំពឹងទុករបស់គាត់ថា ការធ្វើសង្គ្រាមប្រជាជាតិ គឺដើម្បីទាមទារនិងយកអំណាចប្រគល់ជូនសម្តេចព្រះនរោត្តម សីហនុ វិញ ។ ថន បាន ចង់ឲ្យតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមឲ្យបានឆាប់ៗ ព្រោះថាបើយឺតពេលមេដឹកនាំទាំងនោះនឹងស្លាប់អស់ ។ **សារិន ឌីរៈ**

# ឱក សារឿន ទាហានស័ក្តិ៥ជំនាន់លន់នល់

ឱក សារឿន ជានាយទាហានស័ក្តិ៥ កងពលធំលេខ៩ នៅក្នុងរបបលន់នល់ ។ សារឿន និងក្រុមគ្រួសារត្រូវខ្មែរក្រហមជម្លៀសពីទីក្រុងភ្នំពេញឆ្ពោះទៅខេត្តកំពង់ស្ពឺនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៥ សារឿន ត្រូវអង្គការខ្មែរក្រហមបញ្ជូនទៅរៀនសូត្រដោយមិនដឹងថាស្លាប់ឬរស់ ។ នៅក្នុងឆ្នាំដដែលកូនទាំង៤នាក់របស់គាត់ ក៏បានស្លាប់ជាបន្តបន្ទាប់ដោយសារអត់អាហារនិងជំងឺ ។ ចំណែកប្រពន្ធរបស់ សារឿន បានក្លាយជាមនុស្សវិកលចរិតនិងស្លាប់នៅក្នុងរបបនោះដែរ ។

សារឿន មានស្រុកកំណើតនៅភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

សារឿន បានបន្សល់ទុកនូវរូបថតមួយសន្លឹក ដែលនៅក្នុងរូបថតនោះមានរូបគាត់និងកូនទាហានឈរនៅមុខប្រាសាទព្រះវិហារ នៅពេលដឹកជញ្ជូនស្បៀងទៅឲ្យទាហានដែលកំពុងតែជាប់ដៃច្បាំងជាមួយទាហានថៃដើម្បីទាមទារប្រាសាទព្រះវិហារមកវិញ ។

នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៦០នេះ សារឿន បានប្រឡងជាប់ថ្នាក់ទី៦(ថ្នាក់ពីសង្គមចាស់) ហើយគាត់បានសម្រេចចិត្តប្រឡងចូលធ្វើជាទាហាននិងបានទៅបំពេញមុខវិជ្ជានេះបន្ថែមនៅប្រទេសបារាំងរយៈពេលពីរឆ្នាំ ។ បន្ទាប់ពីត្រឡប់មកពីប្រទេសបារាំងវិញ សារឿន ត្រូវព្រះករុណាសម្តេចព្រះ នរោត្តម សីហនុ បំពាក់ស័ក្តិ២ ទទួលបន្ទុកខាងដឹកជញ្ជូនស្បៀងអាហារទៅឲ្យកងទ័ពនៅក្នុងសមរភូមិ ។

ពេលនោះសាច់ញាតិនិងក្រុមគ្រួសាររបស់គាត់បានណែនាំឲ្យស្គាល់នារីម្នាក់ឈ្មោះ សាយ យុន ដែលរស់នៅស្រុកកំណើតជាមួយគ្នា ។ ក្រោយពីរៀបការរួច សារឿន បាននាំប្រពន្ធទៅរស់នៅបន្ទាយស្លឹកនៅម្តុំពេទ្យរុស្ស៊ីភ្នំពេញ ។ ពេលនោះជីវភាពអ្នកទាំងពីរមិនទាន់ធូរធានៅឡើយទេ ទាំងការរស់នៅនិងការហូបចុកនៅមានការខ្វះខាតនៅឡើយ ។

ក្រោយពី លន់ នល់ ឡើងកាន់អំណាចនៅឆ្នាំ១៩៧០ សារឿន បានទទួលតំណែងស័ក្តិ៥ នៅក្នុងកងពលធំលេខ៩ ក្នុងចំណោមកងពលធំទាំង៧នៅក្រោមចំណុះរបស់អគ្គសេនាធិការ ។ បន្ទាយរបស់ សារឿន នៅពេលនោះឋិតនៅទីតាំងនៅបឹងកក់ក្រោយមន្ទីរពេទ្យកាល់ម៉ែត្រ ។ នៅក្នុងកងពលធំលេខ៩ មានការិយា-

ល័យទាំងអស់៦ មានឃ្លាំងសម្រាប់ដាក់គ្រាប់ ស្បៀងអាហារ សម្លៀកបំពាក់ សម្ភារផ្សេងៗ និងមានមន្ទីរពេទ្យបម្រុងនិងអាគារ សម្រាប់ជនពិការស្នាក់នៅ។ សារឿន និងប្រពន្ធផ្លាស់មកនៅម្តុំទីកល្ពក់ ហើយជីវភាពរបស់អ្នកទាំងពីរក៏បានធូរធាជាងមុន។

កងពលធំលេខ៥មានតួនាទីប្រចាំការនៅផ្លូវជាតិលេខ៥ ដើម្បីវាយផ្តាច់ផ្លូវនិងទប់ស្កាត់កុំឲ្យកងទ័ពយៀកកុង ឬកងទ័ពបដិវត្តន៍ចូលទីក្រុងភ្នំពេញ។ មានពេលខ្លះកងពលធំលេខ៥ និងកងពលធំលេខ៧សហការច្បាំងនៅក្នុងសមរភូមិដែរ។ នៅពេលប្រយុទ្ធជាមួយខ្មាំងសត្រូវម្តងៗ កងពលនេះត្រូវប្រចាំការនៅសមរភូមិជាច្រើនខែ គ្មាននរណាម្នាក់អាចវិលត្រឡប់មកបន្ទាយវិញបានទេ អ្នកដែលស្លាប់ចេះតែស្លាប់ ឯអ្នកដែលនៅរស់ត្រូវឡើងច្បាំងបន្ត។ ស្បៀងអាហារ គ្រឿងសព្វាវុធ គ្រាប់រំសេវ ប្រដាប់ប្រដាប្រើប្រាស់ផ្សេងៗនិងសម្ភារសឹកទាំងអស់ អាមេរិកាំងជាអ្នកឧបត្ថម្ភ។ ពេល សារឿន កំពុងធ្វើការនៅភ្នំពេញ ឪពុកម្តាយនិងសាច់ញាតិរបស់ សារឿន រស់នៅខេត្តកំពង់ធំ។

គ្រូបង្រៀននៅស្រុកបារាយណ៍ត្រូវបានបំពាក់កាំភ្លើងគ្រប់ដៃដើម្បីជួយការពារសាលារៀន។ បងថ្លៃរបស់ សារឿន ក៏ធ្វើជាគ្រូបង្រៀនដែរ។ ក្រោយមកសភាពការណ៍កាន់តែធ្ងន់ធ្ងរឡើងៗ គ្រូៗបានយកកាំភ្លើងលាក់ទុកនៅក្នុងស្រះទឹកខាងក្រោយផ្ទះរបស់ឪពុក សារឿន។ គ្រូៗទាំងនោះខ្លះភៀសខ្លួនទៅភ្នំពេញនិងខ្លះទៀតភៀសខ្លួនទៅតាមខេត្តផ្សេងៗ។ ពេលនោះកងទ័ពបដិវត្តន៍បានមកឆែកឆេរនៅផ្ទះរបស់ឪពុក សារឿន ហើយក៏រកឃើញកាំភ្លើងទាំងនោះ។ ឪពុករបស់គាត់ឈ្មោះ ឌិត សំអុន ត្រូវអង្គការហៅទៅរៀនសូត្រ ហើយក៏បាត់ខ្លួនតាំងពីពេលនោះមក។ ពេលមានរឿងនេះកើតឡើង សារឿន មិនអាចទាក់ទងមកសាច់ញាតិនៅឯខេត្តបានឡើយ។

ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃដែលកងទ័ពបដិវត្តន៍ចាប់ផ្តើមជម្លៀសប្រជាជនឲ្យចាកចេញពីទីក្រុងភ្នំពេញ សារឿន ប្រពន្ធ និងកូនៗ ព្រមទាំងក្មួយស្រីម្នាក់ទៀតបានធ្វើដំណើរដោយរថយន្តតាមផ្លូវពោធិ៍ចិនតុងឆ្ពោះទៅខេត្តកំពង់ស្ពឺ។ ក្រោយមករថយន្តរបស់គាត់ត្រូវអង្គការដកយកនៅម្តុំវត្តខ្វាន់។ សារឿន រស់នៅខេត្តកំពង់ស្ពឺបានរយៈពេល៣ខែ ត្រូវបានអង្គការហៅទៅរៀនសូត្រហើយបាត់ដំណឹងរហូតមក។ បន្ទាប់មក កូនប្រុសម្នាក់ និងកូនស្រីទាំងបីនាក់របស់ សារឿន ត្រូវបាត់បង់ជីវិតជាបន្តបន្ទាប់ ដោយសារតែខ្វះអាហារបរិភោគនិងឈឺគ្មាន ថ្នាំសង្កូវព្យាបាលគ្រប់គ្រាន់។ ក្រោយពីការបាត់បង់ប្តីនិងកូនបួននាក់ សាយ យុន បានក្លាយទៅជាមនុស្សវិកលចរិត មួយថ្ងៃៗគិតតែពីសូត្រធម៌។ មិនយូរប៉ុន្មាន សាយ យុន ក៏បានស្លាប់ដែរ។ ចំណែកឯម្តាយរបស់ សារឿន និងសាច់ញាតិត្រូវបានខ្មែរក្រហមជម្លៀសទៅបឹងបី ខេត្តបាត់ដំបង ដែលនៅទីនោះសាច់ញាតិរបស់ សារឿន ស្លាប់បង់ជីវិតស្ទើរតែអស់។


ឌិត សារឿននិងកូនទាហាន ថតនៅមុខប្រាសាទព្រះវិហារ

បច្ចុប្បន្នក្រុមគ្រួសារ សារឿន នៅសល់តែប្អូនស្រីម្នាក់គត់ឈ្មោះ ឌិត គឹមសុង ដែលកំពុងរស់នៅសហរដ្ឋអាមេរិក។ សារឿន បានបន្សល់ទុកនូវរូបថតមួយសន្លឹកនេះនៅជាមួយក្មួយស្រីរបស់គាត់ឈ្មោះ ប៉ិច ផាច។ ចំណែករូបថតផ្សេងទៀត ត្រូវខ្មែរក្រហមរុះរើនិងដុតបំផ្លាញចោលអស់គ្មានសល់។ **គង់ សុភគឿន**

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥ អង្គការសហប្រជាជាតិបានសម្រេចយកបញ្ហាការដ្ឋានកងទ័ពជើងគោក (រូបភាពខាងក្រោម) ដែលទើបនឹងសាងសង់ថ្មីនៅឯជាយក្រុងភ្នំពេញធ្វើជាទីតាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ ។









# សិទ្ធិនិងភារកិច្ចរបស់មេធាវីចុងចោទ

## ១) សេចក្តីផ្តើម

សិទ្ធិរបស់មេធាវីចុងចោទធានាថា មេធាវីអាចការពារជនជាប់ចោទក្នុងតួនាទីជាដៃគូស្មើភាពគ្នារបស់ព្រះរាជអាជ្ញានៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ។ ទន្ទឹមនឹងនោះដែរ មេធាវីចុងចោទត្រូវចងភ្ជាប់ដោយភារកិច្ចមួយចំនួនដើម្បីធានាថា ផលប្រយោជន៍កូនក្តីរបស់ខ្លួននិងសហគមន៍ច្បាប់មិនត្រូវបានប៉ះពាល់ដោយការតំណាងផ្នែកច្បាប់ឡើយ ។

នៅក្នុងប្រព័ន្ធយុត្តិធម៌ភាគច្រើន សិទ្ធិនិងភារកិច្ចរបស់មេធាវីត្រូវបានគ្រប់គ្រងដោយច្បាប់របស់គណៈមេធាវី និងក្រមសីលធម៌វិជ្ជាជីវៈមេធាវី ។ ខចែងបន្ថែមស្តីអំពីសិទ្ធិនិងភារកិច្ចរបស់មេធាវីចុងចោទត្រូវបានរកឃើញនៅក្នុងច្បាប់ព្រហ្មទណ្ឌនិងច្បាប់នីតិវិធីព្រហ្មទណ្ឌ ។

នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិក្រមសីលធម៌ដែលគ្រប់គ្រងសិទ្ធិ និងភារកិច្ចរបស់មេធាវីចុងចោទ ។ សាលាជំនុំជម្រះក្តីខ្មែរក្រហមស្ថិតក្រោមអន្តរជាតិបានធ្វើសេចក្តីព្រាងក្រមបែបនេះឬប្រើប្រាស់ច្បាប់ក្នុងស្រុកដែលមានស្រាប់ដើម្បីដោះស្រាយបញ្ហា ។

សិទ្ធិនិងភារកិច្ចរបស់មេធាវីនៅក្នុងសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌចម្រុះនិងអន្តរជាតិៈ

ICC: ក្រមសីលធម៌ ច្បាប់នីតិវិធី និងភស្តុតាង(មាត្រា ២២១)

ICC:ក្រមវិជ្ជាជីវៈមេធាវីចុងចោទ

ICC:ក្រមវិជ្ជាជីវៈសម្រាប់មេធាវីដែលត្រូវការពារនៅចំពោះICC: និងបទបញ្ជាស្តីពីការប្រគល់ការងារដល់មេធាវីតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនៈ ក្រមវិជ្ជាជីវៈមេធាវីជាមួយនឹងសិទ្ធិរបស់អ្នកស្តាប់នៅចំពោះមុខតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ។

កូសូវ៉ូៈ ច្បាប់ស្តីពីការការពារក្តីនិងជំនួយផ្សេងទៀតនៅក្នុងឆ្នាំ១៩៧៩ លក្ខន្តិកៈរបស់គណៈមេធាវីកូសូវ៉ូ, ក្រមសីលធម៌វិជ្ជាជីវៈ និងក្រមនីតិវិធីព្រហ្មទណ្ឌអន្តរកាលកូសូវ៉ូ ។

**នៅក្នុងប្រទេសកម្ពុជា សិទ្ធិ និងភារកិច្ចរបស់មេធាវីចុងចោទ បច្ចុប្បន្ននេះត្រូវគ្រប់គ្រងដោយៈ**

- ច្បាប់ស្តីពីគណៈមេធាវីឆ្នាំ១៩៩៥
- ក្រមសីលធម៌មេធាវីដែលទទួលស្គាល់ដោយគណៈមេធាវីរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៥
- ច្បាប់នីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣
- ច្បាប់អ៊ុនតាក់ឆ្នាំ១៩៩២

សម្រាប់អង្គជំនុំជម្រះវិសាមញ្ញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានចែងថា អង្គជំនុំជម្រះវិសាមញ្ញនឹងធានាថា មេធាវីចុងចោទអាចអនុវត្តសិទ្ធិរបស់ខ្លួនដោយឯករាជ្យ និងធានាថាមេធាវីចុងចោទនឹងបំពេញតួនាទីរបស់ខ្លួនស្របជាមួយនឹងក្រមសីលធម៌កម្ពុជានិងច្បាប់ស្តីពីការបង្កើតគណៈមេធាវីដែលមានស្រាប់ ។

**កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា មាត្រា២១ៈ មេធាវី**

១) រាជរដ្ឋាភិបាលមិនត្រូវដាក់មេធាវីរបស់ជនសង្ស័យ ឬជនជាប់ចោទ ដែលត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះវិសាមញ្ញឲ្យស្ថិតនៅក្រោមវិធានការណាមួយ ដែលអាចប៉ះពាល់ដល់ការបំពេញតួនាទីដោយសេរី និងឯករាជ្យរបស់ពួកគេនៅក្រោមកិច្ចព្រមព្រៀងនេះ ។

២) ជាពិសេសមេធាវីនឹងទទួលបានៈ

ក) អភ័យឯកសិទ្ធិលើការចាប់ខ្លួន ឬការឃុំខ្លួននិងការរឹបអូសយកសម្ភារផ្ទាល់ខ្លួន ។

១) ភាពមិនអាចរំលោភបំពានបានទៅលើឯកសារទាំងអស់ទាក់ទងនឹងការអនុវត្តមុខងាររបស់ខ្លួនក្នុងនាមជាមេធាវីរបស់ជនសង្ស័យឬជនជាប់ចោទ ។

ក) អភ័យឯកសិទ្ធិយុត្តាធិការព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីទាក់ទងនឹងពាក្យសម្តីនិយាយឬសរសេរ និងសកម្មភាពដែលពួកគេបានបំពេញនៅក្នុងតួនាទីជាមេធាវី ។ អភ័យឯកសិទ្ធិបែបនេះនឹងនៅបន្តផ្តល់ចំពោះមេធាវី ក្រោយពីមេធាវីទាំងនោះបានបញ្ចប់មុខងាររបស់ខ្លួនឲ្យជនសង្ស័យឬជនជាប់ចោទ ។

៣) មេធាវីដែលមានសញ្ជាតិខ្មែរ ឬមិនមែនខ្មែរដែលត្រូវដួលឬចាត់តាំងឲ្យធ្វើការជាមួយជនសង្ស័យ ឬជនជាប់ចោទក្នុងការការពារកូនក្តីរបស់ខ្លួន ត្រូវអនុវត្តតាមកិច្ចព្រមព្រៀងនេះច្បាប់កម្ពុជាស្តីពីលក្ខន្តិកៈមេធាវី បទដ្ឋាននិងសីលធម៌នៃវិជ្ជាជីវៈច្បាប់ដែលគេទទួលស្គាល់ ។

## ២) សិទ្ធិរបស់មេធាវីចុងចោទ

សិទ្ធិរបស់មេធាវីចុងចោទរួមមានការធានាអំពីឯករាជ្យភាពរបស់មេធាវីចុងចោទ សិទ្ធិត្រួតពិនិត្យមើលឯកសាររបស់កូនក្តី សិទ្ធិទទួលបានសម្ភារនិងសិទ្ធិរក្សាការសម្ងាត់ស្តីអំពីបញ្ហាសំខាន់របស់មេធាវីឬកូនក្តី ។ នៅក្នុងយុត្តាធិការភាគច្រើន សិទ្ធិរបស់មេធាវីត្រូវបានការពារតាមរយៈគណៈមេធាវីដែលគ្រប់គ្រងដោយខ្លួនឯង ។

ក) ច្បាប់កម្ពុជា

មេធាវីកម្ពុជាត្រូវបានអនុញ្ញាតឲ្យបង្កើតគណៈមេធាវីដែលមានទម្រង់ជាសមាគមមិនរកប្រាក់កម្រៃដែលមានអំណាចខាងវិន័យនិងបទបញ្ជាលើសមាជិករបស់ខ្លួន ។

ច្បាប់ក្នុងស្រុករបស់កម្ពុជាធានាឯករាជ្យភាពរបស់គណៈមេធាវីនិងរបស់សមាជិកខ្លួនដូចតទៅៈ

- «វិជ្ជាជីវៈផ្នែកច្បាប់គឺជាវិជ្ជាជីវៈស្វយ័ត និងឯករាជ្យដែលទាក់ទងនឹងការបម្រើយុត្តិធម៌...» (មាត្រា១ច្បាប់ស្តីពីគណៈមេធាវី) ។
- «ការប្រគល់តំណែងវិជ្ជាជីវៈត្រូវតែធានាឲ្យបាននូវការគោរពគោលការណ៍នៃភាពថ្លៃថ្នូរនិងឯករាជ្យភាព» (មាត្រា១នៃក្រមសីលធម៌) ។
- «គណៈមេធាវីនឹងមិនទទួលយក ឬទទួលស្គាល់បទបញ្ជាណាមួយពីគណបក្សនយោបាយឬពីអាជ្ញាធរនីតិបញ្ញត្តិឬអាជ្ញាធរនីតិប្រតិបត្តិដែលនៅក្រោមឱវាទនៃភាគីកម្ពុជាណាមួយ នៅក្នុងកិច្ចព្រមព្រៀងក្រុងប៉ារីស (មាត្រា៧១នៃច្បាប់អ៊ុនតាក់) ។

លើសពីនេះទៅទៀត ច្បាប់ក្នុងស្រុករបស់ប្រទេសកម្ពុជាបានចែងថាៈ

- មេធាវីមានសិទ្ធិបដិសេធ ឬទទួលយកសំណុំរឿងណាមួយដោយសេរី ប្រសិនបើគ្មានការចាត់តាំងពីប្រធាន ។
- មេធាវីចុងចោទមានសិទ្ធិត្រួតពិនិត្យមើលសំណុំរឿងរបស់ជនជាប់ចោទ ដោយគ្រាន់តែស្នើសុំជាលាយលក្ខណ៍អក្សរនៅគ្រប់ដំណាក់កាលនៃនីតិវិធី ហើយអាចទទួលបានពីចៅក្រមនូវគ្រប់លទ្ធផលដែលបានមកពីការស៊ើបអង្កេតអំពីសេចក្តីរាយការណ៍របស់អ្នកជំនាញការ ឬសវនកម្មដែលខ្លួនយល់ថាមានប្រយោជន៍ក្នុងការការពារកូនក្តីរបស់ខ្លួន ។
- មេធាវីចុងចោទមានសិទ្ធិទាក់ទងកូនក្តីរបស់ខ្លួនដែលជាប់ឃុំឃាំងដោយសេរី ។
- ការសន្ទនារវាងមេធាវីនិងកូនក្តីដែលកំពុងជាប់ឃុំ មិនត្រូវលួចស្តាប់ឬលួចថតទេ ។
- មេធាវីចុងចោទត្រូវតែទទួលបាននូវការជូនដំណឹងយ៉ាងហោចណាស់១៥ថ្ងៃ មុនថ្ងៃបើកសវនាការរបស់កូនក្តីខ្លួន ។

១) ច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញ

ទាក់ទងនឹងសិទ្ធិរបស់មេធាវីចុងចោទនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាគឺសំដៅទៅរកច្បាប់កម្ពុជាស្តីពីគណៈមេធាវី និងបទដ្ឋានដែលត្រូវបានទទួលស្គាល់ និងសីលធម៌របស់វិជ្ជាជីវៈផ្នែកច្បាប់ ។

បន្ថែមលើច្បាប់ក្នុងស្រុកដែលបានលើកឡើងនេះ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជានិងច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញមានខចែងដាច់ដោយឡែកស្តីពីបញ្ហាជាក់លាក់នៃឯករាជ្យភាពរបស់មេធាវីចុងចោទ ។

ទាក់ទងនឹងបញ្ហានៃឯករាជ្យភាពនេះ មាត្រា២១(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានចែងថា «មេធាវីរបស់ជនសង្ស័យឬជនជាប់ចោទដែលត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះវិសាមញ្ញថាជាមេធាវី នឹងមិនត្រូវបានដាក់ដោយរដ្ឋាភិបាលឲ្យស្ថិតនៅក្រោមវិធានការណាមួយដែលប៉ះពាល់ដល់ការអនុវត្តដោយឯករាជ្យនិងដោយសេរីនូវការងាររបស់មេធាវី នៅក្រោមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ» ។ មាត្រា៤២(៣) នៃច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញមានចែងពីមាត្រាដូចគ្នានេះ ។

## ឯករាជ្យភាពរបស់មេធាវីចុងចោទ

ឯករាជ្យភាពរបស់មេធាវីចុងចោទគឺជាខ្លឹមសារសំខាន់បំផុតនៅក្នុងការពិភាក្សាអំពីសិទ្ធិរបស់មេធាវីចុងចោទ ។ «ឯករាជ្យភាព» មានន័យថា ជាឯករាជ្យនៃវិជ្ជាជីវៈផ្នែកច្បាប់ដែលគ្រប់គ្រងដោយខ្លួនឯងនិង(មេធាវីបុគ្គល) ពីការគ្រប់គ្រងរបស់ចៅក្រមមន្ត្រីតុលាការ ព្រះរាជអាជ្ញា និងសមាជិករបស់រាជរដ្ឋាភិបាល ។ ដូច្នេះមេធាវីចុងចោទមិនគួរស្ថិតនៅក្រោមការដាក់កម្រិតឥទ្ធិពល ការដឹកនាំ ការគាបសង្កត់ ការគំរាមកំហែងឬការជ្រៀតជ្រែកដោយផ្ទាល់ឬមិនផ្ទាល់ពីផ្នែកណាមួយ ឬដោយមូលហេតុណាមួយ នោះទេ ។

នៅពេលតុលាការនិងព្រះរាជអាជ្ញានីមួយៗ ត្រូវបានគាំទ្រដោយអាជ្ញាធរមានអំណាចពីរបស់រដ្ឋ មេធាវីចុងចោទត្រូវបានគាំទ្រដោយគណៈមេធាវីឯករាជ្យនៅក្នុងយុត្តាធិការភាគច្រើន ហើយវាអាចជួយធានាថា មេធាវីចុងចោទត្រូវបានប្រព្រឹត្តដូចជាដៃគូស្មើភាពគ្នាមួយ នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ។

នៅក្នុងបរិបទនៃសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិ មេធាវីចុងចោទអន្តរជាតិ ជួនកាលត្រូវបានហាមប្រាមមិនធ្វើជាសមាជិកគណៈមេធាវីក្នុងស្រុក និងត្រូវបានដាក់ឲ្យនៅក្រៅការការពារ ។ ដើម្បីដោះស្រាយបញ្ហានេះ អ្នកផ្តល់យោបល់បានលើកឡើងអំពីការបង្កើតក្រុមការពារក្តីអចិន្ត្រៃយ៍ដែលមានពត៌មានច្បាស់លាស់និងទាន់ហេតុការណ៍ ។ ការបង្កើតក្រុមការពារក្តីអចិន្ត្រៃយ៍នឹងផ្តល់នូវប្រឆាំងតបតទៅនឹងព្រះរាជអាជ្ញា ។

ទាំងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជានិងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ បានបញ្ជាក់ច្បាស់អំពីសិទ្ធិដែលត្រូវផ្តល់ឲ្យទៅមេធាវីចុងចោទ ដើម្បីឲ្យពួកគេអនុវត្តកិច្ចការរបស់ពួកគេតាមរបៀបមួយដែលសេរីនិងឯករាជ្យ ។ សិទ្ធិទាំងនេះមានៈ

◆ អភ័យឯកសិទ្ធិឲ្យរួចផុតពីការចាប់ខ្លួនឬការជំនុំជម្រះទោសៈ មាត្រា២១(២)(ក) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា៤២(៣)(ក) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលចែងថា មេធាវីនឹងត្រូវ «ទទួលបានអភ័យឯកសិទ្ធិឲ្យរួចផុតពីការចាប់ខ្លួន ឬឃុំខ្លួន និងការរឹបអូសរបស់របរផ្ទាល់ខ្លួន ក្នុងក្របខ័ណ្ឌនៃការបំពេញភារកិច្ចរបស់ខ្លួនក្នុងរឿងក្តីនេះ» ។

◆ ការមិនអាចរំលោភបំពានលើឯកសារៈ មាត្រា២១(២)(ខ) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជានិងមាត្រា៤២(៣)(ខ) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលចែងថា មេធាវីត្រូវបានអនុញ្ញាតឲ្យមាននូវ «ភាពមិនអាចរំលោភបាននូវឯកសារទាំងអស់ដែលទាក់ទងដល់ការបំពេញមុខងាររបស់ខ្លួនជាមេធាវីរបស់ជនសង្ស័យ ឬជនជាប់ចោទ» ។

◆ អភ័យឯកសិទ្ធិឲ្យរួចផុតពីយុត្តាធិការរដ្ឋប្បវេណីនិងព្រហ្មទណ្ឌៈ មាត្រា២១(២)(គ) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជានិងមាត្រា៤២(៣)(គ) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដែលចែងថា មេធាវីនឹងត្រូវ «ទទួលបានអភ័យឯកសិទ្ធិឲ្យរួចផុតពីយុត្តាធិការរដ្ឋប្បវេណី និងព្រហ្មទណ្ឌចំពោះពាក្យពេចន៍ដែលបាននិយាយ ឬសរសេរនិងសកម្មភាពដែលបានបំពេញក្នុងតំណែងផ្លូវការរបស់គេក្នុងនាមជាមេធាវី» ។

## ឯករាជ្យភាពរបស់មេធាវីចុងចោទមានគ្រោះថ្នាក់នៅចំពោះមុខសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី

ខាងក្រោមនេះ គឺជាសេចក្តីដកស្រង់ចេញពីពាក្យសម្តីដំបូង

របស់មេធាវីចុងចោទរបស់ ឌុស្កូ ថេឌិក (Dusko Tadic) នៅក្នុងសំណុំរឿង ឌុស្កូ ថេឌិក ទល់នឹងព្រះរាជអាជ្ញា(Tadic v. Prosecutor) របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី (ICTY) សំណុំរឿងលេខ IT-94-1 នៅ៦៩ ។ សេចក្តីដកស្រង់នេះបានបង្ហាញអំពីរបៀបគំរាមកំហែងមិនផ្ទាល់ពីសហគមន៍ដែលអាចរារាំងដល់សិទ្ធិរបស់មេធាវីចុងចោទក្នុងការអនុវត្តកិច្ចការរបស់ខ្លួនដោយឯករាជ្យ ។

«នៅក្នុងការរៀបចំការការពារក្តី យើងបានតស៊ូជាមួយភាពប្រទូសរ៉ាយនិងការសង្ស័យដែលសាលាជំនុំជម្រះក្តីត្រូវបានមើលឃើញនៅក្នុងសាធារណរដ្ឋស៊ែប៊ី និងជាពិសេសនៅក្នុងតំបន់ព្រីដេឌ័រ...ការការពារក្តីរបស់ ឌុស្កូ ថេឌិក ត្រូវបានរៀបចំដោយមានជំនួយតិចតួច ឬគ្មានជំនួយទាល់តែសោះពីអាជ្ញាធរព្រីដេឌ័រ ហើយមានការប៉ុនប៉ងយ៉ាងសកម្មក្នុងការរារាំងយើងពីការស្វែងរកភស្តុតាងដែលបង្ហាញពីភាពបរិសុទ្ធរបស់កូនក្តីយើង ។ សាក្សីនៅក្នុងតំបន់នេះ ដែលនៅក្នុងការគ្រប់គ្រងរបស់ប៉ូលិស ឬទាហានត្រូវបានហាមឃាត់មិនឲ្យនិយាយរកមេធាវីចុងចោទ ។ មានការផ្សព្វផ្សាយពាក្យចចាមអារ៉ាមមិនត្រឹមត្រូវត្រូវអំពីគោលបំណងរបស់សាលាជំនុំជម្រះក្តីក្នុងការចាប់ខ្លួនអ្នកទាំងឡាយណាដែលហ៊ានចេញមុខប្រគល់ភស្តុតាង ។ សកម្មភាពរបស់យើងត្រូវបានគ្រប់គ្រងយ៉ាងជិតដល់បំផុត ហើយសាក្សីទាំងឡាយដែលត្រូវបានដឹងថា សហការណ៍ជាមួយយើងត្រូវទទួលរងនូវការគំរាមកំហែងចំពោះខ្លួនគាត់ផ្ទាល់និងចំពោះក្រុមគ្រួសារ ។ មន្ត្រីជាន់ខ្ពស់ម្នាក់បាននិយាយ ហើយខ្ញុំបានដកស្រង់សម្តីដូចខាងក្រោមនេះ «មិនមាននរណាម្នាក់អាចបញ្ជាខ្ញុំឲ្យអនុញ្ញាតឲ្យសាក្សីសម្រាប់មេធាវីចុងចោទអាចត្រូវបានស៊ើបអង្កេតនៅក្នុងតំបន់របស់ខ្ញុំទេ ។ គ្មានសាក្សីណាម្នាក់ពីតំបន់របស់ខ្ញុំអាចផ្តល់ចម្លើយដោយមិនមានការយល់ព្រមពីខ្ញុំទេ ។ ខ្ញុំអាចត្រូវបានដកចេញពីតំណែងរបស់ខ្ញុំ ប៉ុន្តែនៅក្នុងករណីនោះ ខ្ញុំនឹងកាត់តំបន់នេះទាំងមូលឲ្យទៅប្រទេសក្រូអាស៊ី ។ យើងមានដែកជាង៤លានតោននៅក្នុងស្តុកដែលយើងនឹងបញ្ជូនទៅកាន់ទីក្រុង (Sesak) ដើម្បីចំរាញ់ ហើយយើងនឹងបានលុយ» ។

### ៣) តួនាទីរបស់មេធាវីចុងចោទ

មេធាវីចុងចោទមានកាតព្វកិច្ចចំពោះកូនក្តីរបស់ខ្លួន និងតុលាការ ។ តួនាទីរបស់មេធាវីចុងចោទរួមមាន ថែរក្សាពត៏មានរវាងមេធាវីនិងកូនក្តីជាការសម្ងាត់ចៀសវាងទំនាស់ផលប្រយោជន៍ និងបំពេញការងារត្រឹមត្រូវចំពោះតុលាការ ។

ក) ច្បាប់កម្ពុជា

នៅក្រោមច្បាប់កម្ពុជាស្តីពីគណៈមេធាវីនិងក្រមសីលធម៌មេធាវីចុងចោទជាប់កាតព្វកិច្ចចំពោះកូនក្តីរបស់ខ្លួនដែលរួមមានៈ

- រក្សាពត៏មានដែលទាក់ទងនឹងសំណុំរឿងកូនក្តីជាសម្ងាត់
- គោរពឆន្ទៈរបស់កូនក្តី
- តំណាងផលប្រយោជន៍កូនក្តី
- ផ្តល់យោបល់ដល់កូនក្តី

មេធាវីចុងចោទជាប់កាតព្វកិច្ចចំពោះតុលាការដែលរួមមានៈ

- បង្ហាញពីការគោរពចំពោះចៅក្រមនិងតុលាការ
- គោរពគោលការណ៍សតិសម្បជញ្ញៈ ភាពជាមនុស្សនិងភាពសមរម្យ ។
- ធ្វើសកម្មភាពដោយស្របច្បាប់និងបទបញ្ជានិងក្រឹត្យក្រមវិន័យ ។ ◆ បញ្ឈប់ពីការជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តដែលមិនស្មោះត្រង់ និងរំខានជាពិសេសទាក់ទងនឹងការជំទាស់ ។

ប្រសិនបើមេធាវីរំលោភកាតព្វកិច្ចទាំងនេះ មេធាវីនោះត្រូវស្ថិតនៅក្រោមទណ្ឌកម្មវិន័យ ហើយគណៈមេធាវីអាចដាក់ទណ្ឌកម្មពីការព្រមានរហូតដល់ការលុបឈ្មោះចេញពីបញ្ជីគណៈមេធាវី ។

នៅក្នុងចំណោមកាតព្វកិច្ចដែលលើកឡើងនៅខាងលើ សហគមន៍ច្បាប់កម្ពុជាបានសង្កត់ធ្ងន់ទៅលើបញ្ហាថែរក្សាការសម្ងាត់ នៃបញ្ហាសំខាន់រវាងមេធាវីនិងកូនក្តីនិងទំនាស់ផលប្រយោជន៍ ។

### ការថែរក្សាការសម្ងាត់និងទំនាស់ផលប្រយោជន៍

មេធាវីជាប់កាតព្វកិច្ចស្មោះត្រង់ចំពោះកូនក្តីក៏ដូចជាចំពោះតុលាការ ។យុត្តាធិការរបស់ខមមិនឡ(Common Law Jurisdiction) យល់ថា កាតព្វកិច្ចស្មោះត្រង់មានប្រភពមកពីទំនាក់ទំនងកិច្ចសន្យារវាងមេធាវីនិងកូនក្តី ។ ភារកិច្ចរបស់មេធាវីអំពីការថែរក្សាការសម្ងាត់និងទំនាស់ផលប្រយោជន៍មានប្រភពនៅក្នុងគំនិតទាំង

នេះនៃកាតព្វកិច្ចស្មោះត្រង់របស់មេធាវីនិងទំនាក់ទំនងកិច្ចសន្យា ។

ការថែរក្សាការសម្ងាត់ៈ ប្រសិនបើគ្មានការអនុញ្ញាតពីកូនក្តីទេ មេធាវីត្រូវតែថែរក្សាការសម្ងាត់នូវរាល់កិច្ចការរបស់កូនក្តី ហើយមិនត្រូវបង្ហាញពត៌មានដែលទទួលបានទៅឲ្យមនុស្សផ្សេងទៀតទេ ។ មេធាវីមិនត្រូវប្រើប្រាស់ពត៌មានបែបនេះវាធ្វើខូចប្រយោជន៍របស់កូនក្តី ឬផលប្រយោជន៍របស់ខ្លួនឡើយ ។ មេធាវីចុងចោទត្រូវបានចងភ្ជាប់ទៅនឹងកាតព្វកិច្ចនេះនៅអំឡុងពេលនិងក្រោយពេលការពារក្តី ។

ទំនាស់ផលប្រយោជន៍ៈ មេធាវីគួរតែដាក់ផលប្រយោជន៍របស់កូនក្តីនិងរបស់តុលាការឲ្យធំជាងផលប្រយោជន៍របស់ខ្លួន ។ ប្រសិនបើមិនត្រូវបានអនុញ្ញាតដោយកូនក្តីទេ មេធាវីមិនត្រូវការពារក្តីឲ្យកូនក្តីទេ ប្រសិនបើផលប្រយោជន៍របស់មេធាវីទំនាស់ទៅនឹងផលប្រយោជន៍របស់កូនក្តី ។ មេធាវីមិនគួរទទួលយកឬបន្តការពារក្តីឲ្យកូនក្តីទេ ប្រសិនបើការការពារក្តីនេះនឹងឬអាចមានហេតុផលថាប៉ះពាល់ដល់ការការពារក្តីរបស់កូនក្តីផ្សេងទៀត ។

## ការថែរក្សាការសម្ងាត់

មាត្រា៥៨ នៃច្បាប់ស្តីពីគណៈមេធាវីបានបកស្រាយថា មេធាវី«ត្រូវថែរក្សាការសម្ងាត់» ហើយការសម្ងាត់មិនត្រូវមកប្រើប្រាស់ដោយមិនត្រឹមត្រូវ ឬត្រូវបានគេបង្ខំឲ្យប្រើប្រាស់ដោយមិនត្រឹមត្រូវដាដាច់ខាតសូម្បីតែនៅចំពោះមុខតុលាការ ។

ច្បាប់កម្ពុជាស្តីពីគណៈមេធាវីនិងក្រមសីលធម៌បានផ្តល់ឧទាហរណ៍អំពីពត៌មានសម្ងាត់និងពត៌មានមិនសម្ងាត់ដូចខាងក្រោមនេះ

*ពត៌មានសម្ងាត់ នៅក្នុងទំនាក់ទំនងរវាងមេធាវីនិងកូនក្តីៈ*

- *ការពិគ្រោះយោបល់*
- *យោបល់*
- *ឯកសារមិនផ្លូវការដែលរៀបចំដោយមេធាវីសម្រាប់កូនក្តី*
- *លិខិតឆ្លើយឆ្លងរវាងមេធាវីនិងកូនក្តី ។*

*(មាត្រា៥៨នៃច្បាប់គណៈមេធាវី)*

*ពត៌មានមិនសម្ងាត់នៅក្នុងទំនាក់ទំនងរវាងមេធាវីនិងកូនក្តីគ្មានកាតព្វកិច្ចនៃការថែរក្សាការសម្ងាត់ទេ នៅពេលដែលមេធាវីត្រូវតែឆ្លើយតបទៅនឹងបណ្តឹងរបស់កូនក្តី នៅក្នុងវិសាលនៃដែនកំណត់ដែលចាំបាច់សម្រាប់ការការពារក្តីរបស់ខ្លួន ។ (មាត្រា៧ នៃក្រមសីលធម៌)*

*ពត៌មានមិនសម្ងាត់ៈ*

- *សំបុត្រដែលប្រើជំនួសលិខិតនីតិវិធី*
- *សំបុត្រដែលមានដាក់ថា «ផ្លូវការ» ហើយដែលបញ្ជូនសេចក្តីស្នើណាមួយ ឬឯកសារមិនសម្ងាត់នានា ។*
- *ការប្តូរសំបុត្រគ្នាទៅវិញទៅមក ដែលមានដាក់ថា«ផ្លូវការ» ដើម្បីបង្ហាញបញ្ជាក់កិច្ចព្រមព្រៀងណាមួយ ឬការចុះហត្ថលេខានៃកិច្ចព្រមព្រៀងណាមួយរវាងមេធាវីនិងមេធាវី ក្នុងកម្រិតលក្ខខណ្ឌនៃអាណត្តិរបស់ខ្លួន ។*

## ទំនាស់ផលប្រយោជន៍

មាត្រា១៨ដល់មាត្រា២០នៃក្រមសីលធម៌ចែងថា មេធាវីគួរតែចៀសវាងទទួលយកសំណុំរឿងថ្មីទៀត ប្រសិនបើរឿងក្តីថ្មីនេះទំនាស់ទៅនឹងផលប្រយោជន៍របស់សំណុំរឿងដែលខ្លួនកំពុងតែកាន់ឬសំណុំរឿងមុនៗ ។ នៅក្នុងករណីបែបនោះ មេធាវីមានកាតព្វកិច្ចត្រូវតែប្រាប់ពត៌មានដល់កូនក្តីអំពីទំនាស់ផលប្រយោជន៍នេះ ។

- ទំនាក់ទំនងរវាងមេធាវីនិងកូនក្តីត្រូវតែជាទំនាក់ទំនងដោយចំពោះនិងផ្ទាល់ ។ មេធាវីអាចមិនទទួលរឿងក្តីណាមួយតាមរយៈតតិយជនបានឡើយ បើប្រសិនជាខ្លួនគ្មានសេរីភាពនឹងចូលទាក់ទងផ្ទាល់ជាមួយអតិថិជនដែលមានរឿងនោះបាន ។ (មាត្រា១៨ ក្រមសីលធម៌របស់មេធាវី)
- នៅពេលដែលមេធាវីត្រូវអតិថិជនច្រើនគ្នាពឹងពាក់ក្នុងរឿងក្តីតែមួយ ឬក្នុងការប្រតិបត្តិតែមួយដូចគ្នា មេធាវីមិនត្រូវកាន់ជើងនិងផ្តល់ផលប្រយោជន៍ឲ្យតែអតិថិជនណាមួយឡើយ ។ អ្វីៗត្រូវតែជូនដំណឹងទៅភាគីទាំងអស់គ្រប់គ្នា ។ មាត្រា១៩ (ក្រមសីលធម៌របស់មេធាវី)
- ក្នុងរឿងតុលាការ មេធាវីដែលបានផ្តល់យោបល់ ឬបានជួយ ឬបានតំណាងភាគីណាមួយមិនអាចទៅធ្វើអន្តរាគមន៍ជួយខាងគូប្រឆាំង ក្នុងរឿងក្តីដដែលឬក្នុងរឿងក្តី ដែលពាក់ព័ន្ធនឹង

រឿងក្ដីដែលបានឡើយ ។ នៅក្នុងគ្រប់រឿងក្ដីទាំងអស់ មេធាវីនឹងអាចធ្វើអន្តរាគមន៍ប្រឆាំងនឹងកូនក្ដីដែលខ្លួនធ្លាប់បានជួយពីលើកមុន បានតែក្នុងលក្ខខណ្ឌតឹងរ៉ឹងនៃការគោរពអាថ៌កំបាំងវិជ្ជាជីវៈ និងភាពគួរសមថ្លៃថ្នូរប៉ុណ្ណោះ ។ (មាត្រា២០ ក្រមសីលធម៌របស់មេធាវី)

◆ ប្រសិនបើរឿងនេះកើតឡើងមែនក្នុងពេលដែលមេធាវីជា ឬធ្លាប់ជាទីប្រឹក្សារបស់ភាគីច្រើនគ្នានោះ មេធាវីនឹងអាចទទួលការពារប្រយោជន៍ភាគីណាមួយបានលុះត្រាតែត្រូវជម្រាបទៅភាគីឯទៀតៗឲ្យបានដឹងសិន ហើយត្រូវប្រុងប្រយ័ត្នកុំឲ្យបាត់បង់នូវភាពគួរសមថ្លៃថ្នូរនិងអាថ៌កំបាំងវិជ្ជាជីវៈផង ។ (មាត្រា១៩ ក្រមសីលធម៌របស់មេធាវី)

១) ច្បាប់អង្គជំនុំជម្រះវិសាមញ្ញ

មាត្រា២១(៣) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ បានចែងថា មេធាវីចុងចោទត្រូវអនុវត្តតាម «កិច្ចព្រមព្រៀង ច្បាប់កម្ពុជាស្ដីពីលក្ខន្តិកៈមេធាវី បទដ្ឋាននិងសីលធម៌នៃវិជ្ជាជីវៈច្បាប់ដែលគេទទួលស្គាល់» ។ ដូច្នេះ ទាំងមេធាវីចុងចោទបរទេសនិងកម្ពុជា ត្រូវបានចងភ្ជាប់នៅក្នុងកាតព្វកិច្ចដែលបានលើកឡើងខាងលើនេះ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ។

## តួនាទីរបស់មេធាវីចំពោះសាក្សី

នៅចំពោះមុខសាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិពិសេស ដោយយោងទៅលើលក្ខណៈនៃការជជែកតវ៉ាគ្នារវាងព្រះរាជអាជ្ញានិងមេធាវី មេធាវីអាចសួរសំណួរខ្លាំងៗនៅអំឡុងពេលនៃការសាកសួរសាក្សីបដិបក្ខ ហើយអាចជាការធ្វើឲ្យប៉ះពាល់ផ្លូវចិត្តម្ដងទៀតដល់សាក្សី ។ អ្នកវិភាគបានយល់ឃើញថា ការអនុវត្តបែបនេះគឺមិនអាចទទួលយកបានទេ ។ មេធាវីចុងចោទជាប់កាតព្វកិច្ចយល់ដឹងអំពីបទពិសោធន៍ប៉ះពាល់ផ្លូវចិត្តរបស់សាក្សី ។ ការព្រួយបារម្ភបែបនេះ ជាពិសេសគឺមាននៅក្នុងរឿងក្ដីដែលទាក់ទងនឹងផ្លូវភេទ ។ ការដកស្រង់ពីអត្ថបទដែលសរសេរដោយអ្នកកាសែតជនជាតិអាមេរិក សាមន្ថា ផូវើរ បានពណ៌នាបទពិសោធន៍ដ៏ឈឺចាប់របស់ជនរងគ្រោះនៃអំពើរំលោភផ្លូវភេទជាមួយនឹងមេធាវីចុងចោទរបស់ ICTR នៅអំឡុងពេលនៃការសាកសួរសាក្សីចុងចោទ ។

«ម៉ារី ចូសេ ខាឃីត និងអ៊ីវ៉ាយេស៊ី គឺជាអ្នកដែលនៅរស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ ហើយឥឡូវនេះពួកគេនិយាយថា «អ្នករួចរស់ជីវិតពីសាលាជំនុំជម្រះក្ដី» ។

គាត់[អ៊ីវ៉ាយេស៊ី]បានប្រាប់តុលាការថា គាត់ត្រូវបានហ្គូហាត់វ៉ា គូ ផូហ្វូ [ពាក្យថា រំលោភរបស់រ៉ាន់ដា] ដែលបកប្រែដោយត្រង់ថា «ដោយប្រើកម្លាំង» ។ មេធាវីចុងចោទបានគ្របសង្កត់លើ[សាក្សី] ។ ដោយយោងទៅលើ អ៊ីវ៉ាយេស៊ី មេធាវីចុងចោទទាមទារចង់ដឹងឲ្យបានពិតប្រាកដថា តើគាត់មានន័យយ៉ាងម៉េចពេលនិយាយថា«រំលោភ»? គាត់បានរំឭកថា «ខ្ញុំបានប្រាប់ពួកគេ[មេធាវី]ថា បុរសនោះបានយកប្រដាប់របស់គេមកដាក់នៅក្នុងប្រដាប់របស់ខ្ញុំ ។ ប៉ុន្តែពួកគេ[មេធាវី]ថាប៉ុណ្ណឹងមិនទាន់គ្រប់គ្រាន់ទេ ។ ពួកគេចង់ឲ្យខ្ញុំប្រើប្រាស់ពាក្យឲ្យត្រូវ ។ ប៉ុន្តែខ្ញុំមិនអាចប្រើពាក្យនោះទេ ។ គ្រប់ៗគ្នាដឹងថាអ្វីជាការរំលោភហើយ ប៉ុន្តែពួកគេទាមទារឲ្យបានពិស្ដារថែមទៀត ។ ប៉ុន្តែខ្ញុំពិតជាមិនអាច...» ។

... ខាឃីត ដែលពិភាក្សាអំពីបទពិសោធន៍របស់គាត់ពេលផ្ដល់សក្ខីកម្មនៅក្នុងតុលាការ ICTR បាននិយាយថា «ពួកគេ[មេធាវី]បានសួរខ្ញុំថា តើខ្ញុំចង់និយាយថាម៉េចពេលដែលខ្ញុំនិយាយអំពីពាក្យថារំលោភ? គាត់ឆ្លើយថា«ខ្ញុំមិនដឹងធ្វើអ្វីទេ នៅពេលឮសំណួរបែបនេះ ។ ខ្ញុំងាកមើលឆ្វេងស្ដាំរកជំនួយ ។ វាមិនមែនជាអ្វីដែលអ្នកតែងតែធ្វើជាទម្លាប់នៅក្នុងវប្បធម៌របស់រ៉ាន់ដានោះទេ ។ ពួកគេបានសួរខ្ញុំថាតើវាមានន័យថា បុរសយកអង្គជាតិរបស់គេមកដាក់បញ្ចូលនៅក្នុងយោនីរបស់ស្ត្រីមែនឬទេ? ខ្ញុំងក់ក្បាលយល់ស្រប ។ ពួកគេនិយាយថា ខ្ញុំត្រូវតែថាតាមពួកគេ ។ ខ្ញុំក៏ថាតាមពួកគេ ។ ប៉ុន្តែខ្ញុំបានចាប់ផ្ដើមយំដោយសារការអាម៉ាស់ ។ សម្រាប់នារីជនជាតិរ៉ាន់ដាក្នុងការប្រើប្រាស់ពាក្យសម្ដីបែបនេះអ្នកមិនដឹងទេះ វាគឺអាក្រក់អាក្រីណាស់» ។

**ឯកសារហ្វឹកហ្វឺនច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា**

# សារសំខាន់នៃការរៀបចំសាក្សី និងការស្វែងយល់ផ្លូវច្បាប់ សម្រាប់សាលាជម្រះក្តីខ្មែរក្រហម

គម្រោង«ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម»បានផ្តល់សេវាកម្មដ៏មានសារសំខាន់ឲ្យដល់មនុស្សជាច្រើនដែលទទួលរងនូវការប៉ះទង្គិចផ្លូវចិត្តបណ្តាលមកពីរបបខ្មែរក្រហម ។ ក្រៅតែពីកំណត់អត្តសញ្ញាណនិងព្យាបាលអ្នករស់រានមានជីវិតទាំងអស់នោះដែលមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរព្រមទាំងរោគសញ្ញាធ្ងន់ធ្ងរ ។ គម្រោង «ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម» ក៏ស្វែងយល់ពីទស្សនៈជនរងគ្រោះស្តីពីការចងចាំនិងភាពយុត្តិធម៌និងការជំរុញឲ្យមានការផ្សះផ្សានៅតាមសហគមន៍នៅក្នុងប្រទេសកម្ពុជា ។ សារសំខាន់មួយរបស់គម្រោង «ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម» គឺងាយនឹងធ្វើឲ្យអ្នករស់រានមានជីវិតទទួលនូវការប៉ះទង្គិចផ្លូវចិត្តឡើងវិញ ក្នុងអំឡុងពេលធ្វើសម្ភាសន៍ ។ ក្នុងពេលធ្វើសម្ភាសន៍បុគ្គលិករបស់គម្រោង «ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម» បានខិតខំប្រឹងប្រែងកាត់បន្ថយឱកាសដែលនាំឲ្យជនរងគ្រោះប៉ះទង្គិចផ្លូវចិត្តឡើងវិញ តាមរយៈការចុះទៅសួរសុខទុក្ខអ្នកផ្តល់សម្ភាសន៍នៅផ្ទះគាត់និងបង្កើតភាពស្និទ្ធស្នាលជាមួយអ្នកផ្តល់សម្ភាសន៍បង្កើតបរិយាកាសជឿទុកចិត្តគ្នានិងចែករំលែកនូវការព្រួយបារម្ភពិតប្រាកដ ។ បុគ្គលិករបស់គម្រោង«ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម» មិនបានចោទសួរឬពិនិត្យពិចារណាទៅលើរឿងរ៉ាវរបស់អ្នកផ្តល់សម្ភាសន៍ទេ ផ្ទុយទៅវិញគឺទទួលយករឿងរ៉ាវទាំងអស់នោះមកក្នុងលក្ខណៈជាការរៀបរាប់ប្រាប់ដ៏ត្រឹមត្រូវពីបទពិសោធន៍របស់អ្នកទាំងអស់នោះវិញ ។

អ្នករស់រានមានជីវិតទាំងអស់នៅនឹងចូលខ្លួនធ្វើជាកសិណសាក្សី នៅក្នុងសាលាជម្រះក្តីខ្មែរក្រហមនាពេលខាងមុខ ប៉ុន្តែបរិយាកាសជុំវិញនៃការចូលរួមរបស់អ្នកទាំងអស់នោះនឹងមិនសូវមានស្ថានភាពល្អប៉ុន្មានទេ ។ ទីមួយសាក្សីនឹងផ្តល់កសិណនៅក្នុងតុលាការដោយមានវត្តមានចុងចោទផង ហើយបរិយាកាសនេះអាចជាបរិយាកាសបំភិតបំភ័យមួយ ។ ទោះបីជារាជរដ្ឋាភិបាលបានអះអាងថា សាក្សីនឹងទទួលបាននូវការការពារពិសេសមួយក៏ដោយក៏បទដ្ឋានសមស្របអន្តរជាតិនានាបានជំរុញមិនឲ្យមានការផ្តល់កសិណដែលលាក់អត្តសញ្ញាណទាំងស្រុងនោះទេ ដែលប្រការនេះបង្កឲ្យមានការព្រួយបារម្ភពីសុវត្ថិភាពសាក្សីដោយថាហេតុដែលអាចមានពិតប្រាកដឬអាចដឹងជាមុនបាន ។ លើសពីនេះទៀត មេធាវីមានសិទ្ធិសួរដេញដោលសាក្សីបដិបក្ខ ហើយព្យាយាមធ្វើយ៉ាងណាឲ្យចម្លើយសាក្សីបដិបក្ខនោះមិនអាចប្រើការបាននៅក្នុងតុលាការ ។ មេធាវីនឹងផ្តោតការយកចិត្តទុកដាក់ទៅលើចំណុចខ្វះចន្លោះនិងភាពមិនស៊ីសង្វាក់គ្នាដោយថាហេតុនៅក្នុងចម្លើយរបស់កសិណសាក្សី ហើយចៅក្រមនឹងវិភាគរាល់កាយវិការនិងឥរិយាបថរបស់សាក្សីទៀត ។ ផ្ទុយទៅវិញ សាក្សីមិនត្រឹមតែមិនបានផ្តល់នូវការយោគយល់ទេ មេធាវីថែមទាំងបានប្រើប្រាស់ការប៉ះទង្គិចផ្លូវចិត្តរបស់សាក្សី ដើម្បីបង្ខូចដល់សេចក្តីទុកចិត្តទៅលើចម្លើយកសិណ ហើយអាចនាំឲ្យសាក្សីមិនសប្បាយចិត្តដែលក្លាយជាជនរងគ្រោះសាជាថ្មីម្តងទៀត ។

សៀវភៅណែនាំបណ្តុះបណ្តាលផ្នែកផ្លូវច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានដកស្រង់អត្ថបទសរសេរដោយ សាម៉ានថា ជូរីពិពណ៌នាអំពីរបៀបដែលសាក្សីនៅក្នុងសាលាជំនុំជម្រះក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសវ៉ាន់ដា ត្រូវបានប្រព្រឹត្តមិនសមរម្យមកលើសាក្សី ជាពិសេសទាក់ទងទៅនឹងបទល្មើសនៃអំពើហិង្សាខាងផ្លូវភេទដែលមនុស្សជាច្រើនចាត់ទុកសាក្សីទាំងនោះថាជា «អ្នករស់រានមានជីវិតរបស់សាលាជំនុំជម្រះក្តី» ។

ជាលទ្ធផល សាក្សីនៅក្នុងសាលាជំនុំជម្រះក្តីនាពេលខាងមុខនេះត្រូវការរៀបចំឲ្យបានល្អមុនពេលឡើងឆ្លើយ ។ ការគ្រប់គ្រងអារម្មណ៍របស់ជនរងគ្រោះទៅលើបទពិសោធន៍ផ្ទាល់មានសារសំខាន់ក្នុងការចៀសវាងធ្វើឲ្យមានប៉ះទង្គិចផ្លូវចិត្តឡើងវិញ ។ ការត្រៀម

រៀបចំសាក្សីកាន់តែបានល្អទាក់ទងទៅនឹង ១)ដំណើរការផ្លូវច្បាប់នាពេលខាងមុខ និង ២) ការរំពុកឡើងវិញ និងការអធិប្បាយពីបទពិសោធន៍ប៉ះទង្គិចផ្លូវចិត្ត ការផ្តល់ចម្លើយកសិណនឹងកាន់តែមានប្រសិទ្ធភាព ហើយឱកាសនៃការធ្វើឲ្យប៉ះទង្គិចផ្លូវចិត្តសាជាថ្មីមានតិចតួច ។

ជាបឋម មេធាវីគួរតែប្រឹងប្រែងឲ្យអស់ពីសមត្ថភាពដើម្បីបន្សាំសាក្សីទៅនឹងដំណើរការផ្លូវច្បាប់នៅមុនពេលសាក្សីផ្តល់ចម្លើយពិតប្រាកដនៅក្នុងតុលាការ ។ ប្រការនេះរាប់បញ្ចូលទាំងការពិភាក្សាពីកាលបរិច្ឆេទនៃហេតុការណ៍នីមួយៗដែលនឹងកើតឡើង គោលបំណងនៃការផ្តល់ចម្លើយកសិណ តួនាទីរបស់ចៅក្រមនិងតួនាទីរបស់មេធាវីចុងចោទ ។ បន្សាំជាមួយនឹងមជ្ឈដ្ឋានជុំវិញឲ្យបានកាន់តែច្រើនប្រសិនបើអាច សាក្សីគួរតែទៅទស្សនាបន្ទប់តុលាការ អង្គុយកៅអីសាក្សី និងបង្ហាញអំពីទីតាំងផ្សេងៗដែលអ្នកផ្សេងទៀតអង្គុយ ហើយនរណាខ្លះដែលនឹងចូលរួម ។

សាក្សីគួរតែត្រូវបានផ្តល់នូវការពន្យល់យ៉ាងល្អិតល្អន់អំពីគ្រោះថ្នាក់និងដំណើរការដែលពាក់ព័ន្ធនឹងការផ្តល់ចម្លើយរបស់ខ្លួនជាពិសេសពាក់ព័ន្ធនឹងសក្តានុពលនៃការចោទសួរក្នុងន័យវាយប្រហារឬប្រទូសរ៉ាយក្នុងពេលមេធាវីសួរដេញដោល ។ ឧទាហរណ៍ មេធាវីចុងចោទត្រូវបានអនុញ្ញាតឲ្យ «សួរសំណួរនាំមុខ»សាក្សី ដែលការចោទសួរបង្ហាញថាជាការចម្លើយមួយក្នុងគំនិតសង្ឃឹមថាសាក្សីឆ្លើយតាម ជាជាងប្រឈមមុខដាក់គ្នា ។ បរិយាកាសទាំងអស់នេះគឺជាការបំភិតបំភ័យដល់សាក្សី ដូច្នេះសាក្សីនឹងយល់ស្របតាមពាក្យសម្តីរបស់មេធាវីចុងចោទ (សួរមានលក្ខណៈជាសំណួរ) ជាជាងបន្តជម្លោះ ។ ទង្វើនេះអាចធ្វើឲ្យខូចដល់រឿងរ៉ាវជាក់លាក់របស់សាក្សីដោយសារតែរឿងនោះ ត្រូវបានធ្វើឲ្យល្អៀងព្រោះតែសម្តីរបស់មេធាវីការពារចុងចោទ ។ ការដែលនិយាយថារឿងរ៉ាវនិងបទពិសោធន៍របស់សាក្សី «និយាយចេញមកមិនត្រឹមត្រូវ» គឺជាអំពើអសីលធម៌យ៉ាងខ្លាំងនិងបន្តការប៉ះទង្គិចផ្លូវចិត្តដល់សាក្សីនិងជាកត្តារួមចំណែកដល់ជនរងគ្រោះបន្តទៀត ។

ជាងនេះទៅទៀត មេធាវីចុងចោទចេះតែចង់និយាយបន្ទុចបន្ទាក់និងកាត់សម្តីសាក្សីនៅពាក់កណ្តាលឃ្លានៅពេលមេធាវីមិនពេញចិត្តទិសដៅដែលចម្លើយកសិណត្រូវបាននាំមុខនោះ ។ សាក្សីត្រូវការប្រាប់ឲ្យដឹងជាមុនថា នៅពេលសួរសំណួរសាក្សីមានសិទ្ធិឆ្លើយសំណួរទាំងស្រុង ដោយគ្មានការបង្អាក់និងមិនគួរទុកឲ្យភាពទន់ភ្លន់ពីធម្មជាតិ និងការប៉ុងប៉ងបំភិតបំភ័យរបស់មេធាវីរារាំងមិនឲ្យសាក្សីប្រាប់ហេតុការណ៍ទាំងស្រុងរបស់ខ្លួនឡើយ ។ សាក្សីគួរតែត្រៀមខ្លួនដើម្បីជម្នះក្នុងការបញ្ចប់ចម្លើយរបស់ខ្លួន ទោះបីជាផ្ទុយពីការប៉ុនប៉ងពីមេធាវីចុងចោទក្នុងការបញ្ឈប់ខ្លួនក៏ដោយ ។ រឿងមួយគួរកត់សម្គាល់នោះគឺសាក្សីដែលត្រូវបានធ្វើទារុណកម្មដោយខ្មែរក្រហមក្នុងពេលសួរចម្លើយក៏អាចត្រូវការអន្តរាគមន៍ខាងផ្លូវចិត្តដ៏ចាំបាច់មួយដើម្បីកាត់បន្ថយឱកាសឈានទៅរកការប៉ះទង្គិចផ្លូវចិត្តម្តងទៀតដោយសារតែមេធាវីចុងចោទមានចិត្តក្រេវក្រោធ ។ ការត្រៀមរៀបចំដោយក្រុមប្រឹក្សាច្បាប់និងចិត្តសាស្ត្រដើម្បីជួយឲ្យសាក្សីទប់ទល់នឹងប្រភេទសំណួរនោះគឺមានសារសំខាន់សម្រាប់ភាពប្រាកដប្រជាចំពោះចម្លើយនិងសុខុមាលភាពរបស់សាក្សីទៀតផង ។

ទីពីរ មេធាវីខាងសាក្សីគួរតែធានាឲ្យប្រាកដថា ដោយពិនិត្យមើលទៅលើរយៈពេលជាង២៥ឆ្នាំចាប់តាំងពីពេលបញ្ចប់អំពើប្រល័យពូជសាសន៍មក រឿងរ៉ាវរបស់សាក្សីដែលមានភាពប្រទាក់ក្រឡាគ្នាគឺគ្រប់គ្រាន់ល្មមអាចឲ្យលើកយកមកបង្ហាញបានក្រោមការពិនិត្យពិច័យដ៏ហ្មត់ចត់មួយ ។ ឧទាហរណ៍សមត្ថភាពរបស់ជនរងគ្រោះចាំហេតុការណ៍ប្រហែលជាមិនអាចបរិយាយចេញមកក្នុងលក្ខណៈហូរហែដែលអាចមិនទទួលយកបាននៅក្នុងដំណើរផ្លូវការតាមប្រពៃណីបានទេ ។ ស្ថិតក្នុងបរិបទធំធេងជាងមុន កាលបរិច្ឆេទជាក់លាក់មិនសូវសំខាន់ចំពោះសាក្សីដូចបទពិសោធន៍ដែលខ្លួនគាត់ឆ្លងកាត់ដោយផ្ទាល់នោះទេ ។ ជាថ្មីម្តងទៀត លក្ខណៈព្យាបាល ឬការរៀបចំអាចត្រូវការចាំបាច់ក្នុងករណីខ្លះ ដើម្បីប្រែក្លាយបទពិសោធន៍ឲ្យទៅជាការអត្ថាធិប្បាយដែលសមស្របទៅតាមដំណើរការផ្លូវច្បាប់ដូចជាការផ្តល់ចម្លើយរបស់សាក្សី ដែលមានលក្ខណៈស្របគ្នា មិននិយាយស្មាន និងមានសក្តានុពលខ្លាំង ។

«ការអត្ថាធិប្បាយរបស់មនុស្សម្នាក់ដែលទទួលរងនូវការប៉ះទង្គិចខាងផ្លូវចិត្តកាលនៅជាយុវវ័យមានលក្ខណៈបែកខ្ញែកនិងមិនគ្រប់ជ្រុងជ្រោយ ។ ការអត្ថាធិប្បាយជារឿយៗបានបង្ហាញឲ្យ

ឃើញពីការភ្លាំងភ្លេចក្នុងពេលពិនិត្យទៅលើហេតុផលទាំងឡាយ ដូចជា កង្វះភាពសមហេតុផល ឬកង្វះការជឿទុកចិត្តបានការសាកល្បងនៅពេលធ្វើការពិភាក្សាអំពីជំងឺប៉ះទង្គិចផ្លូវចិត្ត ការភ្លេចភ្លាំងក្នុងពេលនិយាយក៏ជាលក្ខណៈកត់សម្គាល់ដែរ ដូចជា នៅស្ងៀមស្ងាត់យូរ ការផ្តោតទៅលើសេចក្តីពិស្តារឬនិយាយប្រយោគមិនពេញលេញ....ការប្រែក្លាយជំងឺប៉ះទង្គិចផ្លូវចិត្តឲ្យទៅជាបទអត្ថាធិប្បាយប្រកបដោយការប្រទាក់ក្រឡាគ្នាមានន័យស្មើនឹងការទប់ទល់ខាងចុងចោទ ដូចជាភាពស្ពឹកស្រពន់ខាងផ្លូវចិត្តអារម្មណ៍បែកខ្ញែកដោយសារតែសាច់រឿងទាំងនោះ ការភ្លាំងភ្លេចមួយចំនួន ឬមិនមូលអារម្មណ៍ ។ ជាដំបូងប្រការនេះទំនងជាមានភាពជុំយគ្នាយ៉ាងច្បាស់ក្នុងការចៀសវាងនូវការចងចាំទាក់ទងនឹងការប៉ះទង្គិចផ្លូវចិត្ត ។ ដូច្នេះគ្រូពេទ្យចិត្តសាស្ត្រត្រូវតែ «តំណាងឲ្យអ្នកជំងឺដែលមិនអាចទ្រាំសម្លឹងមើលអ្វីដែលធ្វើមកលើរូបអ្នកជំងឺនោះឡើយ» ។ នៅទីបញ្ចប់អ្នកជំងឺប៉ះទង្គិចផ្លូវចិត្តអាចមានលទ្ធភាពប្រមូលផ្តុំសាច់រឿងដែលបែកខ្ញែកឲ្យទៅជាការរៀបរាប់ប្រកបដោយភាពប្រទាក់ក្រឡាគ្នាស្តីអំពីបទពិសោធន៍កន្លងទៅ ។» (វ៉ាន ឌឺជ) ។

ជាលទ្ធផលក្រៅពីការរៀបចំខាងផ្លូវចិត្តសាស្ត្រ មេធាវីខាងសាក្សីគួរតែផាត់ចោលនូវការចងចាំដែលស្រពេចស្រពិលឬភាពមិនស្របគ្នាជាដើម ។ ជាការប្រសើរសម្រាប់សាក្សីក្នុងការនិយាយដោយត្រង់ៗថា «ខ្ញុំមិនអាចចាំបានទេ» ជាជាងនិយាយស្មានៗ ។ ការណ៍នេះនឹងជួយពង្រឹងស្ថានភាពពិតស្តីពីអ្វីដែលអាចនៅចាំបាននិងបន្ថយជាអប្បបរិមានូវការនិយាយខុសដោយផ្អែកលើការចងចាំខុសដែលមេធាវីចុងចោទអាចវាយប្រហារដើម្បីចោទប្រកាន់ពីភាពមិនអាចជឿជាក់បានទាំងស្រុងទៅលើសាក្សី ។ ជារឿយៗ ការចោទប្រកាន់ទៅលើរឿងមិនសំខាន់អាចធ្វើឲ្យមានការភ័ន្តច្រឡំនិងធ្វើឲ្យសាក្សីមិនសប្បាយចិត្ត ហើយទុកឲ្យសាក្សីមានអារម្មណ៍ដូចជាខ្លួនជាមនុស្សដែលកំពុងត្រូវបានជំនុំជម្រះទោស ។

ក៏ប៉ុន្តែ«ការបង្គាប់សាក្សីឲ្យនិយាយ»ឬបង្ហាត់បង្ហាញពីហេតុការណ៍ពិតប្រាកដគួរត្រូវហាមឃាត់ដាច់ខាត ភាពតានតឹងផ្លូវចិត្តនិងការភ័យខ្លាចដែលធ្វើឲ្យខូចដល់សភាពការណ៍និងសាច់រឿងផ្សេងៗទៀត នាំឲ្យសាក្សីជាច្រើនផ្តល់ចម្លើយតែមួយឃ្លាខ្លីដែលមិនបង្ហាញពីបទពិសោធន៍ល្អិតល្អន់របស់សាក្សីឡើយ ព្រមទាំងធ្វើឲ្យមានភាពធ្ងន់ធ្ងរថែមទៀតនូវការឈឺចាប់ខាងរាងកាយផ្លូវចិត្ត និងផ្លូវអារម្មណ៍ទៀតផង ។ ជារួមមានរឿងច្រើនមិនបាននិយាយចេញដើម្បីជាការឆ្លើយតបទៅនឹងសំណួរនីមួយៗ ។ ដូចជាមេធាវី «ជាមិត្ត»របស់សាក្សីគួរតែដឹងអំពីពត៌មានសំខាន់ៗដែលសាក្សីមាននិងគួរតែសួរសំណួរបំពេញបន្ថែមតាមរយៈការពិភាក្សាគ្នាមុនជាមួយសាក្សី ដើម្បីឲ្យសាក្សីអាចផ្តល់ចម្លើយដោយមិនចាំបាច់មានមេធាវីជួយ ។ មេធាវីគួរតែផ្តល់តារាងចំណុចពត៌មានដែលទទួលបានពីសាក្សី ហើយបន្តសួរសំណួររហូតដល់សាក្សីផ្តល់ពត៌មានបានពេញលេញ ។ ដំណើរការនៃការទទួលសាច់រឿងពេញលេញពីសាក្សីអាចមានការលំបាកដូចបាននិយាយពីខាងលើមក ក៏ប៉ុន្តែវាជាតួនាទីរបស់មេធាវីក្នុងការដឹងជាមុនថា នៅពេលណាសាច់រឿងរបស់សាក្សីនិយាយចេញមកអស់ ។ ជាគោលដៅរបស់មេធាវីដែលនាំឲ្យសាក្សីមានអារម្មណ៍ថា នៅទីបញ្ចប់គាត់បានប្រាប់រឿងរ៉ាវរបស់គាត់ឲ្យអ្នកផ្សេងបានដឹងនិងចាប់ផ្តើមទទួលបាននូវភាពស្របច្បាប់មួយចំនួននិងការបញ្ឈប់រឿងរ៉ាវទាំងនោះ ។ ការស្តាប់ស្ងៀមសាក្សីនៅពេលដែលគាត់កំពុងនិយាយរំពុកដើម្បីត្រៀមផ្តល់ចម្លើយ អាចពង្រឹងអង្គហេតុសំខាន់ៗពីសាក្សីដែលធ្វើឲ្យចម្លើយកសិណសម្រាប់សាលាជម្រះក្តីចុងក្រោយមានលក្ខណៈហូរហែនិងធម្មតា ព្រមទាំងអាចធ្វើឲ្យបទពិសោធន៍ឈឺចាប់របស់គាត់មិនសូវមានការប៉ះទង្គិចខ្លាំង ។ ជាថ្មីម្តងទៀត ទង្វើទាំងអស់នេះគួរតែធ្វើឡើងដោយមានវត្តមានអ្នកឯកទេសផ្លូវចិត្តដើម្បីកាត់បន្ថយឱកាសដែលនាំឲ្យមានការប៉ះទង្គិចផ្លូវចិត្តឡើងវិញ ។

វគ្គបណ្តុះបណ្តាលសម្រាប់មេធាវីនិងចៅក្រមមានតួនាទីនៅក្នុងសាលាជម្រះក្តីស្រដៀងគ្នានឹងវគ្គបណ្តុះបណ្តាលផ្នែកច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលអាចជាមធ្យោបាយមួយដើម្បីជំរុញការយល់យោគនេះ ។ ខ្ញុំបាននិយាយជាមួយ ហេលីន ហើយ ហេលីន បាននិយាយថាគាត់បានចូលរួមវគ្គ

បណ្តុះបណ្តាលនៅកូសូវ៉ូដែលធ្វើឡើងដើម្បីណែនាំចៅក្រមនិងមេធាវីអំពីរបៀបសម្ភាសន៍ជនរងគ្រោះនៃអំពើការរត់ពន្ធ ។ វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំឡើងតែនៅពេលព្រឹកប៉ុណ្ណោះ ដែលទំនងជាមានរយៈពេលខ្លីពេកសម្រាប់អ្នកចូលរួមឲ្យយល់ជ្រួតជ្រាបបានល្អ ។ ខ្ញុំក៏បានយល់ស្របការលើកឡើងរបស់ហេលីន ដែរថារាល់វគ្គបណ្តុះបណ្តាលបែបនេះគួរតែរៀបចំឡើងឲ្យច្រើនវគ្គដើម្បីឲ្យអ្នកចូលរួមអាចយល់ដឹងច្បាស់បានយូរអង្វែងសម្រាប់ភាពឆាប់ងាយទទួលរងបញ្ហារបស់សាក្សីដែលមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ ។ ខ្ញុំមិនបានលើកយកមកបង្ហាញអ្វីៗដែលមានលក្ខណៈស្មុគស្មាញពេកទេ ប៉ុន្តែក្រៅតែពីការពិនិត្យទៅលើឥទ្ធិពលជំងឺប៉ះទង្គិចផ្លូវចិត្តដែលបាននិយាយច្រើនដងរួចមក ហើយដើម្បីឲ្យអ្នកចូលរួមបានយល់ច្បាស់អំពីបញ្ហានេះ ។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំមិនមែនជាអ្នកឯកទេសទេ ហើយក៏ខ្ញុំមិនរំពឹងថាអាចផ្តល់សំណើលម្អិតពាក់ព័ន្ធទៅនឹងបញ្ហាទាំងនេះទេ ។ ខ្ញុំគ្រាន់តែលើកឡើងអំពីសភាពទូទៅរបស់អ្នកទាំងអស់នោះប៉ុណ្ណោះ ។ ខ្ញុំមិនបានដឹងអំពីវគ្គបណ្តុះបណ្តាលស្រដៀងៗគ្នានេះនៅក្នុងប្រទេសកម្ពុជាឬនៅកន្លែងផ្សេងៗទៀតឡើយ ក៏ប៉ុន្តែប្រសិនបើមានគុណប្រយោជន៍ច្រើនក្នុងកិច្ចការនេះ ខ្ញុំប្រាកដជាសប្បាយចិត្តក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះបន្ថែមទៀត ។

នៅទីបញ្ចប់ សំណើរបស់ខ្ញុំចែកចេញជាពីរផ្នែក÷ ទី១ កម្មវិធីត្រៀមរៀបចំសាក្សីឲ្យបានហ្មត់ចត់ ដែលអ្នកឯកទេសចិត្តសាស្ត្រសហការជាមួយមេធាវីដើម្បីរៀបចំសាក្សីប្រកបដោយប្រសិទ្ធភាពសម្រាប់ការជំនុំជម្រះក្តីនិងការសួរដេញដោល ។ ទី២ វគ្គបណ្តុះបណ្តាលចៅក្រម មេធាវី ហើយអាចជាសមាជិកអ្នកសារព័ត៌មានដែរ ដែលសំដៅលើកកម្ពស់ការយល់ដឹងរបស់ចៅក្រមនិងមេធាវីនៅក្នុងសាលាជម្រះក្តីខ្មែរក្រហមទាក់ទងទៅនឹងឥទ្ធិពលនៃការប៉ះទង្គិចផ្លូវចិត្តទៅលើសាក្សីនិងលទ្ធភាពនៃការធ្វើឲ្យប៉ះទង្គិចផ្លូវចិត្តសាជាថ្មីនៅក្នុងដំណើការផ្លូវច្បាប់ ។ ទោះបីជាការត្រៀមរៀបចំសាក្សីត្រូវបានចាត់ទុកថាជាធាតុចាំបាច់ក្នុងដំណើរការកាត់សេចក្តីនានាក៏ដោយ ប៉ុន្តែបញ្ហាថាតើវាគ្រប់គ្រាន់ដែរឬទេ ប្រសិនបើពិនិត្យមើលអំពីសំណួរចោទឡើងជុំវិញបទដ្ឋានប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជា ។ សាក្សីបានប្រទះហេតុការណ៍ច្រើនពេកណាស់ទៅហើយរហូតដល់មិនចង់ធ្វើការលះបង់ណាមួយបន្ថែមទៀតសម្រាប់សាលាជម្រះក្តីមួយនេះទេ ។ ខ្ញុំជឿជាក់ថាស្ថាប័នមួយដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជាអាចលើកទឹកចិត្តឬបញ្ចុះបញ្ចូលឲ្យមានកម្មវិធីផ្លូវការនិងគ្រប់ជ្រុងជ្រោយ ដែលនឹងធានាបានកម្រិតខ្ពស់នៃការការពារសុខុមាលភាពខាងរាងកាយនិងផ្លូវចិត្តរបស់សាក្សី ។ ខ្ញុំយល់ថា ការពិតអាចកម្រិតសក្តានុពលសម្រាប់កម្មវិធីបែបនេះបាន ក៏ប៉ុន្តែខ្ញុំជឿថាសូម្បីតែកម្មវិធីតូចៗក៏អាចមានឥទ្ធិពលធំធេងសម្រាប់ជីវិតរបស់សាក្សីទាំងអស់នោះ ដែលឈ្មោះអ្នកទាំងអស់នោះសាលាជម្រះក្តីបានបង្កើតឡើងមួយផ្នែកដែរ ។

**ម័រហ្គិន ខាយរេថឺ**

# ពន្យល់ពាក្យខ្មែរក្រហម

◆ ***យោធាបដិវត្តល្អ៖*** *យោធាដែលបំពេញភារកិច្ចគ្រប់មុខបានល្អដោយគ្មានលក្ខខណ្ឌ ពេលមាន ពេលអត់ ពេលស្រួល ពេលលំបាក ពេលឈ្នះ ពេលចាញ់ជាបណ្តោះអាសន្ន ពេលឈ្នះទាំងស្រុង ចូលទីក្រុង ក៏គ្មានលក្ខខណ្ឌ ។*

*(កំណត់ហេតុលេខ១០៨)*

◆ ***ធាតុពិតជាប់ជិតស្និទ្ធនឹងមហាជន៖*** *មានមហាជននៅជាមួយបក្ស ។ គណៈកម្មាធិការបក្សមួយនៅក្នុងអង្គភាពមួយ បើគ្មានមហាជននៅជាមួយមិនខ្លាំងទេ ។ នៅជាមួយក្នុងន័យសតិអារម្មណ៍នៅជាមួយ នយោបាយនៅជាមួយ ចាត់តាំងនៅជាមួយ ។*

*(ទង់បដិវត្តលេខ៧ ខែកក្កដា ឆ្នាំ១៩៧៦)*

◆ ***សកម្មនឹងស្មុះស្មាញ៖*** *ប្រយុទ្ធនឹងវាយសម្រុក ដោយឈរលើសន្ទុះឈ្នះ ឈរលើជំហរមានប្រៀបដាច់ខាតលើខ្មាំងនឹងលើសុទិដ្ឋិនិយម បដិវត្តឥតងាករេ ។ តែធំបំផុតសកម្មនឹងស្មុះស្មាញត្រូវឲ្យចំទិស ។*

*(ដកស្រង់ចេញពីសៀវភៅការងារពង្រឹងនិងកែលម្អ គោលជំហរនិងអាកប្បកិរិយាដឹកនាំនិងធ្វើការងាររបស់បក្ស)*

# ការរាប់ចំនួនមនុស្សស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

***(តពីលេខមុន)***

### ***ក) ក្រេក អេចឆេសាន់***

នៅឆ្នាំ១៩៩៤ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចាប់ផ្តើមដោះស្រាយសំណួរទាក់ទងទៅនឹងចំនួនមនុស្សស្លាប់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងឆ្នាំ១៩៩៩ ដោយសង្ខេបការស្រាវជ្រាវក្នុងរយៈពេល៥ឆ្នាំមុន ក្រេក អេចឆេសាន់ បានសរសេរអត្ថបទដ៏វែងមួយដែលមានចំណងជើងថា «ចំនួននិងទំហំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅកម្ពុជា» ។ នៅក្នុងការវិភាគដ៏ចម្រូងចម្រាស់នេះ អេចឆេសាន់ មិនបានផ្តល់នូវការសន្និដ្ឋានអំពីចំនួនមនុស្សស្លាប់សរុបទេ ប៉ុន្តែគាត់បានលើកឡើងនូវភ័ស្តុតាងដែលបង្ហាញថា ការសន្និដ្ឋានរបស់ វិកខ័រី និង យៀរនិន អំពីតួលេខនៃចំនួនមនុស្សស្លាប់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យគឺទាបពេក ។

«ប្រជាជនកម្ពុជាភាគច្រើនជឿជាក់ដោយគ្មានសង្ស័យថា ខ្មែរក្រហមបានសម្លាប់ប្រជាជនជាង៣លាននាក់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលដែលការសន្និដ្ឋានអំពីចំនួនមនុស្សស្លាប់នៅក្រោមរបបខ្មែរក្រហមត្រូវបានចេញផ្សាយជាលើកដំបូងកាលពីដើមទសវត្សរ៍ឆ្នាំ១៩៨០ អ្នកវិភាគនៅលោកខាងលិចបានច្រានចោលតួលេខនេះ ដោយបាននិយាយថាតួលេខនេះគឺជាលទ្ធផលនៃ «ការឃោសនារបស់វៀតណាម» និងត្រូវបានប្រឌិតឡើងជាពិសេសដើម្បីគោលបំណងនយោបាយ» ។ «ក៏ប៉ុន្តែតួលេខ៣លាននាក់នេះមិនមែនជាការប្រឌិតទាំងស្រុងទេ ។ កាលពីដើមទសវត្សរ៍ឆ្នាំ១៩៨០ អាជ្ញាធរសាធារណរដ្ឋប្រជាមានិតកម្ពុជាបានធ្វើកិច្ចការមួយដែលស្មើនឹងការស្ទាបស្ទង់មតិទូទាំងប្រទេសសំដៅសម្ភាសមេគ្រួសារនៅទូទាំងប្រទេសកម្ពុជាអំពីអ្វីដែលបានកើតឡើងក្នុងក្រុមគ្រួសាររបស់អ្នកទាំងនោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៨៣ «គណៈកម្មាធិការស្រាវជ្រាវរបបប្រល័យពូជសាសន៍ ប៉ុល ពត» បានចេញរបាយការណ៍ចុងក្រោយរបស់ខ្លួន ដែលក្នុងនោះរួមមានទាំងទិន្នន័យពិស្តារតាមខេត្តនីមួយៗទៀតផង ។ ទិន្នន័យនេះបានបង្ហាញថា ប្រជាជនចំនួន៣.៣១៤.៧៦៨នាក់បានបាត់បង់ជីវិតនៅក្នុងរបប ប៉ុល ពត ។ ប៉ុន្តែរបាយការណ៍នេះត្រូវបានបំភ្លេចចោលយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា ។ នៅក្រៅប្រទេសក៏មិនដែលបានដឹងអំពីតួលេខនេះដែររហូតដល់ឆ្នាំ១៩៩៥ ។

«ជាងមួយទសវត្សរ៍បន្ទាប់ពីសាធារណរដ្ឋប្រជាមានិតកម្ពុជាចេញផ្សាយរបាយការណ៍របស់ខ្លួន អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញឯកសារជាច្រើនស្តីអំពីគម្រោងស្រាវជ្រាវដ៏គួរឲ្យកត់សម្គាល់នេះ ។ ឯកសារទាំងនោះបានអនុញ្ញាតឲ្យអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលបង្កើតឡើងវិញនូវវិធីសាស្ត្រដែលគណៈកម្មាធិការស្រាវជ្រាវរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាធ្លាប់បានប្រើប្រាស់ ហើយបានរកឃើញកំហុសមួយចំនួននៅក្នុងគម្រោងស្រាវជ្រាវនេះ ។ កំហុសទាំងនេះហើយដែលបាននាំទៅដល់ការសន្និដ្ឋានលើសពីចំនួនមនុស្សស្លាប់ពិតប្រាកដ ។ អ្នកធ្វើសម្ភាសន៍របស់គណៈកម្មាធិការស្រាវជ្រាវកាលពីដើមទសវត្សរ៍ឆ្នាំ១៩៨០ បានធ្វើដំណើរពីផ្ទះមួយទៅផ្ទះមួយ និងពីភូមិមួយទៅភូមិមួយ ដើម្បីប្រមូលយកពត៌មានទាក់ទងនឹងការស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ប៉ុន្តែអ្នកធ្វើសម្ភាសន៍ទាំងនោះមិនបានគិតឲ្យដិតដល់អំពីការណ៍ដែលថា ជាធម្មតាសមាជិកក្រុមគ្រួសារធំមួយបានបំបែកជាគ្រួសារតូចៗ ហើយទៅរស់នៅក្នុងផ្ទះផ្សេងៗពីគ្នា ឬក្នុងភូមិផ្សេងៗពីគ្នាផងទេ ។ ដូច្នេះការរាប់ចំនួនដដែលៗបានកើតឡើង» ។

ដោយលើកឡើងអំពីកំហុសបច្ចេកទេសផ្សេងទៀត អេចឆេសាន់ បានសន្និដ្ឋានជាចុងក្រោយថា ចំនួនមនុស្សស្លាប់ត្រូវបានរាប់លើសយ៉ាងហោចណាស់ក៏៥០ភាគរយដែរ ហើយគាត់បានចេញសេចក្តីសន្និដ្ឋានចំនួនមនុស្សស្លាប់សរុបថាស្ថិតក្នុងវង្វង់

២លាននាក់ ។

ទន្ទឹមនឹងនោះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានចាប់ផ្តើមគម្រោងពិស្តារមួយទៀតដើម្បីកំណត់ទីតាំងរណ្តៅសាកសពដែលនៅរាយប៉ាយពាសពេញផ្ទៃប្រទេស ។ នៅចន្លោះឆ្នាំ១៩៩៥ និងឆ្នាំ១៩៩៩ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើស្ថិតិរណ្តៅសាកសពរួមប្រមាណជា២ម៉ឺនរណ្តៅ ។ អេចឆេសាន់ បានសរសេរថា «យោងទៅតាមទិន្នន័យដែលមានរណ្តៅសាកសពទាំងនេះ មានសាកសពជនរងគ្រោះដែលត្រូវបានប្រហារជីវិតប្រមាណជា១.១១២.៨២៩នាក់ ។ ជាងនេះទៅទៀតចំនួននេះតំណាងឲ្យតែមួយផ្នែកនៃចំនួនសរុបប៉ុណ្ណោះ ។ អេចឆេសាន់ បានសន្និដ្ឋានថា «ចំនួនមនុស្សស្លាប់សរុបអាចខ្ពស់ជាងនេះ ហើយប្រហែលជាអាចច្រើនដល់១,៥លាននាក់» ។

ប្រសិនបើចំនួនសាកសពនៅក្នុងរណ្តៅសាកសពរួមប្រហែលជាបានផ្តល់ឲ្យយើងនូវចំនួនសមហេតុផលនៃមនុស្សដែលត្រូវសម្លាប់ តើទិន្នន័យនេះប្រាប់យើងអំពីចំនួនមនុស្សស្លាប់សរុបបែបណាខ្លះ? អេចឆេសាន់ បានពន្យល់ថា ដោយយោងតាម យៀរនិនទិន្នន័យរបស់ មីលតុន អូសបឺន បានបង្ហាញថា ចំនួនមនុស្សដែលត្រូវសម្លាប់គឺស្មើនឹង៣១ភាគរយនៃចំនួនមនុស្សស្លាប់សរុប ។ ទន្ទឹមនឹងនោះ «ប្រជាវិទូ មេរីក ស្លីវិនស្គី បានសន្និដ្ឋានថា ៤០ភាគរយនៃចំនួនស្លាប់សរុប បានស្លាប់ដោយការសម្លាប់ ៣៦ភាគរយស្លាប់ដោយការអត់អាហារ១៣ភាគរយដោយជំងឺ និងក្រៅពីនេះស្លាប់ដោយសារប្រយុទ្ធគ្នានៅក្នុងសង្គ្រាមឬស្លាប់តាមធម្មជាតិ ។ អ្នកវិទ្យាសាស្ត្រនយោបាយ ស្ទីហ៊ិន ហេដឌ័រ បានអះអាងថា តួលេខមនុស្សស្លាប់អាចខុសគ្នារវាងអ្នកទីក្រុងនិងអ្នកជនបទគឺប្រហែលជា៣៣ភាគរយនៃ«ប្រជាជនថ្មី»និង៥០ភាគរយនៃ«ប្រជាជនមូលដ្ឋាន» ។ ដូច្នេះការសន្និដ្ឋានផ្សេងៗអំពីចំនួនមនុស្សស្លាប់ដែលជាលទ្ធផលនៃការសម្លាប់ស្ថិតនៅចន្លោះទាបបំផុតគឺប្រមាណពី៣០ភាគរយនៃប្រជាជនទូទៅទៅ៥០ភាគរយនៃប្រជាជនមូលដ្ឋាន ។»

ដោយពិចារណាអំពីតួលេខទាំងនេះ អេចឆេសាន់ បានបន្តថា៖«តួលេខទាំងនេះជំពាក់ជាក់វិនិច្ឆ័យជាទីបំផុត ។ ប្រសិនបើការគណនានេះដែលគិតដល់មូលហេតុផ្សេងទៀតក្រៅពីការសម្លាប់គឺជាការត្រឹមត្រូវយើងនឹងចាប់ផ្តើមបោះជំហានទៅរកការសន្និដ្ឋានដ៏គួរឲ្យភ្ញាក់ផ្អើលមួយ ។ មើលទៅប្រហែលជាអាចទៅរួចដែលថាការសន្និដ្ឋានដំបូងបំផុតរបស់កម្ពុជា(៣,៣លាននាក់) អាចជាចំនួនមួយជិតត្រឹមត្រូវដែរ» ។

«ប្រសិនបើគិតអត្រាទាបបំផុតគឺ៣១ភាគរយនៃជនរងគ្រោះជាលទ្ធផលនៃការសម្លាប់នោះអាចមានន័យថា ក្នុងចំនួនមនុស្សស្លាប់សរុប៣,៣លាននាក់មានជាងមួយលាននាក់ស្លាប់ដោយការសម្លាប់ ហើយទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្ហាញថា ជនរងគ្រោះដែលស្លាប់ដោយការសម្លាប់មានច្រើនជាងចំនួននេះ ។ ប្រសិនបើយើងគិតតាម ហេដឌ័រ ដែលយកអត្រាខ្ពស់បំផុតគឺ៥០ភាគរយនៃប្រជាជនមូលដ្ឋាន និងដោយសារការធ្វើស្ថិតិរណ្តៅសាកសពរួម យើងនឹងរកឃើញថា ចំនួនជនរងគ្រោះដែលសង្ស័យថាត្រូវសម្លាប់គឺមានប្រមាណ១,៥លាននាក់ ហើយយើងនឹងបញ្ចប់ជាមួយនឹងតួលេខសន្និដ្ឋានអំពីចំនួនមនុស្សស្លាប់សរុបនៅក្នុងរង្វង់៣លាននាក់នៅក្នុងរបប ប៉ុល ពត ។ នៅក្នុងករណីទាំងនេះ យើងអាចត្រូវជំរុញឲ្យឈានដល់ការសន្និដ្ឋានមួយដែលថា ប្រជាជនកម្ពុជាដែលស្លាប់មុនអាយុនៅក្នុងរបបខ្មែរក្រហមមិនមែន១លាននាក់ហើយក៏មិនមែន២លាននាក់ដែរ គឺ៣លាននាក់» ។

បើគ្រាន់តែអានរបាយការណ៍របស់ អេចឆេសាន់ យើងនឹងយល់ថា ការសន្និដ្ឋានផ្ទាល់ខ្លួនរបស់គាត់អំពីចំនួនមនុស្សស្លាប់សរុបគឺប្រហែលជា៣លាននាក់ ។ ក៏ប៉ុន្តែ បើយោងទៅតាម អេចឆេសាន់ ការសន្និដ្ឋាននេះមិនមែនជាចេតនារបស់គាត់ទេ ។ សម្រាប់ខ្លួនគាត់ផ្ទាល់ អេចឆេសាន់ បានលើកឡើងថា ចំនួនមនុស្សស្លាប់សរុបគឺនៅចន្លោះពី២លាននាក់ទៅ២,៥លាននាក់ ហើយនៅក្នុងនេះ តួលេខដែលទំនងបំផុតគឺ ២,២លាននាក់ ។

តើយើងត្រូវការកត្តាអ្វីខ្លះដើម្បីពិចារណា មុនពេលដែលយើងអាចអះអាងអំពីតួលេខដែលខ្ពស់ជាងមុនដោយសំអាងលើទិន្នន័យកោសល្យវិច័យ? អេចឆេសាន់ បានបង្ហាញបញ្ហាមួយចំនួនដែលជាប់ពាក់ព័ន្ធជាមួយនឹងការសំអាងលើទិន្នន័យពីរណ្តៅសាកសព ។ អេចឆេសាន់ បានដកស្រង់វគ្គមួយចេញពីសៀវភៅ



អដ្ឋិធាតុជនរងគ្រោះនៅវាលពិឃាតបឹងជើងឯក

«កម្ពុជាពីឆ្នាំ១៩៧៥-១៩៨២» របស់ វិកឃ័រវីច ដែលសរសេរថាៈ

«រណ្តៅសាកសពមួយចំនួនដែលរកឃើញ បានផ្តល់ភ័ស្តុតាងដែលបង្ហាញថាការសម្លាប់រង្គាលបានកើតឡើង ប៉ុន្តែមិនទាន់មានមធ្យោបាយដើម្បីរាប់ចំនួននៃការសម្លាប់ឲ្យដាច់ដោយឡែកពីការស្លាប់ដោយសារមូលហេតុផ្សេងៗទៀតនោះទេ។ យ៉ាថៃ បានបង្ហាញថា នៅក្នុងខេត្តពោធិសាត់ពីឆ្នាំ១៩៧៦-៧៧ រណ្តៅសាកសពរួមគឺសម្រាប់កប់តែសាកសពដែលស្លាប់ដោយសារការអត់អាហារនិងដោយជំងឺប៉ុណ្ណោះ ចំណែកការសម្លាប់ប្រព្រឹត្តឡើងនៅកន្លែងផ្សេងទៀតនៅក្នុងព្រៃ។ ដាងនេះទៅទៀត ជនរងគ្រោះប្រមាណ៥សែននាក់ដែលស្លាប់ដោយសង្គ្រាមត្រូវបានកប់នៅក្នុងរណ្តៅសាកសពរួម ហើយប្រសិនបើគ្មានការធ្វើកោសល្យវិច័យទេ យើងប្រហែលជាមិនអាចកំណត់ថាតើសាកសពនោះស្លាប់មុនឬក្រោយឆ្នាំ១៩៧៥ទេ»។

អេបឆេសាន់ បានកត់សម្គាល់ថា «ប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមការងារដែនទីរណ្តៅសាកសពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានកំណត់ទីតាំងរណ្តៅសាកសពមួយចំនួនដែលអ្នកផ្តល់ព័ត៌មាននៅមូលដ្ឋានបាននិយាយថា សាកសពដែលនៅក្នុងរណ្តៅសាកសពរួមទាំងនោះមិនមែនស្លាប់ដោយសារខ្មែរក្រហមសម្លាប់ទេ ប៉ុន្តែដោយសារការទម្លាក់គ្រាប់បែក ដោយសារសង្គ្រាមក្នុងអំឡុងឆ្នាំ១៩៧០-១៩៧៥ ដោយកង្វះអាហារ ហើយរណ្តៅ



សាកសពមួយឬពីរទាក់ទងទៅនឹងការលុកលុយរបស់កងទ័ពវៀតណាមកាលពីឆ្នាំ១៩៧៩» ។ ក៏ប៉ុន្តែគ្មានអ្វីគួរឲ្យសង្ស័យទេ ភាគច្រើននៃរណ្តៅសាកសពទាំងអស់គឺបណ្តាលមកពីរបបខ្មែរក្រហម ។ «មានតែពីរលើកប៉ុណ្ណោះដែលក្រុមការងារផ្នែកផែនទីរណ្តៅសាកសពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញថា រណ្តៅសាកសពនោះជារណ្តៅសាកសពរបស់ជនរងគ្រោះដោយការទម្លាក់គ្រាប់បែកនៅក្នុងអំឡុងសង្គ្រាមពីឆ្នាំ១៩៧០-១៩៧៥» ។ ជាងនេះទៅទៀត អេចឆេសាន់ បានកត់សម្គាល់ថា «ជាញឹកញាប់រណ្តៅសាកសពស្ទើរតែទាំងអស់ត្រូវបានរកឃើញ នៅក្នុងបុរនៅក្បែរមន្ទីរសន្តិសុខរបស់ខ្មែរក្រហមក្នុងរង្វង់ប្រហែលតែមួយគីឡូម៉ែត្រជុំវិញមន្ទីរនោះប៉ុណ្ណោះ ។ នៅក្នុងករណីភាគច្រើនហាក់ដូចជាថា អ្នកផ្តល់ព័ត៌មាននៅមូលដ្ឋានបានរំឭកអំពីឈ្មោះរបស់កម្មាភិបាលដែលទទួលខុសត្រូវមន្ទីរឃុំឃាំងឬមណ្ឌលសម្លាប់មនុស្សរបស់ខ្មែរក្រហម ។ យើងអាចកត់ឈ្មោះនិងទីលំនៅរបស់កម្មាភិបាលសន្តិសុខខ្មែរក្រហមទាំងនោះដើម្បីធ្វើសម្ភាសន៍លើកក្រោយទៀត ។»

ទោះជាយ៉ាងណាក៏ដោយ ចាំបាច់ត្រូវតែស្រាយបញ្ជាក់ចំណុចមួយដែលពាក់ព័ន្ធទៅនឹងទិន្នន័យកោសល្យវិច័យនោះ គឺថាចំនួនគ្រោងឆ្អឹងសាកសពទាំងនោះក៏នៅតែជាការប៉ាន់ស្មានដែរ ។ ក៏ប៉ុន្តែ អេចឆេសាន់ បានអះអាងថា ដោយសារមានបទពិសោធន៍ក្នុងកិច្ចការនេះ ក្រុមការងារអាចសម្រេចបានលទ្ធផលល្អនិងថាជាទូទៅវិធីសាស្ត្រដែលប្រើប្រាស់ក្នុងការចងក្រង ការប៉ាន់ស្មានទាំងនោះមានភាពលម្អៀងតិចតួចប៉ុណ្ណោះ ។

ឃៀរនិន បានជំទាស់ទៅនឹងការអះអាងនេះដោយលើកឡើងថា ទិន្នន័យរបស់ក្រុមការងារកំណត់ផែនទីរណ្តៅសាកសពបានបង្ហាញអំពីចំនួនមនុស្សស្លាប់ច្រើនជាងការប៉ាន់ស្មានរបស់គាត់ (១,៧លាននាក់) ។ ឃៀរនិន បានលើកឡើងថា កំណត់សម្គាល់របស់ អេចឆេសាន់ ដែលថា រណ្តៅសាកសពរួមទាំងនោះមានជនរងគ្រោះនៃការសម្លាប់មិនបានប្រានបោលនូវលទ្ធភាពដែលថា ភាគច្រើននៃរណ្តៅសាកសពទាំងនោះក៏អាចមានជនរងគ្រោះដែលស្លាប់ដោយសារមូលហេតុផ្សេងទៀតដែរ ។ ឃៀរនិន បានសរសេរថា «អេចឆេសាន់ បានមើលរំលងភ័ស្តុតាងរបស់ពិន យ៉ាថៃ ដែលថានៅក្នុងខេត្តពោធិសាត់នៅឆ្នាំ១៩៧៦-១៩៧៧ រណ្តៅសាកសពត្រូវបានជីកសម្រាប់កប់សាកសពដែលស្លាប់ដោយកង្វះអាហារនិងជំងឺ មិនមែនដោយការសម្លាប់ទេ» ។ នេះគឺជាការយោងដូចគ្នាទៅនឹងអ្វីដែលលើកឡើងដោយ វីកឃីរី នៅផ្នែកខាងក្រោមនេះ ។

មិនទាន់ច្បាស់លាស់នៅឡើយទេថា តើកំណត់សម្គាល់របស់ យ៉ាថៃ ពិតជាគាំទ្រការបកស្រាយដែលលើកឡើងដោយអ្នកប្រាជ្ញទាំងពីរនេះដែរឬទេ ។ ឃ្លារបស់ ឃៀរនិន បង្កប់ន័យថា យ៉ាថៃ និយាយថា សាកសពដែលស្លាប់ដោយសារភាពអត់ឃ្លាន

និងជំងឺត្រូវបានកប់ ប៉ុន្តែសាកសពដែលស្លាប់ដោយការសម្លាប់ មិនត្រូវបានកប់ទេ ។ តាមពិត យ៉ាថៃ មិនបាននិយាយដូច្នោះឡើយ ។ ជាងនេះទៅទៀត វាមិនទាន់ច្បាស់លាស់នៅឡើយទេថា អ្វីៗនៅខេត្តពោធិសាត់ដែល យ៉ាថៃ បានរៀបរាប់គួរតែហៅថា ជារណ្តៅសាកសពរួមដែរឬអត់ ។ ការកប់នោះកើតឡើងនៅក្នុងរបៀបជាវាលកប់ខ្មោចដែលដូចគ្នាតិចតួចប៉ុណ្ណោះនឹងរណ្តៅសាកសពរួមដែលគម្រោងផែនទីរណ្តៅសាកសពបានរកឃើញ ។

ការសន្និដ្ឋានរបស់ អេចឆេសាន់ នៅក្នុងរបាយការណ៍ផែនទីរណ្តៅសាកសពគឺថា រណ្តៅសាកសពរួមទាំងនោះមានជនរងគ្រោះដែលស្លាប់ដោយការសម្លាប់ ហើយមិនមានជនរងគ្រោះដែលស្លាប់ដោយការអត់ឃ្លាននិងជំងឺទេ ។ ប្រសិនបើការបកស្រាយរបស់ វីកឃឺរី និង ឃៀវនិន អំពី យ៉ាថៃ ពិតជាត្រឹមត្រូវមែន ហើយការប្រហារជីវិតពិតជាកើតឡើងដាច់ដោយឡែកនៅក្នុងព្រៃមែននោះ សាកសពទាំងនោះប្រហែលជាមិនត្រូវបានកប់នៅក្នុងរណ្តៅសាកសពរួមទេ ។ នៅក្នុងដំណើរហេតុការណ៍បែបនេះចំនួនគ្រោងឆ្អឹងសាកសពដែលគាស់ចេញពីក្នុងរណ្តៅសាកសពគ្រាន់តែតំណាងឲ្យចំនួនមនុស្សស្លាប់តែមួយផ្នែកប៉ុណ្ណោះ ។ រឿងនេះមិនសាំញ៉ាំពេកទេ ដោយសារតែការស្ទាបស្ទង់នេះបានបង្ហាញថា ចំនួនមនុស្សស្លាប់ដោយការសម្លាប់អាចស្ថិតនៅចន្លោះពី៣០ ទៅ៥០ភាគរយនៃចំនួនមនុស្សស្លាប់សរុប ។ ប្រសិនបើអត្រានៃការសម្លាប់គឺ៥០ភាគរយ នោះពាក់កណ្តាលនៃជនរងគ្រោះនៅក្នុងខេត្តពោធិសាត់មិនត្រូវបានរាប់ទេក្នុងករណីដែលយើងរាប់តែចំនួនគ្រោងឆ្អឹងនៅក្នុងរណ្តៅសាកសព ។

ប៉ុន្តែ ការបដិសេធរបស់ ឃៀវនិន គឺខ្លាំងជាងនេះ ។ ឃៀវនិន អះអាងថា ការគណនារបស់ អេចឆេសាន់ «មិនបានគិតដល់ទិន្នន័យទាំងអស់របស់អ្នកប្រជាសាស្ត្រកម្ពុជាទេ» ។ ឃៀវនិន បានសរសេរថា «ការធ្វេសប្រហែសបែបនេះគឺមិនសមនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។ ការបំផ្លើសចំនួនមនុស្សស្លាប់បានរួមចំណែកដល់ការបន្ថយបទដ្ឋាននៃការស្រាវជ្រាវអំពើប្រល័យពូជសាសន៍» ។

ការចោទប្រកាន់អំពី «ការកាត់បន្ថយបទដ្ឋាន» គឺមិនសមហេតុផលទេ ។ វាលំបាកក្នុងការមើលអំពីរបៀបដែលអះអាងថា ការណ៍ដែលការប៉ាន់ស្មានអំពីចំនួនមនុស្សស្លាប់ដែលមានស្រាប់របស់កម្ពុជាអាចជាប់ពាក់ព័ន្ធជាមួយសោកនាដកម្មដែលមិនជាប់ទាក់ទងផ្សេងទៀត ។

បញ្ហាដែលសំខាន់គឺថា តើអត្ថបទរបស់ អេចឆេសាន់ ពិតជាមិនរើរវល់នឹងទិន្នន័យប្រជាសាស្ត្រមែនឬ? តើការចោទប្រកាន់របស់ ឃៀវនិន ត្រឹមត្រូវដែរទេ? ចម្លើយគឺមែនផង មិនមែនផង ។ នៅក្នុងអត្ថបទអំពីផែនទីរណ្តៅសាកសព អេចឆេសាន់ បានសង្ខេបភាពជំពាក់ជំពិនរវាងចំនួនគ្រោងឆ្អឹងជាមួយនឹងយោបល់ថា «យើងអាចត្រូវជំរុញឲ្យទៅដល់ការសន្និដ្ឋានថា ប្រជាជនកម្ពុជាដែលស្លាប់មុនអាយុនៅក្នុងរបបខ្មែរក្រហមមិនមែន១លាននាក់ ហើយក៏មិនមែន២លាននាក់ដែរ គឺ៣លាននាក់» ។ មានតែមួយពាក្យប៉ុណ្ណោះដែលធ្វើឲ្យប្រយោគនេះមិនត្រឹមត្រូវគឺ «មុនអាយុ» ។

អ្វីដែល អេចឆេសាន់ ហាក់ដូចជាមើលរំលងនៅក្នុងការកត់សម្គាល់នេះគឺ តើការលំបាកក្នុងការញែកឲ្យដាច់រវាងការស្លាប់ដោយធម្មជាតិនិងការស្លាប់ដោយមិនមែនធម្មជាតិ នឹងប៉ះពាល់យ៉ាងដូចម្តេចទៅលើការគណនាអត្រាមនុស្សស្លាប់ដោយការសម្លាប់និងការស្លាប់ដោយសារមូលហេតុផ្សេង ។ វាមិនច្បាស់លាស់ទាល់តែសោះដែលថា អ្នកដែលឆ្លើយតបនៅក្នុងការស្ទាបស្ទង់មតិរបស់ ហេដឌ័រ, អូសបិន, និង ឃៀវនិន អាចបែងចែកថាតើការស្លាប់មួយណាដែលអាចកំណត់ថាជាការស្លាប់ធម្មតា ហើយតើការស្លាប់មួយណាដែលអាចកំណត់ថាជាការស្លាប់ដោយមូលហេតុផ្សេងទៀត ។ ដូច្នេះអត្រាដែល អេចឆេសាន់ បានយោងទៅដល់នោះគឺត្រឹមត្រូវជាងក្នុងការគណនាអំពីមនុស្សស្លាប់ទាំងអស់ មិនមែនតែការស្លាប់មុនអាយុនោះទេ ។

អត្រាមរណៈនៅមុនពេលមានសង្គ្រាមអាចបង្ហាញថា សាកសព៥សែននាក់អាចតំណាងឲ្យការស្លាប់ធម្មតានៅក្នុងរបបខ្មែរក្រហម ។ ការស្លាប់ចំនួន៣លាននាក់អាចមានន័យថា ប្រមាណ ២លាន ៥សែននាក់បានស្លាប់ដោយមូលហេតុផ្សេងពីធម្មជាតិ ហើយប្រសិនបើចំនួនស្លាប់ដោយការសម្លាប់ខ្ពស់ជាង៣០ភាគរយនោះចំនួនមនុស្សស្លាប់សរុបគឺទាបជាងនេះ ។

តើតួលេខនេះសមស្របនឹងភស្តុតាងប្រជាសាស្ត្រដែរឬទេ? ប្រជាវិទូ ឃៀរនិន បានដកស្រង់សម្តីរបស់ ផាទ្រីក អ៊ូវែលលីន ដែលបានលើកឡើងថា ការប៉ាន់ស្មានផ្ទាល់របស់ ឃៀរនិន គឺទាប ក៏ប៉ុន្តែការប៉ាន់ស្មានរបស់ ផាទ្រីក អ៊ូវែលលីន ក៏ប្រហាក់ប្រហែលនឹងការប៉ាន់ស្មានរបស់ ឃៀរនិន ដែរ ។

## ឃ) ផាទ្រីក អ៊ូវែលលីន

ការប៉ាន់ស្មានជាដំបូងរបស់ ផាទ្រីក អ៊ូវែលលីន គឺពឹងផ្អែកលើទិន្នន័យចំនួនប្រជាជន ចំណែកឯ ឃៀរនិន វិញ គឺពឹងផ្អែកជាសំខាន់លើការស្ទាបស្ទង់ ។ អត្ថបទកាលពីឆ្នាំ១៩៩៩របស់ អេចឆេសាន់ ពាក់ព័ន្ធជាសំខាន់ជាមួយនឹងទិន្នន័យកោសល្យ-វិច័យ ។ ចេញពីទស្សនវិស័យថ្មី អ៊ូវែលលីន បានវិភាគទំហំនៃក្រុមប្រជាជនផ្សេងៗគ្នា ដោយផ្អែកលើអាយុនិងភេទនៅមុននិងក្រោយទសវត្សរ៍ឆ្នាំ១៩៧០ ។ ដោយសិក្សាអំពីទំហំរបស់ក្រុមទាំងនេះ និងដោយបានកំណត់ទិសដៅនៃការស្រង់ចំនួនប្រជាជន អ៊ូវែលលីន បានគណនាចំនួនមនុស្សស្លាប់ដោយសារមូលហេតុផ្សេងៗមិនមែនធម្មជាតិ សម្រាប់រយៈពេលនៅចន្លោះឆ្នាំ១៩៧០និង១៩៨០ ។

អ៊ូវែលលីន បានសង្កត់ធ្ងន់ថា «ការប៉ាន់ស្មានទាំងឡាយរួមទាំងរបស់ខ្ញុំផង គឺស្ថិតនៅក្រោមភាពមិនច្បាស់លាស់» ។ ប៉ុន្តែវាហាក់បីដូចជាថា អត្រាមនុស្សស្លាប់អាចខ្ពស់ជាងអ្វីដែលបានជឿជាក់កាលពីមុន ។ អ៊ូវែលលីន បានសរសេរថា «ល្អបំផុតដែលឥឡូវនេះយើងអាចប៉ាន់ស្មានបានថា ប្រជាជនកម្ពុជាជាងពីរលាននាក់បានស្លាប់នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ ដោយសារព្រឹត្តិការណ៍នយោបាយនៅក្នុងទសវត្សរ៍នោះ ហើយភាគច្រើននៃអ្នកទាំងនោះស្លាប់នៅក្នុងអំឡុងពេល៤ឆ្នាំនៃរបបកម្ពុជាប្រជាធិបតេយ្យ» ។

ការវិភាគរបស់ អ៊ូវែលលីន មានមូលដ្ឋានលើការពិនិត្យទំនោរនៃអត្រាកំណើនប្រជាជន ។ ដូច្នេះ រយៈពេលដែលអត្រាកំណើនប្រជាជនមានសភាពធម្មតា ជាពិសេសនៅមុនឆ្នាំ១៩៧០ និងក្រោយឆ្នាំ១៩៨០ បានផ្តល់នូវបទដ្ឋានមួយដែលអាចឲ្យអ្នកវិភាគវាស់ស្ទង់ឥទ្ធិពលនៃវិបត្តិបាន ។

នៅក្រោមលក្ខខណ្ឌធម្មតា ការស្លាប់មានទម្រង់ជាខ្សែកោងរាងអក្សរ «J» ។ ពីឆ្វេងទៅស្តាំតាម រាងអក្សរ «J» យើងឃើញថាការស្លាប់របស់ទារកដែលទើបតែចាប់កំណើតភ្លាមៗមានកម្រិតខ្ពស់ ។ អត្រាមរណៈបានថយចុះនៅពេលឆ្លងផុតវ័យកុមារហើយកើនឡើងខ្លាំងម្តងទៀតនៅពេលឆ្លងផុតវ័យជំទង់និងក្រោយមជ្ឈិមវ័យ ។

បើពិនិត្យមើលភាពស៊ីសង្វាក់គ្នានៃអត្រាស្លាប់នៅក្រោមលក្ខខណ្ឌធម្មតា ទិន្នន័យនៃការស្រង់ចំនួនប្រជាជនដែលត្រូវបានធ្វើឡើងយូរបន្ទាប់ពីវិបត្តិអាចត្រូវបានប្រើប្រាស់ដើម្បីប៉ាន់ស្មានចំនួននៃក្រុមប្រជាជនដែលរួចរស់ជីវិតពីវិបត្តិ ។ ការណ៍នេះអនុញ្ញាតឲ្យប្រជាវិទូកំណត់ចំនួននៃការស្លាប់របស់ក្រុមនីមួយៗនៅអំឡុងពេលមានវិបត្តិ ។ នៅក្នុងករណីប្រទេសកម្ពុជា ទិន្នន័យបានបង្ហាញអំពីការបាត់បង់ជីវិតយ៉ាងច្រើននៅក្នុងអំឡុងពេលមានវិបត្តិ ជាពិសេសនៅក្នុងចំណោមបុរសពេញវ័យ ។

ពាក្យថា «វិបត្តិ» នៅក្នុងបរិបទនៃការវិភាគរបស់ អ៊ូវែលលីន គឺសំដៅទៅរករយៈពេលពេញមួយទសវត្សរ៍ឆ្នាំ១៩៧០ ។ ដូច ឃៀរនិន ដែរ អ៊ូវែលលីន ជឿជាក់ថា ការប៉ាន់ស្មានរបស់ វីកឃីរី គឺទាបខ្លាំងពេក ។ អ៊ូវែលលីន បានពិនិត្យមើលរបាយការណ៍ពីការស្រង់ចំនួនប្រជាជននិងការវិភាគបន្ត បន្ទាប់នៃរបាយការណ៍ទាំងនោះដែលធ្វើឡើងដោយ ចច ស៊ីយ៉ាមប៉ូស ។ ស្របជាមួយនឹងភាពចម្រូងចម្រាស់របស់ ស៊ីយ៉ាមប៉ូស ដែលថាអត្រាកំណើតត្រូវបានប៉ាន់ប្រមាណទាបពេក អ៊ូវែលលីន បានប៉ាន់ស្មានចំនួនប្រជាជនសរុបនៅក្នុងឆ្នាំ១៩៧០ថា មានប្រមាណ៧,៧លាននាក់ ។ ស្ថិតិប្រជាជនកាលពីឆ្នាំ១៩៩៨ បានបង្ហាញពីការថយចុះនូវអត្រាកំណើតពីឆ្នាំ១៩៧០ និងធ្លាក់ចុះកាន់តែខ្លាំងបន្ទាប់ពីឆ្នាំ១៩៧៥ ។

បើប្រៀបធៀបចំនួនប្រជាជនកម្ពុជាទៅនឹងចំនួនប្រជាជនថៃ យើងអាចមើលឃើញយ៉ាងងាយនូវឥទ្ធិពលជាបន្តនៃវិបត្តិនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ។ ពីរ៉ាមីដនៃចំនួនប្រជាជនបានបង្ហាញពីការធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងចំណោមក្រុមអាយុនិងក្រុមភេទ ។ ក្រុមដែលកើតនៅចន្លោះឆ្នាំ១៩៧៦និងឆ្នាំ១៩៨០មាន

កម្រិតទាប ហើយគ្រប់ក្រុមដែលកើតមុនឆ្នាំ១៩៧៦ ក៏មានភាពខុសគ្នារវាងបុរសនិងស្ត្រី ។

ទោះជាយ៉ាងណាក៏ដោយ ភាពមិនពិតប្រាកដនៃទិន្នន័យដើមបានធ្វើឲ្យតម្លៃដែលប៉ាន់ស្មានមិនពិតទៅតាមនោះដែរ ។ អ៊ូវែលលីន បាននិយាយថា «ឡូហ្សិកនៃការប៉ាន់ស្មានប្រយោលដោយប្រើសមីការនៃបម្រែបម្រួលចំនួនប្រជាជនគឺស្រដៀងគ្នាទៅនឹងការប្រមូលបំណែកតូចៗមកតម្រៀបឲ្យចេញជារូបភាព នៅពេលលេងល្បែងតម្រៀបរូបដូច្នោះដែរ ។ ប៉ុន្តែជាញឹកញាប់ បំណែកផ្សេងៗអាចត្រូវបានប៉ាន់ស្មានត្រូវ ហើយទំហំនិងរូបរាងនៃបំណែកនីមួយៗមិនច្បាស់លាស់ទេ» ។

ការគណនារបស់ អ៊ូវែលលីន បានបង្ហាញថា ចំនួនមនុស្សស្លាប់អាចខ្ពស់ជាងចំនួនដែលត្រូវបានជឿជាក់ជាទូទៅ ។ សមីការភាគច្រើននៅក្នុងរូបមន្តរបស់ អ៊ូវែលលីន មិនច្បាស់លាស់ប៉ុន្តែអាចប្រហាក់ប្រហែល ។ ដោយផ្តាច់សមីការនីមួយៗឲ្យដាច់ពីគ្នារវាងតម្លៃអប្បបរមានិងតម្លៃអតិបរមា ការគណនាបានបង្ហាញនូវតួលេខចំនួនមនុស្សស្លាប់ខុសពីធម្មជាតិក្នុងរយៈពេលពេញមួយទសវត្សរ៍ ប្រហែលពី១,១៧លាននាក់ ទៅ៣,៤២លាននាក់ ។ ដោយប្រៀបធៀបការគណនាពីមុនឆ្នាំ១៩៧០មកមុខនិងក្រោយឆ្នាំ១៩៨០មកក្រោយវិញ អ៊ូវែលលីន បានឈានដល់តួលេខប្រហែល២,៥២លាននាក់ដែលស្លាប់ខុសពីធម្មជាតិសម្រាប់រយៈពេលពេញមួយទសវត្សរ៍ ។ ដោយគណនាតួលេខនៃចំនួនអ្នកស្លាប់ដោយសង្គ្រាម ការប្រែប្រួលនៃអត្រាមានគភ៌និងអត្រាស្លាប់របស់ទារក និងឥទ្ធិពលនៃគ្រោះទុរភិក្សនៅក្នុងឆ្នាំ១៩៧៩ អ៊ូវែលលីន បានសន្និដ្ឋានថា ចំនួនមនុស្សស្លាប់ខុសពីធម្មជាតិនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យគឺប្រហែល២លាននាក់ ។

## ៤) ការវាយតម្លៃលើការប៉ាន់ស្មាន

វិធីសាស្ត្រខុសគ្នាទាំង៤ក្នុងការវាយតម្លៃចំនួនមនុស្សស្លាប់សរុបបានផ្តល់នូវលទ្ធផលចំនួន៤ខុសៗគ្នា ៖

- ការប្រមូលឡើងវិញនូវទិន្នន័យនៃជំរឿនប្រជាជនៈ ៧៤០.០០០(វីកឃឺរី)
- ការធ្វើគំរូស្មាបស្មុគ្រស្មាញ[?]ៈ ១.៦៧០.០០០(ឃៀរនិន)
- ការស្រង់ស្ថិតិតាមផ្ទះនិងការវាយតម្លៃកោសល្យវិច័យៈ ៣.០០០.០០០ (សាធារណរដ្ឋប្រជាមានិតកម្ពុជា/គម្រោងធ្វើផែនទីរណ្តៅសាកសព)
- និន្នាការប្រជាសាស្ត្រ/ការវិភាគក្រុមមនុស្សៈ ២.០០០.០០០ (អ៊ូវែលលីន)

ដំបូងយើងគួរពិចារណាអំពីការប៉ាន់ស្មានរបស់ វីកឃឺរី ។ តើវាទំនងឬទេ? ការប៉ាន់ស្មាននេះមិនស៊ីគ្នាទៅនឹងទិន្នន័យពីគម្រោងផែនទីរណ្តៅសាកសពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។ របាយការណ៍របស់ អេចឆេសាន់ អំពីគម្រោងផែនទីរណ្តៅសាកសព គឺមានមូលដ្ឋាននៅលើទិន្នន័យដែលប្រមូលធ្វើចាប់តាំងពីឆ្នាំ១៩៩៩ ។ គម្រោងនេះគឺកំពុងតែមានដំណើរការនៅឡើយ ហើយរបាយការណ៍សង្ខេបថ្មីៗរបស់គាត់បានកែប្រែតួលេខកាលពីដំបូង ។ ការប៉ាន់ស្មានថ្មីៗនេះបានបង្ហាញថារណ្តៅសាកសពរួមមានជនរងគ្រោះចំនួន ១.៣៨៦.៧៣៤នាក់ ។

ដូច្នេះចំនួនជនរងគ្រោះដែលមាននៅក្នុងរណ្តៅសាកសពរួមដែលសន្មតថាត្រូវបានសម្លាប់លើសចំនួនមនុស្សស្លាប់សរុប ដែល វីកឃឺរី បានអះអាងថា ជាការស្លាប់ដោយគ្រប់មូលហេតុទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ តាមការពិតចំនួនជនរងគ្រោះដែលមាននៅក្នុងរណ្តៅសាកសពរួមទាំងនេះខ្ពស់ជាងតួលេខបូកបញ្ចូលគ្នារវាងចំនួនអ្នកស្លាប់នៅក្នុងសង្គ្រាមស៊ីវិលនិងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលប៉ាន់ស្មានដោយ វីកឃឺរី ។ វាទំនងថា សាកសពដែលស្លាប់នៅពេលសង្គ្រាមមិនត្រូវបានកប់នៅក្នុងរណ្តៅសាកសពរួមទេ ហើយការស្លាប់ដោយសារឥទ្ធិពលរបស់សង្គ្រាម (ដូចជា ជំងឺ កង្វះខាតអាហារ ។ល ។) ក៏មិនមែនកប់នៅក្នុងរណ្តៅសាកសពរួមដែរ ។

យើងអាចដកចេញនូវការប៉ាន់ស្មានដែលទាបបំផុតនៅក្នុងចំណោមការប៉ាន់ស្មានទាំង៤ ប៉ុន្តែចុះចំណែកការប៉ាន់ស្មានដែលខ្ពស់បំផុតវិញ? ប្រសិនបើទិន្នន័យរបស់គម្រោងផែនទីរណ្តៅសាកសពបង្ហាញថាចំនួនមនុស្សស្លាប់ដោយការសម្លាប់អាចខ្ពស់ដល់១,៣លាននាក់ តើតួលេខមនុស្សស្លាប់៣,៣លាននាក់ដែល

រាយការណ៍ដោយសាធារណរដ្ឋប្រជាមានិតកម្ពុជាអាចត្រឹមត្រូវដែរឬទេ?

ដូចដែល អេចឆេសាន់ បានលើកឡើង ការស្រង់ស្ថិតិរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាមានកំហុសមួយចំនួនខាងផ្នែកបច្ចេកទេស ។ ចំនួនមនុស្សស្លាប់ដែលបានមកពីការស្រង់ស្ថិតិតាមផ្ទះត្រូវបានបូកបញ្ចូលជាមួយចំនួនគ្រោងឆ្អឹងសាកសពដែលគាស់ចេញពីរណ្តៅសាកសពរួម ក៏ប៉ុន្តែគ្មានមធ្យោបាយណាមួយដើម្បីកំណត់ថាតើសាកសពនៅក្នុងរណ្តៅមួយណាជាសាកសពដែលក្រុមគ្រួសារជនរងគ្រោះបានរាយការណ៍ទេ ។ សំខាន់បំផុតអ្នកស្រាវជ្រាវមិនបានគិតគូរឲ្យត្រឹមត្រូវចំពោះករណីខ្លះដូចជាការស្លាប់របស់មនុស្សតែម្នាក់ប៉ុន្តែរាយការណ៍ដោយច្រើនគ្រួសារ ។ ជាក់ស្តែង ការស្លាប់របស់បុរសម្នាក់អាចត្រូវបានរាយការណ៍ពីគ្រួសាររបស់គាត់ផ្ទាល់ផង និងដោយគ្រួសារសាច់ថ្លៃរបស់គាត់ផង ។ អាចទៅរួចដែរ ដែលថាអ្នកខ្លះដែលត្រូវបានជឿជាក់ថាស្លាប់ ប៉ុន្តែបែរជានៅរស់ ហើយតាំងទីលំនៅថ្មីនៅឯបរទេសទៅវិញ ហើយក៏អាចទៅរួចដែរចំពោះការណ៍ដែលថា គ្រួសារខ្លះបានស្លាប់ទាំងអស់ គ្មានសមាជិកណាម្នាក់នៅរស់ទាល់តែសោះ ។ ការស្លាប់ប្រភេទនេះមិនត្រូវបានរាយការណ៍ទេ នៅពេលស្រង់ស្ថិតិ ។ នេះជាចំណុចសំខាន់ ហើយការជំពាក់ជាក់វិនទាំងអស់នេះនឹងត្រូវពិភាក្សានៅខាងក្រោម ។ បើទោះបីជាយ៉ាងនេះក៏ដោយមិនមានភស្តុតាងណាផ្សេងទៀតដើម្បីបង្ហាញឲ្យច្បាស់ថា ចំនួនមនុស្សដែលបាត់បង់ជីវិតពិតប្រាកដស្ថិតនៅក្នុងលំដាប់៣លាននាក់ដែរ ។

ការណ៍នេះនាំយើងទៅរកតួលេខមួយដែលទំនងជាត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនោះគឺ ការប៉ាន់ស្មានរបស់ ឃៀរនិន ដែលថាប្រជាជន១,៦៧លាននាក់ស្លាប់ខុសពីធម្មជាតិ ។ ដូចជាការប៉ាន់ស្មានរបស់អ្នកដទៃទៀតដែរមានចំណុចមិនច្បាស់លាស់មួយចំនួនដែលគួរឲ្យសង្ស័យ ប៉ុន្តែការប៉ាន់ស្មានរបស់ ឃៀរនិន ដែលបានមកពីអត្រាស្លាប់ហាក់បីដូចជាត្រូវគ្នាជាមួយនឹងការប៉ាន់ស្មានរបស់គាត់អំពីចំនួនប្រជាជននៅក្នុងឆ្នាំ១៩៧៥ និងក្នុងឆ្នាំ១៩៧៩ ។

តួលេខរបស់ ឃៀរនិន ក៏ធ្លាក់ទៅក្នុងប្រភេទតួលេខប្រហែលដែល អ៊ូវ៉ែលលីន លើកឡើង ប៉ុន្តែទាបជាងតួលេខ «ប្រហែល» របស់ អ៊ូវ៉ែលលីន ហើយក៏ទាបជាងអ្វីដែលយើងបានរំពឹងទុកដោយសំអាងលើភស្តុតាងកោសល្យវិច័យ ។

កត្តាដែលអាចមួយនោះគឺថាការប៉ាន់ស្មានរបស់ ឃៀរនិន អំពីការស្លាប់របស់«ប្រជាជនថ្មី» និង«ប្រជាជនចាស់» អាចមិនត្រឹមត្រូវ ។ ឃៀរនិន បានលើកឡើងនូវតួលេខ «ប្រជាជនថ្មី» ចំនួន៣,០៥លាននាក់ ក្នុងនោះរួមទាំងអ្នកទីក្រុងចំនួន២,៥៣លាននាក់ ។ គាត់មានមូលដ្ឋានលើតួលេខប្រជាជននៅទីក្រុងភ្នំពេញ១,៨លាននាក់រួមទាំងជនភៀសខ្លួនផង ។ ក៏ប៉ុន្តែ វីលៀម ស្វាវក្រុស បានបង្ហាញតួលេខប្រជាជននៅទីក្រុងភ្នំពេញជាង២លាននាក់ និងបានបន្ថែមថា «ស្ទើរតែពាក់កណ្តាលនៃប្រជាជននៅជនបទបានចាកចោលដីស្រែចម្ការទៅរកកន្លែងប្រសើរជាងមុននៅក្នុងទីក្រុង» ។ ចច ហ៊ីលប្រ៊ែន និង ហ្គារេដ ផតធ័រ បានលើកឡើងថា ប្រជាជននៅក្នុងទីក្រុងភ្នំពេញមានចំនួនប្រហែល៣លាននាក់ ។ សូម្បីតែនៅពេលដែលយើងបូកបញ្ចូលជាមួយប្រជាជននៅក្នុងទីក្រុងផ្សេងៗទៀត ក៏តួលេខនេះនៅតែទាបជាងការសន្និដ្ឋានរបស់សេ.អ៊ី.អា. នៅក្នុងរបាយការណ៍មហន្តរាយប្រជាជនដែលបាននិយាយថា នៅក្នុងឆ្នាំ១៩៧៥មានប្រជាជនប្រមាណ៤លាននាក់ ។

ឃៀរនិន បានគណនាអត្រាមនុស្សស្លាប់២៥ភាគរយនៅក្នុងចំណោមអ្នកទីក្រុង និង១៥ភាគរយនៅក្នុងចំណោមអ្នកជនបទ ។ ការទទួលយកការប៉ាន់ស្មានខ្ពស់ជាងមុននៃចំនួនប្រជាជនភៀសសឹក (ជាពិសេស«ប្រជាជនថ្មី» ចំនួន៤លាននាក់ជំនួសឲ្យតួលេខ៣លាននាក់) នឹងមានន័យថា ចំនួនប្រជាជនស្លាប់សរុបគឺប្រមាណ១,៧៧លាននាក់ ។ ប៉ុន្តែខណៈដែលចំនួនប្រជាជនថ្មីអាចខ្ពស់ជាងអ្វីដែល ឃៀរនិន បានលើកឡើង មិនមានភស្តុតាងសំខាន់ណាមួយនោះទេ ហើយអ្វីដែលយើងមានគឺការប៉ាន់ស្មានពីរដែលទំនង ។

មានកត្តាមួយផ្សេងទៀតដែលអាចប៉ះពាល់ខ្លាំងដល់ការប៉ាន់ស្មានរបស់ ឃៀរនិន ។ មានគុណវិបត្តិមួយនៅក្នុងវិធីសាស្ត្រ

ស្ទាបស្ទង់ដែល ឃៀរនិន បានប្រើប្រាស់នោះគឺ ការបែងចែកមូលហេតុនៃការស្លាប់នឹងបណ្តាលឲ្យការស្ទាបស្ទង់នេះមិនត្រឹមត្រូវ (ទាបជាងចំនួនពិតប្រាកដ) ។

កាលពីដំបូង វិធីសាស្ត្រស្ទាបស្ទង់ហាក់បីដូចជាសមហេតុផលៈ ដោយការធ្វើសម្ភាសន៍អ្នកដែលនៅរស់រានមានជីវិតដែលអាចរាប់ចំនួនសមាជិកគ្រួសារដែលស្លាប់ យើងអាចកំណត់អត្រាស្លាប់ប្រហាក់ប្រហែល ហើយដោយការប្រើប្រាស់អត្រាស្លាប់នេះធៀបទៅនឹងចំនួនប្រជាជនសរុប យើងអាចគណនាការប៉ាន់ស្មានអំពីចំនួនមនុស្សស្លាប់សរុប ។ អ៊ូវែលលីន បានចង្អុលបង្ហាញថា "ជារឿយៗ ការស្រង់ស្ថិតិគឺជាបច្ចេកទេសតែមួយគត់ដែលអ្នកស៊ើបអង្កេតនិងសហការីប៉ុន្មាននាក់អាចប្រើប្រាស់ភ្លាមៗបន្ទាប់ពីវិបត្តិ ។ ដូច្នេះវាផ្តល់ឲ្យនូវការប៉ាន់ស្មានដំបូងដ៏មានសារសំខាន់មួយ ដោយសារបច្ចេកទេសផ្សេងទៀតបង្កការលំបាកខ្លាំងនិងចំណាយអស់ច្រើនជាង" ។ ប្រសិនបើចំនួនមនុស្សស្លាប់តិចតួច វិធីសាស្ត្រស្ទាបស្ទង់បែបនោះអាចត្រឹមត្រូវ ។ ប៉ុន្តែនៅពេលដែលការស្លាប់មិនមានសមាមាត្រនៅក្នុងក្រុមខ្វះ តើនឹងមានរឿងអ្វីកើតឡើង?

ឥឡូវនេះ សូមពិចារណាអំពីការស្លាប់នៅក្នុងគ្រួសារនីមួយៗនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បញ្ហាទីមួយនៃការស្រង់ស្ថិតិនេះត្រូវបានមើលឃើញយ៉ាងច្បាស់ៈ ក្រុមគ្រួសារដែលស្លាប់ទាំងអស់មិនត្រូវបានរាយការណ៍បញ្ចូលទៅក្នុងការស្រង់ស្ថិតិនេះទេ ដោយសារមិនមានសមាជិកណាម្នាក់ដែលនៅរស់រានមានជីវិតដើម្បីរាយការណ៍នោះទេ ។ បើទោះជាគ្រាន់តែករណីនេះតែមួយអាចធ្វើឲ្យប៉ះពាល់ដល់ការប៉ាន់ស្មានអត្រាស្លាប់ ក៏វានៅតែមិនមែនជាបញ្ហាចម្បងនៅឡើយទេ ។ បញ្ហាដែលសំខាន់ជាងនេះគឺការណ៍ពិតដែលថាការស្រង់ស្ថិតិប្រជាជននៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យគឺទំនងជាត្រូវបានរាយការណ៍ដោយគ្រួសារដែលមានសមាជិកនៅរស់ច្រើន ដូច្នេះអត្រាស្លាប់សរុបដែលទាញចេញពីនេះក៏ទាបពេកដែរ ។

ហេតុអ្វី? ដើម្បីជាអំណះអំណាង សូមពិចារណាអំពីឧទាហរណ៍មិនពិតមួយៈ

សន្មតថា យើងចង់ប៉ាន់ស្មានចំនួនមនុស្សស្លាប់នៅក្នុងភូមិមួយដែលមានប្រជាជនចំនួន៣ពាន់នាក់ ។ យើងសាកសួរអ្នកដែលរួចរស់ជីវិតចំនួន៥០នាក់ថាតើមានសមាជិកប៉ុន្មាននាក់ដែលបានស្លាប់នៅក្នុងគ្រួសារនីមួយៗ ។

តើមានរឿងអ្វីកើតឡើងប្រសិនបើការស្លាប់នៅក្នុងភូមិនេះមិនស្មើគ្នា? សន្មតថា នៅក្នុងភូមិនោះមានប្រជាជនសរុប៣០០គ្រួសារ ហើយគ្រួសារនីមួយៗមានសមាជិក១០នាក់ ។ ១៥០គ្រួសារនៅក្នុងចំណោម៣០០គ្រួសារនេះបានបាត់បង់សមាជិកចំនួន៣នាក់ក្នុងមួយគ្រួសារ រីឯ១៥០គ្រួសារទៀតបាត់បង់សមាជិក១នាក់ក្នុងមួយគ្រួសារ ។ ចំនួនស្លាប់សរុបគឺ៦០០នាក់ ។

មុនដំបូង វាហាក់បីដូចជាថា លទ្ធផលដែលទទួលបានគឺត្រឹមត្រូវៈ គ្រួសារនីមួយៗក្នុងចំណោម១៥០គ្រួសារស្លាប់សមាជិកចំនួន៣នាក់ ហើយគ្រួសារនីមួយៗ១៥០គ្រួសារទៀតស្លាប់សមាជិក១នាក់ ។ ដូច្នេះជាមធ្យម ក្នុងមួយគ្រួសារមានសមាជិកស្លាប់ចំនួន២នាក់ ហើយចំនួនស្លាប់សរុបគឺត្រឹមត្រូវតាមចំនួន៦០០នាក់ពិតប្រាកដមែន ។

ចុះហេតុអ្វីបានជាមានបញ្ហា? សូមចាំថាយើងមិនមែនស្ទាបស្ទង់អ្នកដែលនៅរស់ជីវិតគ្រប់ៗគ្នានោះទេ ។ យើងនឹងស្ទាបស្ទង់ទៅលើមនុស្សតែ៥០នាក់ប៉ុណ្ណោះ ដោយសន្មតថាតំណាងឲ្យមនុស្សទាំងអស់ ។ តើជាការពិតដែរឬទេចំពោះភូមិឧទាហរណ៍របស់យើង? នៅក្នុងចំណោមអ្នកនៅរស់រានមានជីវិតចំនួន២.៤០០នាក់ មានសមាជិក១.៣៥០នាក់ពីក្រុមគ្រួសារដែលមានសមាជិក១នាក់ស្លាប់ ហើយមានតែ១.០៥០នាក់ប៉ុណ្ណោះដែលមកពីក្រុមគ្រួសារដែលមានសមាជិក៣នាក់ស្លាប់ ។ យើងមិនទំនងជាអាចទទួលបានចំនួនអ្នករួចរស់ជីវិតស្មើគ្នាពីក្រុមនីមួយៗទេគឺប្រហែលជាទទួលបានអ្នករួចរស់ជីវិតច្រើនពីក្រុមគ្រួសារដែលមានសមាជិកម្នាក់ស្លាប់ ។ បើយើងពិនិត្យមើលឆ្នោតវត្ថុដែលមនុស្សម្នាក់បានទិញចំនួន១.៣៥០សន្លឹក ហើយមនុស្សម្នាក់ទៀតទិញ១.០៥០សន្លឹក តើអ្នកណាម្នាក់មានឱកាសឈ្នះច្រើនជាង? គោលការណ៍គំរូនេះបង្ហាញអំពីភាពមិនច្បាស់លាស់ៈ ដោយសារអ្នករួចរស់ជីវិតពីគ្រួសារ

ដែលមានអត្រាស្លាប់ទាបមានចំនួនច្រើនជាងអ្នកដែលរួចរស់ជីវិតពីក្រុមគ្រួសារដែលមានអត្រាស្លាប់ខ្ពស់អ្នករួចរស់ជីវិតពីគ្រួសារដែលមានអត្រាស្លាប់ទាបទំនងជាត្រូវបានជ្រើសរើសដើម្បីធ្វើការស្ទាបស្ទង់នោះ ។

បញ្ហានេះនឹងលេចឡើងកាន់តែច្បាស់នៅពេលដែលចំនួនមនុស្សស្លាប់កើនឡើង ហើយនឹងកាន់តែធ្ងន់ធ្ងរនៅពេលដែលចំនួនមនុស្សស្លាប់កើនខ្ពស់នៅក្នុងគ្រួសារនីមួយៗ ។ សូមពិចារណាអំពីឧទាហរណ៍ដ៏ជ្រុលហួសហេតុមួយៈ តើយ៉ាងដូចម្តេចទៅវិញ ប្រសិនបើការស្លាប់ទាំង៦០០នាក់នៅក្នុងភូមិនោះកើតឡើងតែក្នុងវង្វង់៧៥គ្រួសារ? ឥឡូវនេះនៅក្នុងចំណោមអ្នករួចរស់ជីវិត ២.៤០០នាក់ មានមនុស្ស២.២៥០នាក់នឹងប្រាប់យើងថាមិនមាននរណាម្នាក់នៅក្នុងគ្រួសាររបស់ខ្លួនស្លាប់នោះទេ ហើយមានតែ១៥០នាក់ប៉ុណ្ណោះដែលនឹងប្រាប់យើងថាសមាជិកគ្រួសាររបស់ខ្លួនចំនួន៨នាក់បានស្លាប់ ។ ដោយសារចំនួនអ្នកនៅរស់ពីក្រុមគ្រួសារដែលគ្មានមនុស្សស្លាប់ច្រើនលើសលប់លើចំនួនផ្សេងទៀតក្នុងអត្រា១៥ទល់នឹង១ វាមិនទំនងទាល់តែសោះដែលថាការស្ទាបស្ទង់មិនច្បាស់លាស់មួយនឹងផ្តល់ឲ្យយើងនូវការប៉ាន់ស្មានត្រឹមត្រូវអំពីចំនួនមនុស្សស្លាប់ ។

ការស្រង់ស្ថិតិមិនច្បាស់លាស់នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ បានឆ្លុះបញ្ចាំងឲ្យឃើញនូវសមាសភាពនៃអ្នកដែលរួចជីវិត...ហើយអ្នករួចរស់ជីវិតអាចជាក្រុមមួយដែលខុសស្រឡះពីប្រជាជនទូទៅនៅពេលចាប់ផ្តើមរបបនេះ ។ វិធីសាស្ត្រធម្មតាក្នុងការដោះស្រាយបញ្ហានេះគឺព្យាយាមជ្រើសរើសអ្នកឆ្លើយតបចំពោះការស្ទាបស្ទង់តាមរបៀបមួយដែលឆ្លុះបញ្ចាំងពីក្រុមប្រជាជនដែលជាទិសដៅរបស់យើង ។

គ្រប់គ្នាអាចជំទាស់ថា តាមរយៈការគណនាអត្រាមរណៈដាច់ដោយឡែកនៃក្រុមមនុស្សផ្សេងៗគ្នា ឃៀរនិន បានដោះស្រាយបញ្ហានេះ ។ ក៏ប៉ុន្តែនេះមិនមែនជាការពិតទេ ។ នៅក្នុងក្រុមមនុស្សនីមួយៗ ការវិវត្តដូចគ្នាបានកើតឡើងៈ ក្រុមគ្រួសារដែលមានអ្នករួចរស់ជីវិតច្រើនទំនងជានឹងត្រូវបានជ្រើសរើសមកធ្វើការស្ទាបស្ទង់ ។

ការលំបាកនៅក្នុងការទទួលបានពិតប្រាកដនូវគំរូមិនច្បាស់លាស់មួយ បានឆ្លើយតបទៅនឹងការពិតដែលថាការគណនារបស់ ឃៀរនិន ដែលបានមកពីការស្ទាបស្ទង់ គឺទាបជាងការប៉ាន់ស្មាន "ផ្ទាល់" ដោយផ្អែកលើទិន្នន័យជំរឿនប្រជាជន ដែល ឃៀរនិន ខ្លួនឯងពេញចិត្តៈ នៅពេលដែលការស្ទាបស្ទង់បានបង្ហាញពីចំនួនមនុស្សស្លាប់ប្រហែល១,៦៧លាននាក់ ការប៉ាន់ស្មានផ្ទាល់បានបង្ហាញថាចំនួនមនុស្សស្លាប់ប្រហែល១,៧៩៧លាននាក់ ។

បើពិចារណាអំពីការណ៍ដែលថា អត្រាមរណៈដែលបង្ហាញដោយការស្ទាបស្ទង់គឺខ្ពស់រួចទៅហើយនោះ វាប្រហែលជាមានការលំបាកសម្រាប់អ្នកធ្វើសម្ភាសន៍ក្នុងការទទួលយកទស្សនៈដែលថា អ្នកដែលមិនបាត់បង់ជីវិតគឺជាមនុស្សមានសំណាង ។ អារម្មណ៍បានប្រឆាំងទៅនឹងគំនិតថាអ្នកដែលបានបាត់បង់សមាជិកគ្រួសារអស់១ភាគ៤គឺជាអ្នកដែលមានសំណាងជាងអ្នកឯទៀត ។ ប៉ុន្តែការណ៍នេះអាចក្លាយជាការពិត ហើយយ៉ាងហោចណាស់ក៏មួយផ្នែកដែរដែលវាបានឆ្លើយតបទៅនឹងការណ៍ដែលថាការប៉ាន់ស្មានរបស់ ឃៀរនិន ទាបជាងតួលេខដែលបានរកឃើញដោយ អេចឆេសាន់ និង អ៊ូវែលលីន ។

ទាក់ទងទៅនឹងការប៉ាន់ស្មានរបស់ អ៊ូវែលលីន យើងប្រហែលជាត្រូវសួរខ្លួនឯងនូវសំណួរមួយៈ ប្រសិនបើអាចកែប្រែទំហំនៃការប៉ាន់ស្មានរបស់ អ៊ូវែលលីន ឲ្យត្រូវគ្នានឹងការវិភាគរបស់ ឃៀរនិន តើមានមូលហេតុណាមួយក្នុងការសន្មតថា អ៊ូវែលលីន ជាអ្នកត្រូវដែរឬទេ? ខ្ញុំរកមិនឃើញមូលហេតុដើម្បីជំទាស់ទៅនឹងការប៉ាន់ស្មានឬការសន្និដ្ឋានរបស់ អ៊ូវែលលីន ទេ ។ ប៉ុន្តែការប៉ាន់ស្មានរបស់ ឃៀរនិន មានបញ្ហាច្រើនៈ ទាំងភ័ស្តុតាងកោសល្យវិច័យនិងច្បាប់នៃភវនីយភាព(ដំណើរសមជាពិត) បង្ហាញថាតួលេខនោះទាប ។ ជាងនេះទៅទៀត ការស្រង់ស្ថិតិពីផ្ទះមួយទៅផ្ទះមួយដែលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានធ្វើក៏បានបង្ហាញថាការប៉ាន់ស្មានរបស់ ឃៀរនិន ទាបដែរ ហើយចំណុចនេះនឹងមានពិភាក្សានៅខាងក្រោម ។

**(នៅមានត)**

**ប្រ៊ូស ស្យាប**

# ការិយាល័យពត៌មានសាធារណៈ

«ការិយាល័យពត៌មានសាធារណៈ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យពត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ពត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

«ការិយាល័យពត៌មានសាធារណៈ» មានផ្តល់ជូននូវសេវា៤យ៉ាងៈ

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង ៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យពត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជ័យ សុភារម្យ ឬ រ័ត្ន ដារា ពិដោរ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។


ក្រុមនិស្សិតធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា


ក្រុមដូនជីប្រជុំនៅបន្ទប់ពត៌មានសាធារណៈ

# ជីវិតក្នុងភាពនឹងថ្កល់

## អ៊ឹង មុត

### គណៈស្រុក ខេត្តសៀមរាប

*(បទសម្ភាសន៍ជាមួយកូនប្រុសឈ្មោះ ណុប ម៉ៃ អាយុ៣៩ឆ្នាំ នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម)*



ថតនៅស្រុកកងមាស ខេត្តកំពង់ចាម ក្នុងឆ្នាំ១៩៧៥

អ៊ឹង មុត

កាលដែលឪពុកខ្ញុំត្រូវចាប់ខ្លួន ខ្ញុំទើបតែអាយុបាន១០ឆ្នាំប៉ុណ្ណោះ ទើបខ្ញុំមិនដឹងពត្រពីហេតុការណ៍ដែលកើតឡើងចំពោះគាត់ ។ តែខ្ញុំបានសាកសួរអ្នកភូមិចាស់ៗអំពីរឿងគាត់ ។ អ្នកភូមិនិយាយថាឪពុកខ្ញុំធ្វើជាគណៈស្រុកនៅខេត្តសៀមរាបតាំងពីឆ្នាំ១៩៧៥ ។ ខ្មែរក្រហម កុហកគាត់ថាឲ្យទៅចូលរួមប្រជុំ រួចបែរជាចាប់គាត់និងអង្គរក្សរបស់គាត់ ។

មានពាក្យចចាមអារ៉ាមថា មានកម្មាភិបាលមកពីតំបន់ភ្លៀសានបានចោទពុកខ្ញុំថាក្បត់ជាតិក្បត់ប្រជាជន ។ មានអ្នកនិយាយថា ខ្មែរក្រហមចាប់ឪពុកខ្ញុំចងស្លាបសេករួចដាក់ក្នុងយន្តហោះ ។ អ្នកខ្លះទៀតនិយាយថា គាត់ត្រូវខ្មែរក្រហមបោះចូលក្នុងទឹកទន្លេ ប៉ុន្តែប្រហែលជាអ្នកទាំងនោះនិយាយដូច្នេះព្រោះតែចង់ធ្វើឲ្យខ្ញុំអាម៉ាស់មុខក្នុងនាមជាកូនប្រុសរបស់គាត់ ។

ក្រោយមក ម្តាយខ្ញុំក៏បាត់ខ្លួនជាមួយនឹងប្អូនស្រីខ្ញុំដែលទើបតែមានអាយុ៨ខែ ចំណែកខ្ញុំត្រូវអង្គការចាត់តាំងឲ្យធ្វើការនៅសហករណ៍ខេត្តសៀមរាប ។ ◆◆◆

## ដួង ធឿន

### អនុលេខាក្រសួងពាណិជ្ជកម្ម

*(បទសម្ភាសន៍ជាមួយម្តាយឈ្មោះ ស៊ឹម ផេន អាយុ៨២ឆ្នាំ នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម)*



ដួង ធឿន ថតនៅអង្គរវត្ត ប្រហែលក្នុងឆ្នាំ១៩៧៤

ធឿន រៀននៅខេត្តកំពង់ចាម ហើយក្រោយមកប្រឡងជាប់បានធ្វើគ្រូ ។ ប្រពន្ធរបស់ ធឿន ស្លាប់នៅពេលបាញ់កាំភ្លើងធំក្នុងឆ្នាំ១៩៧៣ ។ ក្រោយមក ធឿន ចូលរួមជាមួយខ្មែរក្រហមដោយមិនបានប្រាប់ខ្ញុំសោះ ។ អង្គការបានចាប់ខ្លួនប្រធានរបស់ ធឿន ឈ្មោះ នង សួន ពីបទក្បត់បដិវត្តន៍ ហើយក្រោយមកអង្គការក៏ចាប់កូនប្រុសខ្ញុំនៅឆ្នាំ១៩៧៧ ។ ប្រជាជនខ្សឹបខ្សៀវប្រាប់ខ្ញុំថា កូនប្រុសខ្ញុំត្រូវអង្គការសម្លាប់ហើយ ។

ពីមុនពេលខ្ញុំពុស្សួរម៉ូតូ ខ្ញុំគិតថាកូនប្រុសខ្ញុំត្រឡប់មកវិញហើយ ។ ខ្ញុំយំរៀងរាល់ថ្ងៃ ដោយសារបាត់បង់កូនៗខ្ញុំទាំង៦នាក់នៅក្នុងពេលធ្វើបដិវត្តន៍ ។ ខ្ញុំខំរៀនធម៌អារ្យដើម្បីរំងាប់ចិត្តគំនិត ។ សព្វថ្ងៃនេះខ្ញុំមានអារម្មណ៍គ្រាន់បើជាងមុន ។ ◆◆◆

## ហួន យ៉េង
## គណៈស្រុក ខេត្តក្រចេះ

*(បទសម្ភាសន៍ជាមួយជាប្អូនស្រីឈ្មោះ ហួន យ៉ុម អាយុ៥០ឆ្នាំ នៅស្រុកបាធាយ ខេត្តកំពង់ចាម)*


ហួន យ៉េង មុនចូលបដិវត្តន៍

បងយ៉េង ចូលរួមបដិវត្តន៍ ពេលដែលគាត់មានអាយុ១៨ឆ្នាំ ។ ពុកម៉ែព្យាយាមឃាត់គាត់ដែរ ប៉ុន្តែគាត់នៅតែចង់ទៅ ។ គាត់មកលេងផ្ទះបានពីរដងដែរ ។ គាត់មកដំបូងក្នុងឆ្នាំ១៩៧៣ គឺក្រោយពេលដែលគាត់ត្រូវរបួសហើយទើបនឹងចេញពីពេទ្យថ្មីៗ ។ លើកចុងក្រោយគាត់មកផ្ទះនៅឆ្នាំ១៩៧៥ ។ ក្រោយពីនោះមកគាត់ក៏បាត់ខ្លួនឈឹងតែម្តង ។

ខ្ញុំដឹងរឿងរ៉ាវរបស់គាត់តែត្រឹមនេះទេ ។ សព្វថ្ងៃនេះអ្វីៗចប់អស់ហើយ ។ ◆◆◆

## ញឹប ស្រេង
## មេក្រុមក្រសួងពាណិជ្ជកម្ម

*(បទសម្ភាសន៍ជាមួយប្អូនប្រុសឈ្មោះ ញឹប ស្រ៊ីម អាយុ៤៧ឆ្នាំ នៅស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម)*

បងប្អូនរបស់ខ្ញុំប្រាំនាក់បានចូលធ្វើបដិវត្តន៍ខ្មែរក្រហម ។ យើងទាំងអស់គ្នាមិនមានអ្នកណាមកបង្ខិតបង្ខំទេ គឺយើងស្ម័គ្រចិត្តដោយខ្លួនឯង ដោយសេចក្តីជឿជាក់លើអង្គការ ។ មានតែប្អូនស្រីពៅខ្ញុំឈ្មោះ ទូច ទេដែលនាងមិនបានទៅចូលរួម ។

បងស្រេង ចូលរួមបដិវត្តន៍ នៅឆ្នាំ១៩៧០ គឺពេលដែលគាត់មានអាយុ១៧ឆ្នាំ ។ ប្រធានកងពាណិជ្ជកម្មក្រូចឆ្មារឈ្មោះ ព្រៀម ជាអ្នកបញ្ចុះបញ្ចូលគាត់និងប្រជាជនជាច្រើនទៀតឲ្យទៅធ្វើបដិវត្តន៍ ។ មុនដំបូងគាត់ជានិសាររត់សំបុត្រពីតំបន់មួយទៅតំបន់មួយ ។ ក្រោយមកគាត់ត្រូវបញ្ជូនទៅកំពង់សោម (បច្ចុប្បន្នក្រុងព្រះសីហនុ) ។

នៅឆ្នាំ១៩៧៤ គាត់មកផ្ទះបានបីថ្ងៃ ។ កាលណោះគាត់ជិះម៉ូតូមក ហើយមានកាន់កាំភ្លើងនៅនឹងដៃ ។ គាត់យករូបថតរបស់គាត់មកជាមួយ ។ គាត់ថាគាត់ថតរូបនេះទុកឲ្យបងប្អូន ថែមទាំងប្រាប់យើងថាកុំឲ្យដាក់តាំងរូបនេះ ទាល់តែគាត់ស្លាប់សិនទើបដាក់តាំងបាន ។ គាត់អត់និយាយអ្វីច្រើនទេ ព្រោះគាត់មិនសូវបានសម្តី ។

កាលណោះខ្ញុំមានសុខភាពខ្សោយ ទើបខ្ញុំមិនចាំបាច់វែកដីដូចអ្នកភូមិឯទៀត ។ អង្គការចាត់តាំងឲ្យខ្ញុំនៅខាងថ្នាំបុរាណ ។ យើងផ្សំថ្នាំពីសំបកឈើផ្សេងៗ ។ ខ្ញុំដើរតាមអ៊ំប្រុសម្នាក់ឡើងលើភ្នំដើម្បីរកថ្នាំ ។ ថ្នាំពេទ្យដែលយើងផលិតបានគ្មានប្រសិទ្ធភាពអ្វីទេ ។ ខ្ញុំនៅកងនេះរហូតទាល់តែរបបខ្មែរក្រហមដួលរលំ ។

បងប្រុសបងស្រីរបស់ខ្ញុំត្រូវអង្គការបញ្ជូនទៅភូមិភាគឧត្តរ ។ អ្នកទាំងពីរស្លាប់នៅអំឡុងពេលបដិវត្តន៍ ។ ចំណែកឪពុកខ្ញុំត្រូវខ្មែរក្រហមបាញ់សម្លាប់ពេលដែលគាត់កំពុងដូរស្រូវអង្ករ ។

◆◆◆


ញឹប ស្រេង ថតនៅកំពង់សោម

## ស្រី សំបូរ
## ប្រធានពាណិជ្ជកម្មតំបន់៣២

*(បទសម្ភាសន៍ជាមួយបងស្រីឈ្មោះ អោក ទូច អាយុ៦៧ឆ្នាំ និងក្មួយប្រុសឈ្មោះ អោក សារ៉ា អាយុ៤៨ឆ្នាំ នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ)*

អោក សារ៉ាៈ ពូសំបូរ ចូលព្រៃនៅឆ្នាំ១៩៧០ ។ គាត់មានគម្រោងចង់ទៅរៀនបន្តយកបរិញ្ញាបត្រនៅបរទេស ស្រាប់តែមានរដ្ឋប្រហារធ្វើឲ្យគាត់ខកខាន ។ ពេលសម្តេច សីហនុ អំពាវនាវតាមវិទ្យុឲ្យអ្នកស្នេហាជាតិគ្រប់រូបចូលរួមចលនាតស៊ូនៅក្នុងព្រៃ ពូសំបូរ ក៏ក្លាយខ្លួនជាខ្មែរក្រហមមួយរូប ។

ពូសំបូរ មកលេងផ្ទះជាញឹកញយ ។ មុនឆ្នាំ៧៥ការងាររបស់គាត់គឺនៅកងសេដ្ឋកិច្ចតំបន់៣២ គាត់ទទួលខុសត្រូវឧបត្ថម្ភផ្នែកសេដ្ឋកិច្ចដល់កងទ័ព ។ ដូច្នេះពេលគាត់មកលេងភូមិយើងឃើញប្រជាជនរងទុក្ខលំបាកវេទនា គាត់ក៏ចែកស្រូវអង្ករឲ្យប្រជាជន ។ ជួនកាលគាត់យកថ្នាំពេទ្យមកឲ្យអ្នកភូមិ ។ ពេលគាត់មកម្តងៗ មានឡានធំមួយដឹករបស់អស់ទាំងនោះនិងមាននិរសា ៥ នាក់មកជាមួយផង ។

ក្រោយឆ្នាំ១៩៧៥ ពូសំបូរ ធ្វើជាប្រធានពាណិជ្ជកម្មនៅភ្នំពេញ ។ ខ្ញុំបានទៅលេងគាត់ពីរដងដែរ ។ គាត់មានសម្ភារបរិក្ខារខ្លះ និងមានឡានមួយនៅផ្ទះរបស់គាត់ ។ គាត់ណែនាំខ្ញុំតែមួយម៉ាត់គត់គឺកុំនិយាយច្រើនពេកប្រយ័ត្នអង្គការតាមដានខ្ញុំ ។

អោក ទូចៈ ពេលគាត់មកផ្ទះនៅឆ្នាំ១៩៧៧ គាត់កំពុងធ្វើដំណើរទៅប៉ោយប៉ែតដើម្បីប្រមូលស្បៀង ។ គាត់ថា «ស្ថានការណ៍ឥឡូវនេះ មិនសូវស្រួលទេ ដូច្នេះឯងកុំនិយាយអ្វីប្រឆាំងនឹងអង្គការ ។ ឯងគួរតែធ្វើការងារដែលអង្គការចាត់តាំងវិញប្រសើរជាង ។» ដោយសារគាត់ធ្វើដំណើរទៅជិតព្រំដែន ដូច្នេះងាយស្រួលណាស់ បើគាត់រត់គេចពីខ្មែរក្រហម ប៉ុន្តែគាត់បែរជាវិលត្រឡប់ទៅភ្នំពេញវិញដើម្បីជុំកូនប្រពន្ធ ។

អោក សារ៉ាៈ ស្រីនៅក្នុងរូបថតនេះគឺឈ្មោះ កែវ ជាប្រពន្ធរបស់គាត់ ។ បើតាមខ្ញុំគិតគឺអង្គការជាអ្នករៀបចំអ្នកទាំងពីរជាប្តី



ស្រី សំបូរ ថតនៅទីក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៧៦



កែវ ប្រពន្ធ ស្រី សំបូរ និងប្អូនស្រី

ប្រពន្ធ ។ ពូសំបូរនិងប្រពន្ធគាត់មានកូនពីរនាក់ ។ នៅឆ្នាំ១៩៧៧ មីងកែវ ប្រាប់ខ្ញុំថា ពូសំបូរ បានរត់គេចទៅប៉ោយប៉ែតតាមផ្លូវជាតិលេខ៦ ។ មីងកែវ និយាយទៀតថា ពូសំបូរ បានជួបនឹងម្តាយខ្ញុំនៅភូមិយើង និងបានសុំឲ្យម្តាយខ្ញុំដាំបាយឲ្យគាត់ហូប ។ ខ្ញុំមិនដឹងថាហេតុអ្វីបានជាគាត់ទៅទីនោះទេ ព្រោះពេលនោះខ្ញុំកំពុងតែដេកនៅពេទ្យកំពង់ចាម ។ ខ្ញុំមិនបានឃើញមីងកែវម្តងទៀតទេ ប៉ុន្តែខ្ញុំច្បាស់ថាអង្គការបានសម្លាប់គាត់ និងកូនៗគាត់អស់ហើយ ។

*អោក ទូចៈ* ក្រោយពេលប្អូនសំបូរបាត់ខ្លួន មាននារីមួយក្រុមជិះឡានម៉ូតូពីភ្នំពេញមកដល់ភូមិយើង ។ អ្នកទាំងនោះមកបរិហារអំពីគាត់ចោទថាគាត់ជាជនក្បត់ជាតិ ហើយថែមទាំងនិយាយថា គាត់មានទាំងឡានមានទាំងនាឡិកាហើយនៅចង់បានអ្វីទៀត ។

*អោក សាភ៌ៈ* ក្រោយពេលខ្ញុំចេញពីពេទ្យ ខ្ញុំក៏ត្រូវអង្គការចាប់ខ្លួនដែរ ។ ខ្ញុំមិនដឹងថាហេតុអ្វីបានជាខ្ញុំត្រូវចាប់ខ្លួនទេ ។ ខ្ញុំត្រូវអង្គការឃុំឃាំងនៅជំរំអាចារ្យលាក់ ។ ខ្ញុំត្រូវទទួលរងទារុណកម្មនិងការសួរចម្លើយជាមួយនឹងមនុស្ស១២នាក់ទៀត ។ ក្នុងចំណោមយើងទាំងអស់គ្នា មានតែពីរនាក់ទេដែលនៅរស់មកទល់សព្វថ្ងៃ ។ ខ្ញុំតក់ស្លុតណាស់ពេលដែលខ្មែរក្រហមចោទខ្ញុំថាជាខ្មែរបណ្តាញក្បត់ ។ ខ្ញុំនៅតែមិនទាន់យល់ថាតើអង្គការសំដៅលើខ្មែរបណ្តាញមួយណា ។ នៅចុងឆ្នាំ១៩៧៧ឬដើមឆ្នាំ១៩៧៨ ខ្ញុំត្រូវអង្គការដោះលែងហើយបញ្ជូនទៅព្រំដែនវៀតណាមដើម្បីចូលរួមការប្រយុទ្ធដ៏ធំមួយនៅទីនោះ ។ ក្រោយមកខ្ញុំបានរត់ត្រឡប់មកផ្ទះវិញ ។

ក្រោយពីរបបខ្មែរក្រហមដួលរលំ ខ្ញុំសាកសួរអ្នកដែលបានទៅមើលគុកទួលស្លែងថាតើ មានឃើញអ្វីទាក់ទងនឹងពូសំបូរទេ ។ អ្នកទាំងនោះឃើញតែឈ្មោះ ហៀន តែពូរបស់ខ្ញុំឈ្មោះ ហាន ឈ្មោះ ស្រី សំបូរ (ជាឈ្មោះក្លែងប្រើនៅរបបខ្មែរក្រហម) ។ ឪពុកម្តាយខ្ញុំមានកូន៨នាក់ ហើយស្លាប់នៅក្នុងរបបខ្មែរក្រហមស្ទើរតែទាំងអស់ ។ គ្មានអ្វីអាចមកកែប្រែហេតុ-ការណ៍នេះបានទេ ។

**ចប់**



**រាប់ពីឆ្វេងៈ សួន (និរសារ ស្រី សំបូរ), អត់ស្គាល់, សួត, ស្រី សំបូរ (រូបអង្គុយ), លី (ក្មួយប្រុស ស្រីសំបូរ) និងជឿន ថតក្នុងឆ្នាំ១៩៧៦**

# សុំ រិទ្ធី: សុំប្តឹងតុលាការជាតិនិងអន្តរជាតិជួយរកយុត្តិធម៌

កងទ័ពខ្មែរក្រហមបានចូលលុកលុយក្រុងសៀមរាបនៅយប់ថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ ហើយហាមប្រាមប្រជាពលរដ្ឋមិនឲ្យដើរឆ្លងកាត់ពីកន្លែងមួយទៅកន្លែងមួយទេ ។ ព្រឹកថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពអាវខ្មៅបានស្រែកប្រកាសតាមមីក្រូឲ្យប្រជាពលរដ្ឋ ទាហាន គ្រូបង្រៀន មន្ត្រីរដ្ឋការទៅប្រជុំនៅសាលាខេត្តដើម្បីទទួលផែនការរបស់អង្គការថ្នាក់លើ ។ អង្គការអំពាវនាវឲ្យទាហាន គ្រូបង្រៀន អ្នករដ្ឋការ ចុះឈ្មោះដើម្បីអង្គការរកការងារឲ្យធ្វើ ។ ថ្ងៃបន្ទាប់ អង្គការអំពាវនាវឲ្យប្រជាជននៅក្នុងក្រុងសៀមរាបចាកចេញពីក្រុងសៀមរាបបីបួនថ្ងៃសិន ។

កងទ័ពអាវខ្មៅស្ពាយកាំភ្លើងប្រវែងប្រវាងបញ្ជាប្រជាជនឲ្យរៀបចំអីវ៉ាន់ចាកចេញ ។ ខ្ញុំនិងក្រុមគ្រួសារមានឪពុកម្តាយក្មេក បងថ្លៃប្រុសម្នាក់ បងថ្លៃស្រីម្នាក់ និងប្រពន្ធរបស់ខ្ញុំ បានចាកចេញពីផ្ទះ ដោយរុញរទេះដែលដាក់អីវ៉ាន់បន្តិចបន្តួច ។ តាមផ្លូវមានមនុស្សកកកុញ មានរែក ទូល បណ្តើរគង់ រុញរទេះ កែវភ្នែក ដោយទឹកមុខក្រៀមក្រំនិងភ័យខ្លាច ។

កងទ័ពអាវខ្មៅបានឈរពាសពេញផ្លូវដូចហ្វូងក្អែក ។ ផ្ទះសម្បែងរបស់ប្រជាពលរដ្ឋមានសភាពស្ងាត់ជ្រងំ ខ្ញុំឃើញតែតុ ជើងម៉ា ប្រវែងប្រវាង មាន់ទាជ្រូករត់ប្រសេចប្រសាច ។ មកដល់ផ្លូវបំបែកជាបួននៅមុំសាលាដំបូងខេត្តសៀមរាប ខ្ញុំបានជួបកងទ័ពខ្មែរក្រហមម្នាក់ទៀតដែលមានសៀតកាំភ្លើងខ្លីមួយដើមនៅចង្កេះកំពុងតែដើរសំដៅមករកគ្រួសារខ្ញុំ ហើយសួរខ្ញុំថា គ្រួសារមិត្តឯងធ្វើការអី? ខ្ញុំឆ្លើយថា ខ្ញុំធ្វើជាងម៉ូតូ ឪពុកក្មេកខ្ញុំឆ្លើយថាគាត់ ជាកម្មករ ។ កងទ័ពខ្មែរក្រហមនោះប្រាប់ខ្ញុំឲ្យដើរទៅទិសខាងលិចតាមផ្លូវទៅស្រុកក្រឡាញ់ ។ ឆ្ងាយពីក្រុងសៀមរាបបន្តិច ក្រុមគ្រួសារខ្ញុំបានឈប់សម្រាកដើម្បីសន្សំកម្លាំងបន្តដើរនៅថ្ងៃស្អែកទៀត ។ នៅក្បែរកន្លែងសម្រាកខ្ញុំបានជួបស្ត្រីម្នាក់ ។ គាត់ប្រាប់ខ្ញុំថា គាត់ត្រូវកងទ័ពខ្មែរក្រហមបណ្តេញចេញពីមន្ទីរពេទ្យទាំងឈឺ ហើយអ្នកជំងឺដែលដើរមិនរួចត្រូវកងទ័ពទាំងនោះស្តែងដាក់លើឡានដឹកយកទៅបាត់មិនដឹងយកទៅកន្លែងណា ។ ស្ត្រីនោះនិយាយបណ្តើរយំបណ្តើរព្រោះគាត់បែកពីប្តីនិងកូន ។

ខ្ញុំបានប្តូរឲ្យបងថ្លៃខ្ញុំរុញរទេះម្តង ។ ដើរបានប្រហែលមួយគីឡូម៉ែត្រ ខ្ញុំបានជួបស្ត្រីម្នាក់ទៀតកំពុងដឹកដៃកូនពីរនាក់និងទូលបង្វេចមួយនៅលើក្បាល ។ ស្ត្រីម្នាក់នេះទឹកភ្នែករលីងរលោងនៅពេលឮកូនសួររកឪពុក ស្ត្រីម្នាក់នោះប្រាប់កូនថាអង្គការឲ្យឪពុកកូនទៅរៀនសូត្រ ហើយរកការងារឲ្យធ្វើ ។ ដោយអាណិតកុមារតូចៗទាំងពីរពេក ខ្ញុំក៏លើកដាក់លើរទេះ ។ ថ្ងៃកាន់តែក្តៅ ពោះកាន់តែហេវ ក្រុមគ្រួសារខ្ញុំសម្រាកនៅភូមិទឹកវិលដើម្បីហូបបាយ ។ ពេលធ្វើដំណើរខ្ញុំបានជួបកងទ័ពអាវខ្មៅជិះម៉ូតូបុះឡើង ហើយសួរថាខ្ញុំធ្វើអី ខ្ញុំនៅតែឆ្លើយដូចមុន ។ ម៉ោងប្រហែល៥ល្ងាច ក្រុមគ្រួសារខ្ញុំបានទៅដល់ភូមិខ្នាតហើយសម្រាកនៅក្រោមដើមអម្ពិលធំមួយដើម ។ ភ្លាមនោះកងទ័ពខ្មែរក្រហមពីរនាក់រុញសម៉ូតូមួយគ្រឿងមកឲ្យខ្ញុំជួសជុល ។ ក្រោយពីជួសជុលរួច ខ្មែរក្រហមនោះប្រាប់ខ្ញុំថាកុំទៅណាទៀត ព្រោះអង្គការកំពុងតែរៀបចំកន្លែងឲ្យបងប្អូនស្នាក់នៅ ។ រំលងបានពីរថ្ងៃ អង្គការអនុញ្ញាតឲ្យប្រជាជនទៅយកអីវ៉ាន់នៅតាមផ្ទះ ។ ពេលដែលខ្ញុំនិងបងថ្លៃទៅជិតដល់ក្រុងសៀមរាបស្រាប់តែកងទ័ពអាវខ្មៅដេញឲ្យត្រឡប់ក្រោយវិញ ។

មួយសប្តាហ៍បានកន្លងផុតទៅ កម្មាភិបាលខ្មែរក្រហមម្នាក់ឈ្មោះ សល់ បានមកក្តាប់ភូមិខ្នាត ហើយបានហៅប្រជាជនមកប្រជុំស្តាប់ផែនការរបស់អង្គការ ។ ផែនការរបស់អង្គការគឺថាប្រជាជនធ្វើដំណើរទៅណាមកណាត្រូវតែមានលិខិតអនុញ្ញាតពីអ្នកគ្រប់គ្រងភូមិឃុំស្រុកសិន បើមិនដូច្នេះទេនឹងត្រូវទទួលខុសត្រូវដោយខ្លួនឯង ។

ព្រឹកឡើងប្រជាជនប្រមាណ៥០គ្រួសារដែលគ្មានផ្ទះត្រូវអង្គការបាត់តាំងឲ្យទៅនៅខាងត្បូងភូមិខ្នាត តាមផ្លូវរទេះជិត

គោកខ្មោច ។ ការសង់ជម្រកវេទនាណាស់ ពីព្រោះត្រូវយកខោអាវ សម្ភារ ថ្នាំជក់ ទៅដោះដូរជាមួយប្រជាជនមូលដ្ឋានយកឫស្សី ស្លឹកត្នោត សសរ ទម្រាំគ្រប់យកមកសង់បានជាខ្ទមសម្រាប់ជ្រក ។ ពីមួយថ្ងៃទៅមួយថ្ងៃស្បៀងកាន់តែហោចទៅៗ ។ មិនយូរប៉ុន្មានអង្គការប្រកាសប្រមូលទ្រព្យសម្បត្តិដាក់រួម ហើយបង្កើតជាសហករណ៍ហូបរួម ។ អង្គការបានចាត់តាំងឲ្យអ្នកមូលដ្ឋានគ្រប់គ្រងអ្នក១៧មេសា ។ អង្គការបែងចែកកម្លាំងប្រជាជនទៅធ្វើស្រែ លើកភ្លឺ ជីកប្រឡាយ កាប់ឆ្ការព្រៃ គាស់គល់ឈើ និងដាំដំឡូង ។ អង្គការដាក់ទិសឲ្យប្រជាជនធ្វើស្រែឲ្យបាន៣តោនក្នុងមួយហិកតា ចំណែករបបអាហារមានតែបបររាវៗ ពេលខ្លះមានលាយពោតដំឡូង បុកចូចថែមទៀតផង ។



ថ្ងៃមួយពេលខ្ញុំដើរទៅកាប់ខសនៅលើខ្នងបារាយណ៍ ខ្ញុំបានប្រទះឃើញសាកសពជាច្រើននៅក្នុងលេណដ្ឋានចាស់ៗដែលនៅក្បែរនោះ ។ ខ្ញុំគិតថាសាកសពទាំងនោះប្រហែលជាគ្រូបង្រៀន ទាហាន និងអ្នករដ្ឋការដែលអង្គការដាក់ឡានឲ្យទៅរៀនសូត្រតាំងពីពេលចេញពីទីក្រុងសៀមរាបដំបូងម៉្លេះ ។

ឆ្នាំ១៩៧៦ ផែនការសម្រុកបង្កបង្កើនផលកាន់តែប្រញឹកឡើងៗ របបហូបចុកកាន់តែតិចទៅៗ ខ្លួនខ្ញុំធ្លាក់ខ្លួនឈឺស្គមស្គាំង ។ អង្គការចាត់តាំងខ្ញុំនិងមិត្តរួមការងារចំនួន៥នាក់ទៅបោចវល្លិ៍នៅបរិវេណព្រៃខាងត្បូងអង្គរវត្ត ពេលនោះខ្ញុំបានឃើញឆ្អឹងខ្មោចជាច្រើន ។ នៅភូមិខ្ញុំអង្គការបានបែងចែកការងារតាមកម្លាំង បុរសវ័យចំណាស់ធ្វើរទេះគោ បង្គី ត្បាល់កិនស្រូវ វេញខ្សែគោក្របី ។ យាយចាស់ៗ កាប់ដើមរំចេកយកមកធ្វើកន្ទេលហាលស្រូវ និងមើលកុមារ ។ មនុស្សពេញកម្លាំងបង្កបង្កើនផលគ្រប់យ៉ាង ។ យុវជន យុវនារី ធ្វើការនៅក្នុងកងចល័តភូមិឃុំស្រុកនិងតំបន់ ។ កុមារត្រូវអង្គការចាត់តាំងឲ្យឃ្វាលក្របី រើសអាចម៍គោ និងកាប់ដើមទន្ទ្រានខែត្រធ្វើជី ។ លើសពីនេះទៀត អង្គការចាត់តាំងឲ្យប្រជាជនមូលដ្ឋានតាមដានប្រជាជន១៧មេសា បើនរណាមិនធ្វើការ អង្គការចោទថាក្បត់បុរខ្នាំង ។

អង្គការមហាអស្ចារ្យមហាលោតផ្លោះបានដាក់ផែនការឲ្យប្រជាជនភូមិខ្ញុំធ្វើស្រែក្រោម ស្រែលើ ស្រែប្រដេញទឹក ទាំងយប់ទាំងថ្ងៃ ប៉ុន្តែនៅពេលបានផល ប្រជាជនមិនដែលបានហូបគ្រប់គ្រាន់ទេ ហើយក៏គ្មាននរណាម្នាក់ហ៊ានតវ៉ាប្រឆាំងនឹងអង្គការដែរ ។ ប្រជាជនខ្លះបានយកគល់ចេក គល់ល្ហុង ត្រកួន ស្លឹកបាស ស្លឹកត្រាច ស្លឹកដំឡូង ស្លឹកថ្មី មកលាយជាមួយបបរគ្រាន់ចម្អែតក្រពះបានមួយពេលៗ ។ ខ្ញុំលួចកាប់គាស់ដីនៅពេលយប់ដើម្បីដាំដំឡូងឈើនិងដំឡូងជ្វាបន្តិចបន្តួចរហូតធ្លាក់ខ្លួនឈឺ ។ ក្រោយមកទៀតអង្គការចាត់តាំងខ្ញុំឲ្យទៅកាប់ឫស្សីនៅស្រុកលើភូមិរលំដើងស្ពានដែលជាកន្លែងជនជាតិភាគតិចរស់នៅរយៈពេលមួយខែ និងទៅកាប់ផ្ទៀងនង្គ័លនៅបរិវេណបារាយណ៍ជ្រុងខាងកើតរយៈពេលពីរខែ ។ បន្ទាប់មកអង្គការឲ្យខ្ញុំទៅភ្ជួរស្រែក្រោមនៅវាលរនាម ។ ថ្ងៃមួយបុរសម្នាក់ត្រឡប់ទៅផ្ទះដោយមិនបានសុំការអនុញ្ញាតត្រូវអង្គការវាយធ្វើបាប ហើយចងគាត់ឲ្យរត់តាមពីក្រោយសេះ ។ ចាប់តាំងពីពេលនោះខ្ញុំមិនដែលឃើញបុរសនោះទៀតទេ ។ មានម្តងនោះ ស្ត្រីមានផ្ទៃពោះម្នាក់ដួលនៅលើភ្លឺស្រែ ឈ្លបខ្មែរក្រហមបានចោទស្ត្រីនោះថាខ្ជិលធ្វើការ ហើយឡើងជាន់ពោះស្ត្រីនោះរហូតដល់ធ្លាក់ឈាមស្លាប់នៅនឹងកន្លែង ។ ពួកយើងដែលជាអ្នក១៧មេសាដូចគ្នា ឃើញអំពើឃោរឃៅបែបនេះ

បានពិគ្រោះគ្នាថា បើថ្ងៃក្រោយមានហេតុការណ៍យ៉ាងណាៗ ឬខ្មែរក្រហមចាប់ពួកយើងយកទៅសម្លាប់ដោយគ្មានកំហុស សូមអ្នកដែលនៅរស់ជួយរកយុត្តិធម៌ឲ្យអ្នកស្លាប់កុំខាន ។

យប់មួយនៅពាក់កណ្តាលអធ្រាត្រដើមឆ្នាំ១៩៧៧ ពេលខ្ញុំកំពុងដេក ឈ្លបខ្មែរក្រហមមួយក្រុមប្រដាប់ដោយអាវុធគ្រប់ដៃបានឡើងមកចាប់ខ្ញុំនៅលើខ្ទម ហើយវាយខ្ញុំនឹងស្នូកកាំភ្លើងរហូតដល់លេចនោមដាក់ខោ ។ ឈ្លបបានចងស្លាបសេកនិងដាក់ខ្នោះដៃខ្ញុំ ។ បងថ្លៃប្រុសរបស់ខ្ញុំក៏ត្រូវចាប់ខ្លួននៅថ្ងៃនោះដែរ ។ ខ្មែរក្រហមបណ្តើរខ្ញុំនិងបងថ្លៃទៅកាន់រថយន្ត ។ ម្តាយក្មេកខ្ញុំស្រែកថា «យកកូនខ្ញុំទៅណា?» ឈ្លបគំរាមម្តាយក្មេកខ្ញុំថា «អញចាប់តែខ្មាំងក្បត់អង្គការទេ» ។ នៅលើរថយន្តខ្ញុំឃើញមានអ្នកទោសប្រមាណជា១០នាក់ផ្សេងទៀត ។ ខ្មែរក្រហមបានបញ្ជូនយើងទៅដាក់នៅមន្ទីរឃុំឃាំងខេត្តសៀមរាប ។ ដៃទាំងពីររបស់ខ្ញុំហើមជើងទាំងពីររបស់ខ្ញុំជាប់ខ្នោះ ខ្ញុំឈឺចាប់ស្នាមរបួសដែលខ្មែរក្រហមវាយខ្ញុំ ។ ខ្ញុំងាកមើលជុំវិញខ្លួនឃើញអ្នកទោសនៅខាងក្រៅប្រហែល៣០០នាក់ជាប់ខ្នោះទាំងស្រីទាំងប្រុសដេកតម្រៀបជាជួរៗ ។ ព្រឹកឡើងកងទ័ពខ្មែរក្រហម៥នាក់កាន់សៀវភៅមកកត់ឈ្មោះនិងសួរប្រវត្តិរូបអ្នកទោសចូលថ្មី ។ ឈ្លបសួរខ្ញុំថា ពីមុនធ្វើអ្វីខ្លះ ។ ខ្ញុំឆ្លើយថាខ្ញុំជាជាងម៉ូតូ ។ នៅក្នុងគុកនេះខ្ញុំបានទទួលរបបបបររាវនិងសម្លដែលមានបន្លែដើមចេកស្លឹកសាវម៉ាវ ឬស្លឹកបាស ។ អ្នកទោសស្ត្រីពីរនាក់ជាអ្នកដាំស្លឲ្យអ្នកទោសទាំងអស់ ។

ក្រោយមក ឈ្លបខ្មែរក្រហមបានយកខ្ញុំទៅដាក់នៅបន្ទប់ថ្មតូចៗដែលមួយបន្ទប់ដាក់អ្នកទោសបានតែពីរនាក់ប៉ុណ្ណោះ ។ នៅក្នុងបន្ទប់នោះមានកូនពាងមួយនិងម្ពកដែកមួយសម្រាប់ដាក់ទឹកនោមនិងលាមក ។ បីថ្ងៃបន្ទាប់ ខ្មែរក្រហមបានយកអ្នកទោសម្នាក់ទៀតមកដាក់បន្ទប់ជាមួយខ្ញុំដែរ ។ គាត់នោះឈ្មោះ ស៊ីម ជាគណៈស្រុកជីក្រែង អង្គការចោទគាត់ថាក្បត់បដិវត្ត ។ ព្រឹកឡើងឈ្លបមកនាំ បងស៊ីម ទៅសួរចម្លើយ ។ ថ្ងៃជិតត្រង់ អ្នកយាមបណ្តើរ បងស៊ីម មកវិញ ។ បន្តិចក្រោយមក អ្នកយាមយកបាយមួយកូនចាននិងសម្លមួយកូនចានមកឲ្យ បងស៊ីម ហូប ។ ខ្ញុំបានត្រឹមតែលេបទឹកមាត់ ហើយប្រាសខ្លួនដេកនៅលើថ្ម ។ បងស៊ីម ហូបបាយទាំងដៃជើងជាប់ខ្នោះនិងទឹកមុខក្រៀមក្រំ ។ បងស៊ីម ហូបបាយតែពាក់កណ្តាលទុកឲ្យខ្ញុំពាក់កណ្តាល ។ ពេលរសៀលអ្នកយាមគុកបានមកបណ្តើរ បងស៊ីម ទៅសួរចម្លើយទៀត ។ នៅក្នុងដៃរបស់អ្នកយាមគុកម្នាក់ៗមានកាន់កូនសោ ដំបង ពូថៅ ដែកបំពង់ទីប ញញួរ ឈើច្រត់ មានកាំបិតនៅពីក្នុង រំពាត់ខ្សែភ្លើងវេញចូលគ្នា ។ ល្ងាចបន្តិច អ្នកយាមបណ្តើរ បងស៊ីម មកវិញ ។ រាល់ពេលដែលគាត់បានរបបបាយ បងស៊ីម តែងតែចែកឲ្យខ្ញុំពាក់កណ្តាលជានិច្ច ។ បងស៊ីម ខ្សឹបប្រាប់ខ្ញុំថា គាត់មិនឲ្យឈឺខ្លួននៅមុនពេលស្លាប់ទេ បើអង្គការសួរថាក្បត់ គាត់ឆ្លើយថាក្បត់ គាត់សុខចិត្តឆ្លើយស្របនឹងសំណួររបស់អង្គការ ។ មិនក្បត់ក៏ស្លាប់ ក្បត់ក៏ស្លាប់ ។

ប៉ុន្មានថ្ងៃក្រោយមក អ្នកយាមគុកបានដោះខ្នោះខ្ញុំ ហើយថាឲ្យទៅធ្វើម៉ូតូ ។ អ្នកយាមម្នាក់បណ្តើរខ្ញុំទៅសាលាដំបូង ។ ខ្ញុំឃើញឡានឃ្លុបមួយគ្រឿង ម៉ូតូបីគ្រឿងនិងកូនសោសម្រាប់ជួសជុលម៉ូតូ និងកងទ័ពខ្មែរក្រហម៦នាក់នៅទីនោះ ។ កងទ័ពម្នាក់ប្រាប់ខ្ញុំថា «ហ្អែងធ្វើម៉ូតូបីគ្រឿងនេះឲ្យបានល្អ បើធ្វើមិនបានទេអញសម្លាប់ចោល» ។ ខ្ញុំខំប្រឹងជួសជុលម៉ូតូទាំងញ័រដៃទទ្រើកព្រោះចង់បង្ហាញឲ្យខ្មែរក្រហមឃើញថាខ្ញុំពិតជាជាងម៉ូតូមែន ។ ពេលថ្ងៃត្រង់ អ្នកយាមបានបណ្តើរខ្ញុំចូលបន្ទប់ឃុំឃាំងវិញ ហើយពេលរសៀលអ្នកយាមគុកបណ្តើរខ្ញុំចេញទៅធ្វើការទៀត ។

ព្រឹកមួយ ពេលខ្ញុំចេញទៅធ្វើការដូចរាល់ដង ស្រាប់តែកងទ័ពខ្មែរក្រហមវ័យក្មេងម្នាក់លោតចុះពីលើរថយន្តអា-២ មកសម្លុតខ្ញុំថា «ហ្អែងចេះធ្វើម៉ូតូតាំងពីឆ្នាំណា?» ខ្ញុំឆ្លើយថា «ខ្ញុំបាទចេះជួសជុលម៉ូតូតាំងពីឆ្នាំ១៩៦៨ម្ល៉េះ» ។ ឈ្លបសួរខ្ញុំទៀតថា «ហ្អែងធ្លាប់ធ្វើទាហានទេ?» ។ ខ្ញុំតបទៅវិញថា «ខ្ញុំមិនធ្លាប់ទេ» ។

រំលងបាន២០ថ្ងៃ ឈ្លបមកយក បងស៊ីម ទៅសម្លាប់ចោល ។ ឈ្លបបានឲ្យ បងស៊ីម ស្លៀកពាក់ ខោអាវថ្មីៗ និងរៀបបាយមួយថាសឲ្យគាត់ហូបទល់មុខប្រពន្ធដែលជាប្រធាននារីស្រុកជីក្រែង (ត្រូវចាប់ខ្លួនមកឃុំឃាំងនៅក្នុងគុកនេះដែរ) ។ បន្ទាប់មកឈ្លប

យក បងស៊ឹម ចេញទៅជាមួយអ្នកទោសប្រហែល១០០នាក់ទៀត ។ ចំណែកប្រពន្ធរបស់ បងស៊ឹម ក៏ត្រូវអ្នកយាមវាយធ្វើទារុណកម្មរហូតដល់ហើមមុខមាត់ដៃជើងដើរស្ទើរមិនរួច ហើយយកគាត់ទៅសម្លាប់នៅពេលក្រោយ ។

ខ្ញុំត្រូវខ្មែរក្រហមប្តូរទៅបន្ទប់ធំដែលមានអ្នកទោស៥០នាក់នៅក្នុងនោះ ។ ព្រលឹមឡើង ខ្ញុំត្រូវឈ្លបបណ្តើរឲ្យទៅជួសជុលម៉ូតូសេ-៩០របស់កូនគណៈភូមិភាគ ។ ពីមួយថ្ងៃទៅមួយថ្ងៃរាងកាយខ្ញុំកាន់តែចុះខ្សោយជាលំដាប់ ។

ខ្ញុំអស់សង្ឃឹមក្នុងជីវិត គិតថាប្រហែលជាមិនបានវិលត្រឡប់ទៅជួបមុខប្រពន្ធកូនទេ ។ ខ្ញុំហូបសព្វគ្រប់ទាំងអស់តាំងពីសត្វចង្រិត កណ្តូប កង្កែប គីង្គក់ កូនក្អាត់ ក្តាម ស្លឹកឈើព្រៃ ឬអ្វីក៏ដោយដែលខ្ញុំអាចរកបាន ។

ថ្ងៃមួយ កម្មាភិបាលវ័យក្មេងបានយកកង់មកឲ្យខ្ញុំលាបនៅក្នុងបរិវេណវត្តធម្មយុត្តិ ។ នៅជុំវិញ ខ្លួនខ្ញុំមានកម្មាភិបាលខ្មែរក្រហមជាច្រើននាក់ឈរមើលខ្ញុំលាបកង់ ។ ឃើញខ្ញុំលាបស្អាត គ្រប់គ្នាក៏យកកង់មកឲ្យខ្ញុំលាបជាបន្តបន្ទាប់ ។

អ្នកទោសទាំងអស់ដែលចេញទៅធ្វើការ រួមទាំងរូបខ្ញុំផ្ទាល់ផង មុននឹងធ្វើអ្វីត្រូវតែសុំអនុញ្ញាតពីអ្នកយាម សូម្បីតែបត់ជើងតូច-ធំ ឬរើសអ្វីយកមកស៊ី ឬសូម្បីតែដឹកទឹកក៏ត្រូវសុំដែរ បើមិនដូច្នោះទេ នឹងត្រូវអ្នកយាមវាយធ្វើបាបតាមតែអំពើចិត្ត ។ ថ្ងៃមួយដោយឃ្លានខ្លាំងពេក ខ្ញុំបានកេះក្តាំងបបរមួយដុំតូចយកមកហូប អ្នកយាមគុកឃើញក៏យកច្រវាមកវាយខ្ញុំចំកញ្ចឹងកបែកអំពិលអំពែក ។ ពេលមួយទៀត ដោយមិនបានសុំការអនុញ្ញាត ខ្ញុំរើសគ្រាប់ខ្នុរដែលអ្នកយាមបោះចោលទៅដី ។ ភ្លាមនោះ អ្នកយាមម្នាក់ទៀតបានហៅខ្ញុំទៅលុតជង្គង់ ហើយវាយនឹងព្រនង់បួនជ្រុងចំត្រង់ចង្កេះ ។ ពេលមួយទៀត ខ្ញុំកំពុងតែសែងឆ្នាំងបបរជាមួយអ្នកទោសម្នាក់ទៀត ដោយខ្ញុំនៅខាងមុខ ។ ពេលនោះ អ្នកយាមគុកឈ្មោះ សំ បានរុញអ្នកសែងពីក្រោយធ្វើឲ្យជង់ស្នែងរុលមកមុខ ។ ខ្ញុំទន់ក្បាលជង្គង់ដួលស្រ៊ុប ។ បបរដែលទើបតែដាក់ចុះពីចង្ក្រានបានស្រោចមកលើខ្ញុំតាំងពីក្បាលដល់ចុងជើង ។ ជើងទាំងពីរ ដៃម្ខាង ខ្លួនប្រាណ និងទ្រូងរបស់ខ្ញុំក្តៅអន្ទះអន្ទែងដូចគេយកភ្លើងមកដុត ។ ខ្ញុំគ្មានថ្នាំព្យាបាលទេ ខ្ញុំយកគល់ចេករលួយៗមកជ្រលក់ប្រេងម៉ាស៊ីនចាស់ៗលាបលើមុខរបួស ។ ក្បាលខ្ញុំហូរទឹករងៃឥតឈប់ ។ ខ្ញុំបានពឹងអ្នកទោសដែលចេញទៅធ្វើការនៅខាងក្រៅឲ្យជួយរកដើមសំបកកណ្តោលយកមកស្ងោរដឹកនិងលាងមុខរបួស ។ រយៈពេល៧ថ្ងៃ

**រូបភាពដោយៈ សុំ រិទ្ធី**
**ជាសកម្មភាពដែលគាត់បានឃើញនិងជួបប្រទះនៅក្នុងអំឡុងពេលជាប់មន្ទីរឃុំឃាំងសៀមរាបរយៈពេលជិតមួយឆ្នាំ។**





ខ្លួនរបស់ខ្ញុំហើមដូចខ្មោច ខ្ញុំរស់យ៉ាងវេទនា ។ អស់រយៈពេលបីខែទើបដំបៅរបស់ខ្ញុំបានជាសះស្បើយ ។

ប្រសិនបើអ្នកទោសណាលួចរត់នឹងត្រូវអ្នកយាមវាយរហូតដល់ស្លាប់ ។ ខ្ញុំបានឃើញអ្នកយាមបណ្តើរក្មេងប្រុសម្នាក់វាយផងសួរផងថា «ហេតុអីបានជាអែ្ហងរត់?» ក្មេងនោះឆ្លើយ

ថា «ខ្ញុំនឹកឪពុកម្តាយពេក»។ អ្នកយាមនោះសំពងមួយដំបងចំកណ្តាលខ្នងក្មេងប្រុសនោះហើយប្រាប់ថា «ម៉ែអ្ហែង អញយកទៅសម្លាប់ចោលអស់ហើយ អាកូនក្បត់!»។ បានតែមួយយប់ ក្មេងនោះត្រូវអ្នកយាមយកទៅសម្លាប់ចោល។

ថ្ងៃមួយទៀត អ្នកយាមគុកបានប្រើខ្ញុំនិងអ្នកទោសម្នាក់





ទៀតឈ្មោះ សី ឲ្យទៅជួសជុលឡាននៅសាលាដំបូង។ នោះជាប្រភេទឡានឃ្យុបម៉ាក៨-៨របស់អាមេរិក ដែលទាហានលន់នល់ប្រើជាឡានពេទ្យទាហាន។ ធ្វើឡានបណ្តើរ មិត្តសី និយាយប្រាប់ខ្ញុំតិចៗបណ្តើរថា «អារិទ្ធ! ឯងដែលឃើញកាំបិតកាប់មនុស្សទេ?» ខ្ញុំឆ្លើយថា «អញមិនដែលបានឃើញទេ»។ មិត្តសី ប្រាប់ថា «បើឯងចង់ឃើញ ឯងទៅមើលនៅក្រោយកៅអីអ្នកបើកឡានទៅនឹងឃើញហើយ»។ នៅពេលស្ងាត់ៗ ខ្ញុំក៏ដើរទៅលបមើលនៅក្រោយកៅអីអ្នកបើកឡានឃើញមុខកាំបិតបួនប្រឡាក់សុទ្ធតែឈាម មុខកាំបិតឆែបដូចមុខរណារ ហើយមានច្រែះផង។

ថ្ងៃមួយ ខ្ញុំកំពុងធ្វើការនៅជិតរោងដំដែក។ កងទ័ពខ្មែរក្រហមម្នាក់ឈ្មោះ ប្រុញ មកប្រើជាងដំដែកឲ្យដំកាំបិតពីរដែលមានប្រវែង៥តឹក ទទឹងក១តឹក៣ហ៊ុន ដងមូលធំបន្តិចប្រវែង៣តឹក។ ប្រុញ និយាយថា «កាំបិតពីលើកមុនកាប់មិនសូវស្រួលសោះ ជាងឯងធ្វើលើកនេះកាប់ឲ្យបានស្រួលមើល៍បើមិនស្រួលប្រយ័ត្នស្លាប់ជាងឯង»។ ឮដូច្នោះខ្ញុំព្រឺក្បាលខ្លាក។

ក្រៅពីជួលជុលម៉ូតូ ខ្ញុំត្រូវធ្វើការផ្សេងៗទៀត ដូចជាជួយសែងឆ្នាំងបបរ ជួយចែកម្ហូបដែកសម្រាប់ដាក់បបរឲ្យអ្នកទោសសែងទឹកនោមនិងលាមកលាយធ្វើជី សែងខ្មោចអ្នកទោសយកទៅកប់។ល។ ដោយខ្ញុំធ្វើការនៅបរិវេណគុក ដូច្នេះជារៀងរាល់ថ្ងៃ ខ្ញុំឃើញឡានឃ្យុបជាច្រើនដឹកអ្នកទោសថ្មីៗចូលនិងដឹកអ្នកទោសចាស់ចេញទៅវិញ។ ជាមធ្យមក្នុងមួយថ្ងៃមានអ្នកទោសចូលថ្មីប្រមាណពី២០០ទៅ៣០០នាក់ ហើយអ្នកទោសចាស់ដែលត្រូវយកទៅសម្លាប់ក៏មិនតិចជាងនេះដែរ។ ថ្ងៃខ្លះខ្មែរក្រហមបញ្ចេញអ្នកទោសទៅសម្លាប់ពីរដង ពេលព្រឹកម្តង ពេលល្ងាចម្តង។ អ្នកទោសនៅក្នុងគុកនេះមានរាងកាយស្គមស្គាំងដោយសារខ្វះអាហារ បន្ថែមពីលើនេះត្រូវឆ្មាំគុកវាយធ្វើបាបនិងធ្វើទារុណកម្មទៀតពេលសួរចម្លើយម្តងៗ។ បន្ទប់គុកនីមួយៗធុំក្លិនស្អុយអសោចិ៍ដូចឋាននរក។ អ្នកទោសមួយចំនួនបានស្លាប់នៅក្នុងបន្ទប់គុកមួយចំនួនទៀតបានធ្វើអត្តឃាតដោយខាំអណ្តាតចងក លោតទម្លាក់ខ្លួនក្នុងអណ្តូង ចាក់ផ្តាច់សរសៃឈាមខ្លួនឯង ។ល។ គ្មានថ្ងៃណាដែលថាមិនមានអ្នកទោសស្លាប់ក្នុងគុកទេ។ ដូច្នេះរៀងរាល់ល្ងាច ខ្ញុំត្រូវដើរសួរតាមបន្ទប់តើមានអ្នកទោសស្លាប់ឬទេ ស្លាប់ប៉ុន្មាននាក់។ ខ្មោចដែលត្រូវយកទៅកប់គ្មានអ្វីសម្រាប់រុំទេ គឺចងបីចំណងភ្ជាប់នឹងឈើស្នែងត្រង់កមួយចំណងខ្លួនមួយចំណង និងកជើងមួយចំណង។ ខ្មោចទាំងនោះត្រូវយកទៅកប់នៅក្នុងវត្តធម្មយុត្តិឬនៅខាងលិចវត្ត។ យើងកាប់រណ្តៅ

ឲ្យធំបន្តិចដែលអាចដាក់ខ្មោចបានពី៥ទៅ១០នាក់ ។ ថ្ងៃខ្លះយើងត្រូវសែងបីបួនដងទើបអស់ខ្មោចដែលត្រូវកប់ ។ ពេលសែងខ្មោចទៅកប់ មានអ្នកយាមម្នាក់ដើរតាមយើងជាប់រហូត ។ កប់ខ្មោចរួចយើងសុំអ្នកយាមបេះត្រកួនបានម្នាក់មួយក្តាប់យកមកស្ងោរហូប ។

កងទ័ពខ្មែរក្រហម ដែលធ្វើការនៅក្នុងមន្ទីរឃុំឃាំងនេះ មានមិនលើសពី៦០នាក់ទេ ។ ជារៀងរាល់ថ្ងៃ អ្នកយាមមករាប់ចំនួនអ្នកទោសនិងកត់ត្រាចូលក្នុងបញ្ជីយ៉ាងទៀងទាត់ ។ កងទ័ពវ័យក្មេងទាំងនោះជេរប្រមាថមាក់ងាយនិងវាយដំអ្នកទោសស្រេចតែអំពើចិត្ត ។ រស់នៅក្នុងគុកអស់រយៈពេលជិតពីរឆ្នាំ នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំនិងអ្នកទោស២៨នាក់ទៀតត្រូវបានដោះលែងពីគុក ហើយបញ្ជូនទៅកន្លែងលត់ដំនៅស្ពានមេម៉ាយ ហៅស្ពានស្រែងស្រុកក្រឡាញ់ ចម្ងាយពីខេត្តសៀមរាប ៥៥គីឡូម៉ែត្រ ។ មុននឹងចេញទៅ ប្រធានគុកឈ្មោះ សុង ណែនាំពួកខ្ញុំថា «ពួកឯងខំធ្វើការតាមការចាត់តាំងរបស់អង្គការកុំឲ្យចូលមកកន្លែងនេះម្តងទៀត ឯងគ្រប់គ្នាដឹងហើយ» ។ ប្រធានគុកថែមទាំងឲ្យកូនជ្រូកចំនួន១២ក្បាលមកពួកខ្ញុំថែមទៀត ។ ពេលដែលរថយន្តបើកចេញពីមន្ទីរឃុំឃាំងហើយបត់តាមផ្លូវជាតិមកទិសខាងលិច ទើបខ្ញុំដឹងថាជីវិតខ្ញុំបានរស់ម្តងទៀតហើយ ។ រថយន្តមកដល់ភូមិព្រៃជ្រូក ទើបឈប់ដាក់ពួកខ្ញុំឲ្យចុះដើរបន្តអស់ពេលមួយព្រឹកទើបទៅដល់ភូមិស្ពានមេម៉ាយ ។ ខ្ញុំធ្វើការនៅកន្លែងនោះបាន៧ថ្ងៃ ទើបដឹងថាប្រពន្ធ កូនស្រីនិងម្តាយក្មេករបស់ខ្ញុំត្រូវខ្មែរក្រហមជម្លៀសពីភូមិខ្នាតទៅភូមិគោកល្ហុង ចម្ងាយបួនគីឡូម៉ែត្រពីស្ពានស្រែង ។

ព្រឹកថ្ងៃ៧មករា ឆ្នាំ១៩៧៩ រថក្រោះរបស់កងទ័ពវៀតណាមបានមកដល់ភូមិគោកល្ហុង ។ ខ្ញុំនិងក្រុមគ្រួសារបានធ្វើដំណើរអស់រយៈពេលពីរថ្ងៃទើបទៅដល់ភូមិគោកខ្នាត ។ ប្រាំថ្ងៃបន្ទាប់ ខ្ញុំបានមកដល់ខេត្តសៀមរាប ។ បន្ទាប់មកខ្ញុំបានធ្វើដំណើរមកភូមិកំណើតរបស់ខ្ញុំនៅខេត្តបាត់ដំបងដើម្បីជួបឪពុកម្តាយនិងបងប្អូន ។ ម្តាយខ្ញុំស្ទុះមកឱបខ្ញុំហើយទ្រហោយំ ។ ក្នុងចំណោមបងប្អូនរបស់ខ្ញុំទាំងអស់មានតែប្អូនរបស់ខ្ញុំពីរនាក់ប៉ុណ្ណោះដែលនៅរស់ ។ ឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមយកទៅសម្លាប់ ។ បងប្រុសពីរនាក់ឈ្មោះ ដា និង ថា ត្រូវស្លាប់ដោយអត់អាហារ ។ ប្អូនប្រុសពៅរបស់ខ្ញុំឈ្មោះ ណារ៉េត ត្រូវខ្មែរក្រហមអារ-កនឹងកាំបិត ។ អារ-កលើកទី១ ណារ៉េត មិនទាន់ស្លាប់ហើយវារចេញពីរណ្តៅមកវិញ ឈ្លបឃើញដូច្នោះក៏ស្ទុះទៅចាប់ ណារ៉េត អារ-កម្តងទៀតរហូតដល់ស្លាប់ ។ បងថ្លៃស្រីម្នាក់ត្រូវខ្មែរក្រហមយកប្តីរបស់គាត់ទៅសម្លាប់ ក្លាយជាស្ត្រីមេម៉ាយដែលមានកូនក្នុងបន្ទុក៥នាក់ ។ បងថ្លៃស្រីឈ្មោះ ទន់ ត្រូវខ្មែរក្រហមចាក់សាំងដុតទាំងរស់ បន្សល់ទុកកូនបីនាក់ ។ អ្នកទាំងអស់ស្លាប់ដោយខ្ញុំមិនបានឃើញឆ្អឹងឡើយ ។

ខ្ញុំរស់រានមានជីវិតមកដល់សព្វថ្ងៃនេះដោយសារជំនាញជួសជុលម៉ូតូរបស់ខ្ញុំ ។ ខ្ញុំសូមអំពាវប្រជាពលរដ្ឋខ្មែរនៅក្នុងប្រទេសក្តីនិងក្រៅប្រទេសក្តី កុំជឿពួកកុម្មុយនិស្តដាច់ខាត ។ ខ្ញុំសូមប្រកាសឲ្យបងប្អូនរួមជាតិខ្មែរនិងអន្តរជាតិដឹងថាខ្ញុំស្រឡាញ់របបប្រជាធិបតេយ្យ ។ ខ្ញុំឈ្មោះ សុំ រិទ្ធី សូមប្តឹងដល់តុលាការជាតិនិងអន្តរជាតិ សូមជួយរកយុត្តិធម៌ឲ្យរូបខ្ញុំបាទនិងប្រជាពលរដ្ឋខ្មែរស្លូតត្រង់ដែលស្លាប់ទៅចំនួន៣លាននាក់ ។ សូមជួយកាត់ទោសពួកខ្មែរក្រហមឲ្យបានឆាប់ កុំពន្យារពេលតទៅទៀត ។

**សុំ រិទ្ធី**

## ពន្យល់ពាក្យខ្មែរក្រហម

- **ជនកុម្មុយនិស្ត៖** គឺជាអ្នកអង់អាចក្លាហានពុះពារនូវរាល់ឧបសគ្គគ្រប់បែបយ៉ាង មោះមុត ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង មានការលះបង់សួនតួ បុគ្គលអាត្មាខ្លួនរហូតដល់ជីវិតខ្លួនទៀតក៏ឥតរុញរា ។ រូបភាពគឺជាមនុស្សដូចគ្នា តែខ្លឹមសារវិញខ្ពស់ឧត្តុង្គឧត្តមណាស់ ។

(កំណត់ហេតុលេខ១២ កណាហ១៨១)

- **គោលនយោបាយ៖** ទិសដៅដំណើរការបដិវត្តន៍ឬការវិវត្ត ។
- **មាគ៌ានយោបាយ៖** សេចក្តីផ្តើមគំនិត ។
- **មនោគមវិជ្ជា៖** សេចក្តីជំនឿផ្សេងៗ ។

កំណត់ហេតុ (TSL N-97, N-11 លេខៈ១០)

# សេចក្តីប្រកាសរកឪពុកម្តាយនិងប្អូន៦នាក់

ខ្ញុំបាទឈ្មោះ ស៊ុន ស៊ីវ៉ា អាយុ៥៣ឆ្នាំ សព្វថ្ងៃរស់នៅផ្ទះលេខ៦៣ ផ្លូវលេខ១៥០ ក្រុម៣៥ ភូមិ៦ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន ក្រុងភ្នំពេញ ក្បែរសារមន្ទីរទួលស្លែង។ សូមសួររកក្រុមគ្រួសារឈ្មោះ ស៊ុន ជូ ជាគ្រូបង្រៀននៅសាលាវត្តថ្មស ខេត្តកំពង់ឆ្នាំង ត្រូវជាឪពុក ឈ្មោះ ឃឹម ថុន ត្រូវជាម្តាយនិងប្អូនៗចំនួន៦នាក់ទៀត។ អ្នកទាំងអស់នេះមានឈ្មោះដូចតទៅ÷

១) ប្អូនប្រុស ស៊ុន សាររឿន ២) ប្អូនស្រី ស៊ុន សុផានី ៣) ប្អូនស្រី ស៊ុន សុផាណា ៤) ប្អូនស្រី ស៊ុន សុផល្លា ៥) ប្អូនស្រី ស៊ុន សុមាលី និង៦) ស៊ុន សាវ៉ាន់ នៅកុមារ មានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំងម្តុំខាងមុខវត្តអារញ្ញ ដែលបានបែកគ្នាក្នុងឆ្នាំ ១៩៧៥ ដោយរូបខ្ញុំបាទ ស៊ុន ស៊ីវ៉ា មកបន្តការសិក្សាមុខវិជ្ជាពេទ្យនៅក្រុងភ្នំពេញ។ ក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ រូបខ្ញុំបាទបានទៅរកក្រុមគ្រួសារនៅខេត្តកំពង់ឆ្នាំង ហើយទទួលដំណឹងពីអ្នកជិតខាងថា គ្រួសារខ្ញុំបាទត្រូវពួកខ្មែរក្រហមសម្លាប់ចោលទាំងអស់នៅក្រោយថ្ងៃរំដោះខែមេសា ឆ្នាំ១៩៧៥។ ក្រោយមកទៀត នៅពេលខ្ញុំរវល់ទៅធ្វើបុណ្យភ្ជុំបិណ្ឌដើម្បីសូមឧទ្ទិសកុសលជូនពួកគាត់ ពេលនោះមានបងប្អូននិងអ្នកផ្សេងទៀតមករកគ្រួសារខ្ញុំបាទដល់ផ្ទះទីរួមខេត្តកំពង់ឆ្នាំង។

ប្រសិនបើប្អូន និងលោក លោកស្រីបានទទួលពត៌មានដែលទាក់ទងដល់គ្រួសារខ្ញុំបាទ សូមមេត្តាផ្តល់ដំណឹងមករូបខ្ញុំបាទតាមរយៈអាសយដ្ឋានខាងលើ ឬតាមទូរស័ព្ទលេខ ០១១ ៩៥៧ ២៤៥ ដោយអនុគ្រោះ។ សូមអរគុណ។

# សេចក្តីប្រកាសរកកូនប្រុសឈ្មោះ មាស សុខុម

១) នាងខ្ញុំ អ៊ឹម យារ៉ា អាយុ៧០ឆ្នាំ រស់នៅភូមិស្វាយទាប ឃុំអំពិលក្រៅ ស្រុកស៊ីកណ្តាល ខេត្តព្រៃវែង។ សូមប្រកាសសួររកកូនប្រុសឈ្មោះ មាស សុខុម ដែលបានបាត់ខ្លួននៅក្នុងអំឡុងឆ្នាំ១៩៧៨។ ពេលដែល សុខុម ត្រូវខ្មែរក្រហមបញ្ជូនទៅប្រយុទ្ធជាមួយវៀតណាមនៅទល់ដែនខេត្តកំពង់ចាម។ សុខុម គឺជានិវាសារឃុំអំពិលក្រៅតាំងពីឆ្នាំ១៩៧៤ ក្រោយមកផ្លាស់ទៅធ្វើជានិវាសារស្រុកស៊ីធរកណ្តាល។ មុនពេលអង្គការខ្មែរក្រហមបញ្ជូនទៅសមរភូមិ សុខុម បានមកលេងផ្ទះម្តង ព្រមទាំងបានផ្តាំផ្ញើគាត់និងប្តីគាត់ថាឲ្យប្រយ័ត្នខ្លួន ព្រោះនឹងមានមនុស្សយកទៅសម្លាប់មិនខាន។ តាំងពីនោះមក ក៏បាត់ដំណឹងកូនរហូត។

ប្រសិនបើកូនឈ្មោះ មាស សុខុម បានឃើញសេចក្តីប្រកាសនេះ ឬក៏ញាតិមិត្តណាបានស្គាល់ ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ពត៌មានមកនាងខ្ញុំតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥។ សូមអរគុណ។

# សេចក្តីប្រកាសរកកូនប្រុសឈ្មោះ ម៉ាន ម៉ុន

យស ផេង អាយុ៧២ឆ្នាំ ត្រូវជាម្តាយ ព្រមទាំងកូនស្រី ម៉ាន ម៉ន អាយុ៤៥ឆ្នាំ សូមប្រកាសសួររកកូនប្រុសឈ្មោះ ម៉ាន ម៉ុន ដែលបានចេញពីផ្ទះតាំងពីឆ្នាំ១៩៧៦ បាត់ដំណឹងរហូតដល់សព្វថ្ងៃ។ ដើមឆ្នាំ១៩៧៦ ម៉ាន ម៉ុន ត្រូវខ្មែរក្រហមបង្ខំឲ្យជ្រើក បន្ទាប់មកត្រូវបានបញ្ជូនទៅធ្វើការក្នុងកងជំទ្បួងនៅម្តុំភ្នំពាមជាំង ស្រុកព្រះស្តេច។ តាំងពីពេលនោះមក ម៉ាន់ ម៉ុន មិនបានត្រឡប់មកផ្ទះវិញទេ។

ប្រសិនបើកូនបានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តណាបានស្គាល់ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ពត៌មានមកនាងខ្ញុំតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ឬទូរស័ព្ទលេខ ៨៥៥ ០២៣ ២១១ ៨៧៥។ សូមអរគុណ។



DC-Cam Main Office #66, Preah Sihanouk Blvd, Tonle Bassac, Chamkar Morn, Phnom Penh, Cambodia. Tel: (855) 23 211 875, Fax: (855) 23 210 358, Email: dccam@online.com.kh, Homepage: www.dccam.org
A magazine of the Documentation Center of Cambodia: Searching for the truth. Number 69, September 2005. Funded by Norway, Sweden, and USA.